សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université royale de Droit des Sciences économique
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការ
# នៃមហាអយ្យការអមសាលាឧទ្ធរណ៍

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ហាំង ចាន់សុធិតា**
កញ្ញា **សឿន ច័ន្ទពេជ្របរមី**

សាស្ត្រាចារ្យណែនាំ
លោក **ច័ន្ទ តារារស្មី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវនេះ អាចត្រូវបានសម្រេចឡើងក្រោមការជួយជ្រោមជ្រែងពីសំណាក់បុគ្គលដែលពាក់ព័ន្ធសំខាន់ៗជាច្រើន។

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ហាំង ចាន់សុធិតា** និង **សឿន ច័ន្ទពេជ្របរមី** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ សូមសម្តែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់អ្នកដែលបានជ្រោមជ្រែង ទំនុកបម្រុង និងយកចិត្តទុកដល់ចំពោះរូបយើងខ្ញុំកន្លងមក។

**សូមគោរពលំឱនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត និងមិនអាចកាត់ថ្លៃបានជូនចំពោះ**

លោកឪពុក **សាត សឿន** និង អ្នកម្តាយ **ខួន ស៊ីម**

អ្នកម្តាយ **ហាំង ចាន់ថា**

ហើយក៏សម្តែងនូវការដឹងគុណចំពោះ លោកតា **ជុំ ខួន** លោកយាយ **ហ៊ល នាព** លោកតា **ហាំង សុខ** និងលោកយាយ **គីម អេង។**

ជាអនេកប្បការដែល លោកទាំងពីរបានផ្តល់កំណើតដល់រូបកូន ព្រមទាំងតស៊ូ ពុះពារគ្រប់ឧបសគ្គ ខិតខំចិញ្ចឹមបីបាច់ថែរក្សា កូនតាំងពីកុមារភាពរហូតដល់ធំពេញវ័យ ព្រមទាំងអប់រំទូន្មានប្រៀនប្រដៅ ទំនុកបម្រុងទាំងផ្នែកស្មារតី និងសម្ភារៈឱ្យទទួលបានចំណេះដឹងខ្ពង់ខ្ពស់ តាំងពីការសិក្សាថ្នាក់បឋមរហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ប្រកបដោយជោគជ័យ វាជាមោទកភាពមួយសម្រាប់យើងខ្ញុំ។ កូនសូមក្រាបប្រតិបត្តិ និងសម្តែងនូវកតញ្ញូតាធម៌ចំពោះឧបក្ការៈគុណរបស់លោកទាំងទ្វេលើរូបកូន។

សូមថ្លែងអំណរគុណចំពោះឯកឧត្តមសាកលវិទ្យាធិការ **លុយ ចន្ទណ្ណា** ព្រមទាំងសាកលវិទ្យាធិការរងព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យ និងលោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានផ្តល់ចំណេះដឹង ដំបូន្មានល្អៗជួយបង្ហាត់បង្រៀន និងណែនាំដល់រូបនាងខ្ញុំទាំងពីរយ៉ាងយកចិត្តទុកដាក់ រហូតដល់ការសិក្សាបញ្ចប់បានដោយជោគជ័យ និងប្រកបដោយក្រមវិជ្ជាជីវៈ។

សូមគោរពថ្លែងអំណរគុណលោកសាស្រ្តាចារ្យ **ច័ន្ទ នារាស្មី** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ បង្ហាត់បង្ហាញនូវគំនិត កែតម្រូវ ផ្តល់មតិយោបល់ និងវិធីសាស្រ្តល្អៗ

ទាក់ទងនឹងប្រធានបទតាំងពីដើមរហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ។ ស្នាដៃដែលកើតចេញពីការស្រាវជ្រាវនេះ នឹងមិនអាចលេចចេញជាសមិទ្ធផលបានឡើយ ប្រសិនបើគ្មានវត្តមានរបស់លោក។

សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា អរគុណសន្តិភាព ព្រោះបើគ្មានម្លប់នៃសន្តិភាពទេ នោះយើងខ្ញុំជានិស្សិតមិនអាចសិក្សារៀនសូត្របានចប់ចុងចប់ដើមដោយគ្មានការបារម្ភបានឡើយ។ ពិសេសក្រសួងអប់រំយុវជន និងកីឡាដែលបានផ្ដល់ឱកាសដល់ កុលបុត្រកុលធីតាខ្មែរគ្រប់រូបក៏ដូចជាយើងទាំងពីរបានសិក្សារៀនសូត្រ និងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រឹងវិស័យអប់រំ ដើម្បីបណ្ដុះបណ្ដាលនូវធនធានមនុស្សសម្រាប់ការអភិវឌ្ឍប្រទេសជាតិយើងឱ្យកាន់តែរីកចម្រើនទៅមុខទៀត។

ជាចុងបញ្ចប់យើងទាំងពីរនាក់ សូមធ្វើការអរគុណ និងដឹងគុណម្ដងទៀតដល់អ្នកមានគុណទាំងបួន និងបុគ្គលដែលពាក់ព័ន្ធដូចបានរៀបរាប់ខាងលើ សូមឱ្យលោកប្រកបតែនឹងពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីការសិក្សាអស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កន្លងមក ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រ ក្រេបជញ្ជក់ចំណេះដឹងពីលោក~លោកស្រីសាស្ត្រាចារ្យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលការអនុញ្ញាតពីសាកលវិទ្យាល័យដើម្បីសរសេរសារណាបញ្ចប់ការសិក្សា។

ដោយសារតែយើងខ្ញុំមានចំណាប់អារម្មណ៍ទៅលើមុខវិជ្ជា នីតិវិធីព្រហ្មទណ្ឌ។ មុខវិជ្ជានេះគឺសិក្សាទាក់ទងទៅនឹងនីតិវិធីព្រហ្មទណ្ឌ ជាវិធានច្បាប់មួយដ៏សំខាន់ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងចំណោមវិធានច្បាប់ផ្សេងទៀត សម្រាប់គ្រប់គ្រងសង្គមឱ្យមានស្ថេរភាព សណ្តាប់ធ្នាប់ សុខសន្តិភាព ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឱ្យទទួលបានសុវត្ថិភាពពេញលេញ។ ហើយក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាមានចែងនូវ មុខងារ តួនាទី សិទ្ធិអំណាច របស់អង្គការ ឬស្ថាប័នផ្សេងៗដែលមាន ភារកិច្ចអនុវត្តមុខងាររបស់ខ្លួននៅក្នុងស្ថាប័នតុលាការ។ យើងខ្ញុំក៏សម្រេចជ្រើសរើសប្រធានបទ **“តួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍”** លើកយកមកសរសេរសារណាក្នុងការបញ្ចប់ការសិក្សាបរិញ្ញាបត្រ ដោយមូលហេតុចង់ឱ្យយល់ច្បាស់អំពីតួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមអយ្យការ ដែលអនុវត្តក្នុងស្ថាប័នតុលាការ និងស្ថាប័នអយ្យការ។ ប្រធានបទមួយនេះ គឺផ្តោតសំខាន់ទៅលើចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍។ ចៅក្រមអយ្យការបំពេញមុខងារតួនាទីរបស់ខ្លួន ជាតំណាងឱ្យស្ថាប័នអយ្យការដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គម និងជាអ្នកតំណាងការពារប្រយោជន៍សាធារណៈ ដើម្បីបង្ការ បង្ក្រាប បទល្មើសនានា ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្វីដែលពិសេសនោះគឺខាងរឿងក្តីព្រហ្មទណ្ឌ ព្រោះជាបញ្ហាដែលជះឥទ្ធិពលអាក្រក់ដល់សង្គមជាតិ រំខានដល់ការអភិវឌ្ឍប្រទេសជាតិទាំងមូល។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថា សារណាដែលយើងខ្ញុំទាំងពីរនាក់បានសរសេរឡើងនេះនឹងក្លាយជាឯកសារផ្នែកច្បាប់មួយមានសារៈប្រយោជន៍ ដល់និស្សិតជំនាន់ក្រោយៗទៀត ក្នុងការពង្រឹងពុទ្ធិ និងលើកស្ទួយវិស័យច្បាប់ឱ្យកាន់តែរឹងមាំនិង រីកចម្រើន។ ដោយសារតែនេះជាស្នាដៃដំបូងរបស់យើងខ្ញុំ ថ្វីបើយើងខ្ញុំបានធ្វើការពិនិត្យផ្ទៀងផ្ទាត់រួចមកហើយក្តី ក៏កំហុសឆ្គងនៅតែអាចនឹងកើតមានឡើងជាពុំខាន។ ដូចនេះយើងខ្ញុំសូមធ្វើការអភ័យទោសនូវរាល់កំហុសឆ្គងដោយអចេតនាដែលអាចកើតមានឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ។ យើងខ្ញុំរីករាយនឹងទទួលការរិះគន់ដើម្បីស្ថាបនាបំពេញចន្លោះខ្វះខាតពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បណ្ឌិត និស្សិត និងអ្នកអានទាំងអស់។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ **១**

**ជំពូកទី១**

**សញ្ញាណទូទៅនៃសាលាជម្រះក្តី និងអង្គការអយ្យការ**

**ផ្នែកទី១៖ សាលាជម្រះក្តី** ........................................ **៥**

**កថាខណ្ឌទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាជម្រះក្តី** ........................................ **៥**

ក. តុលាការកំពូល ........................................ **៦**

ខ. សាលាឧទ្ធរណ៍ ........................................ **៨**

គ. សាលាដំបូងរាជធានី~ខេត្ត ........................................ **១១**

**កថាខណ្ឌទី២៖ ប្រព័ន្ធរដ្ឋបាលសាលាជម្រះក្តី** ........................................ **១៤**

ក. លេខាធិការដ្ឋាន ........................................ **១៤**

ខ. អគ្គលេខាធិការដ្ឋាន ........................................ **១៥**

**ផ្នែកទី២៖ អង្គការអយ្យការ** ........................................ **១៦**

**កថាខណ្ឌទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តី** ........................................ **១៧**

ក. មហាអយ្យការអមតុលាការកំពូល ........................................ **១៨**

ខ. មហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ ........................................ **១៨**

គ. អយ្យការអមសាលាដំបូងរាជធានី~ខេត្ត ........................................ **១៩**

**កថាខណ្ឌទី២៖ សមត្ថកិច្ចនៃស្ថាប័នអយ្យការ** ........................................ **១៩**

ក. មន្ត្រីរដ្ឋបាល ........................................ **២០**

ខ. ក្រឡាបញ្ជី ........................................ **២១**

**ជំពូកទី២**

**តួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍**

**ផ្នែកទី១៖ តួនាទីរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍**

**កថាខណ្ឌទី១៖ លក្ខណៈសម្បត្តិ**

ក. ជំនាញវិជ្ជាជីវៈ ..... ២៣
ខ. ការជ្រើសរើស ..... ២៣
គ. ការបណ្ដុះបណ្ដាល ..... ២៤
ឃ. ការតាំងស៊ប់ក្នុងក្របខណ្ឌ ..... ២៤
**កថាខណ្ឌទី២៖ ថ្នាក់ និងឋានន្តរស័ក្តិ ..... ២៤**
ក. ការតែងតាំង ..... ២៤
ខ. ការផ្លាស់ប្ដូរ ..... ២៦
គ. ការផ្អាច់ពីមុខងារ ..... ២៦
ឃ. ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ..... ២៧
ង. ការដាក់ឱ្យនៅទំនេរ និងលុបចោល ..... ២៧
**ផ្នែកទី២៖ សិទ្ធិ និងអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍**
**កថាខណ្ឌទី១៖ ចំពោះកិច្ចការផ្ទៃក្នុង**
ក. ស្ថាប័នសាមី ..... ២៩
ខ. មន្ត្រីរដ្ឋបាល ..... ២៩
គ. បណ្ដឹងឯងទាស់ចំពោះសាលដីកាកំបាំងមុខ ..... ៣០
**កថាខណ្ឌទី២៖ ចំពោះសេចក្ដីសម្រេចរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង**
ក. បណ្ដឹងឧទ្ធរណ៍
១. បណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រម ..... ៣១
២. បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ..... ៣៤
ខ. ការតម្កល់រឿងទុកឥតចាត់ការ ..... ៣៥
គ. ចំពោះព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ..... ៣៦
**កថាខណ្ឌទី៣៖ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ ..... ៣៦**
**កថាខណ្ឌទី៤៖ ចំពោះតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល**
ក. បណ្ដឹងសាទុក្ខ ..... ៣៧
ខ. ចំពោះអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ..... ៣៩

កថាខណ្ឌទី៥៖ ទំនាក់ទំនងការងារផ្សេងៗជាមួយស្ថាប័នជាតិ និងអន្តរជាតិ

ក. ស្ថាប័នជាតិ ........ **៣៩**

ខ. ស្ថាប័នអន្តរជាតិ ........ **៤០**

**សេចក្តីសន្និដ្ឋាន** ........ **៤១**

**អនុសាសន៍** ........ **៤៤**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## មូលហេតុនៃការសិក្សាស្រាវជ្រាវ

ក្នុងការគ្រប់គ្រងរដ្ឋមួយ ច្បាប់ដើរតួនាទីជាអ្នកកំណត់អំពីសិទ្ធិ និងដែនកំណត់នៃសិទ្ធិរបស់ប្រជាពលរដ្ឋ។ ប្រព័ន្ធច្បាប់ដែលប្រើប្រាស់សម្រាប់ដឹកនាំ គ្រប់គ្រងរដ្ឋទាំងអស់លើសកលលោកមាន៤ធំៗរួមមាន ប្រព័ន្ធច្បាប់រ៉ូម៉ាំង ឬស៊ីវិលឡូ (Civil Law) ប្រព័ន្ធច្បាប់កុម្មិនឡូ (Common Law) ប្រព័ន្ធច្បាប់សង្គមនិយម និងប្រព័ន្ធច្បាប់សាសនា។[1] ប៉ុន្តែមានប្រព័ន្ធច្បាប់តែ២ប៉ុណ្ណោះដែលពេញនិយម និងត្រូវបានបណ្ដាប្រទេសជាច្រើនលើពិភពលោកយកមកអនុវត្ត គឺប្រព័ន្ធច្បាប់រ៉ូម៉ាំង ឬស៊ីវិលឡូ(Civil Law) និងប្រព័ន្ធច្បាប់កុម្មិនឡូ(Common Law)។[2] ជាមួយគ្នានេះដែរ ដោយសារតែការធ្លាប់ស្ថិតនៅក្រោមអាណានិគមគ្រប់គ្រងរបស់ប្រទេសបារាំងជិតមួយសតវត្ស ការគ្រប់គ្រងរដ្ឋរបស់ប្រទេសកម្ពុជាក៏ទទួលឥទ្ធិពលពីអតីតប្រទេសមហាអំណាចកាលពីសម័យសតវត្សទី១៨ និង១៩។ បើទោះបីកម្ពុជាធ្លាប់បានហែលឆ្លងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃបន្តបន្ទាប់ មកក្រោយទទួលឯករាជ្យក្តី ផ្លាស់ប្តូររបបគ្រប់គ្រងច្រើនយ៉ាងណាក៏ដោយ បច្ចុប្បន្នកម្ពុជាបានប្រកាន់យក**ប្រព័ន្ធច្បាប់រ៉ូម៉ាំង ឬអាចហៅម្យ៉ាងទៀតថាជា ស៊ីវិលឡូ (Civil Law)** ដែលជាប្រព័ន្ធច្បាប់សរសេរអនុវត្តតាមច្បាប់បានតាក់តែង និងចូលជាធរមាន។ ស្របពេលជាមួយគ្នានេះដែលក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំងមានប្រព័ន្ធនៃការរកភស្តុតាងមួយបែបហៅថា ប្រព័ន្ធនៃការរកភស្តុតាង**អាំងគីស៊ីទ័រ** ជាភាសាបារាំង Inquisitoire។[3] ប្រព័ន្ធនៃការរកភស្តុតាងអាំងគីស៊ីទ័រចង់បានន័យថាតួនាទីក្នុងការរកភស្តុតាងដាក់បន្ទុកក្នុងរឿងក្តីនីមួយៗគឺ ជាសមត្ថកិច្ចរបស់រដ្ឋ។[4]

ក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំង ចៅក្រមគ្មានតួនាទីក្នុងការតាក់តែងច្បាប់ទេ ពោលគឺត្រឹមជាបុគ្គលដែលអនុវត្តច្បាប់ និងបកស្រាយច្បាប់ប៉ុណ្ណោះ។ ទន្ទឹមនឹងនេះក្នុងប្រព័ន្ធនៃការរកភស្តុតាងអាំងគីស៊ីទ័រ ដោយសារតួនាទីក្នុង

---

[1] University of South Carolina, Law Library. (2018). *Guide to International and Foreign Law Research* [ការណែនាំអំពីការស្រាវជ្រាវច្បាប់អន្តរជាតិនិង ច្បាប់បរទេស]. អាចរកបាន នៅhttps://guides.law.sc.edu/c.php?g=315476&p=2108388 (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)

[2] The World Bank. (Updated 2021). *Key Features of Common Law or Civil Law Systems* [លក្ខណៈសំខាន់ៗនៃប្រព័ន្ធច្បាប់ទូទៅឬប្រព័ន្ធច្បាប់ស៊ីវិល]. អាចរកបាននៅ៖ https://ppp.worldbank.org/public-private-partnership/legislation-regulation/framework-assessment/legal-systems/common-vs-civil-law (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)

[3] ចក សម្បត្តិ, *នីតិវិធីព្រហ្មទណ្ឌកម្ពុជា*, (២០១៩), អាចរកបាននៅ៖ https://salatraju.com/post/448 (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)

[4] ឯកឧត្តម កើត រិទ្ធ, *មេរៀនសង្ខេបស្តីពីនីតិវិធីព្រហ្មទណ្ឌ*, នីតិកោសល, រៀបរៀង (២០២០), ទំព័រ៥ អាចរកបាននៅ៖ https://www.facebook.com/1812462692130749/posts/2758586860851656/ (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)

ការរកភស្តុតាងគឺជាសមត្ថកិច្ចរបស់រដ្ឋ កម្ពុជាបានបង្កើតនូវស្ថាប័នមួយ គឺស្ថាប័នអយ្យការដែលស្ថិតនៅក្រោមក្រសួងយុត្តិធម៌ ហើយធ្វើការយ៉ាងជិតស្និតជាមួយសាលាជម្រះក្តីដែលជាទូទៅយើងឃើញថានៅគ្រប់សាលាជម្រះក្តីតែងមានអង្គការអយ្យការអមសាលាជម្រះក្តីនោះ និងមានចៅក្រមអយ្យការជាតំណាងនៃស្ថាប័ននេះ។ នៅក្នុងរឿងព្រហ្មទណ្ឌ យោងតាមមាត្រា១៣១ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ដោយយោងតាមមាត្រា ៥ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី ចុះថ្ងៃទី២៩ ខែមករាឆ្នាំ១៩៩៣ បានចែងថាក្នុងរឿងព្រហ្មទណ្ឌក្រុមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើការសន្និដ្ឋានទោសដោយតាំងខ្លួនជាគូក្តីដើមជាដរាប។ ដោយយោងតាមមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងបន្ថែមទៀតថា បណ្តឹងអាជ្ញា ត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ដោយអយ្យការបានន័យថាព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញា និងជាគូក្តីដើមក្នុងរឿងព្រហ្មទណ្ឌដើម្បីការពារ រក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម តាមរយៈការចោទប្រកាន់ប្រឆាំងនឹងបុគ្គលទាំងឡាយណាដែលបានរំលោភច្បាប់ និងជួយសម្រាលបន្ទុកដល់ជនរងគ្រោះផងដែរ។ ដូចនេះ សបញ្ជាក់ឱ្យឃើញថាព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ និងជាតួអង្គដែលត្រូវបំពេញភារកិច្ចយ៉ាងសកម្មក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌដូចជា ដើមបណ្តឹងអាជ្ញា ជាអ្នកទទួលពាក្យបណ្តឹងបរិហាពីមន្ត្រីនគរបាលយុត្តិធម៌ ការស៊ើបអង្កេតបទល្មើស ការពិនិត្យលើនីត្យានុកូលភាពនៃការស៊ើបអង្កេត ការអនុវត្តសាលក្រម និងការបំពេញតួនាទីផ្សេងៗទៀត ក្នុងនាមជាអ្នកតំណាងឱ្យប្រយោជន៍សាធារណៈ។ ប៉ុន្តែដោយហេតុថាស្ថាប័នអយ្យការមានដល់ទៅបីថ្នាក់ ដូចនេះថាតើតួនាទី សិទ្ធិអំណាចរបស់ចៅក្រមអយ្យការទាំងបីមានលក្ខណៈខុសគ្នាយ៉ាងណាដែរ? សារណានេះនឹងការបង្ហាញពីតួនាទី សិទ្ធិអំណាចរបស់ចៅក្រមអយ្យការដែលស្ថិតនៅអមសាលាជម្រះក្តីជាន់ខ្ពស់ថ្នាក់ទី២ ពោលគឺតួនាទី សិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍។

## ១. លំនាំបញ្ហា

មិនថាសាលាជម្រះក្តី ឬអង្គការអយ្យការដែលស្ថិតនៅអមសាលាជម្រះក្តីទាំងបីថ្នាក់ទេ តួនាទី សិទ្ធិអំណាចចៅក្រមអយ្យការនៃអង្គការអយ្យការ ពិសេសគឺចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ការយល់ដឹង និងការដែលបែងចែកឱ្យដាច់ នៅតែមានភាពស្រពិចស្រពិល និងនៅតែជាមន្ទិលសម្រាប់អ្នកសិក្សា និងប្រជាពលរដ្ឋគ្រប់មូលដ្ឋាននៅឡើយ។

ដូចនេះដើម្បីស្វែងយល់ និងលុបបំបាត់ការភ័ន្តច្រឡំនូវតួនាទី និងសិទ្ធិអំណាចរបស់តួអង្គដែលតំណាងស្ថាប័នអយ្យការនៅកម្រិតសាលាឧទ្ធរណ៍ ក្នុងសារណានេះនឹងរៀបរាប់ពីបញ្ហាខាងលើឱ្យច្បាស់ក្នុងកម្រិត

កិច្ចការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រ ដើម្បីជាជំនួយចំណេះដឹងសម្រាប់មិត្តអ្នកអានទាំងឡាយដែលចង់យល់ដឹង។ ជាពិសេសអ្នកដែលមានបំណងចង់ក្លាយខ្លួនជាតំណាងអយ្យការ។ យើងខ្ញុំសង្ឃឹមថាសារណានេះនឹងអាចក្លាយជាពុទ្ធិដ៏តូចមួយសម្រាប់ជាជំនួយក្នុងការពង្រឹងភាពច្បាស់លាស់ ត្រឹមត្រូវដែលជាកង្វល់កន្លងមករបស់មហាជនចំពោះតួនាទី សិទ្ធិអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍ និងនីតិវិធីផ្សេងៗទៀតដែលមានភ្ជាប់ក្នុងកិច្ចការនេះ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ជាគោលការណ៍ បើទោះបីជាចៅក្រមអយ្យការនៃអង្គការអយ្យការស្ថិតនៅអមសាលាជម្រះក្តី ក៏ដោយកាតព្វកិច្ច ភារកិច្ចរបស់ព្រះរាជអាជ្ញាមានលក្ខណៈដាច់ដោយឡែកពីចៅក្រមជំនុំជម្រះ និងមានលក្ខណៈខុសគ្នាទៅតាមកម្រិតសាលាជម្រះក្តីដែលខ្លួននៅអម។ ដើម្បីឱ្យយល់កាន់តែច្បាស់ និងស៊ីជម្រៅនូវខ្លឹមសារនៃប្រធានបទសារណាដែលបានលើកឡើងនេះ បង្ហាញឱ្យឃើញនូវបញ្ហាគតិយុត្តិមួយចំនួនរួមមាន៖

- តើតួនាទីរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍មានអ្វីខ្លះ?
- តើអ្វីខ្លះជាសិទ្ធិអំណាចរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវសារណានេះដែរ គឺធ្វើឡើងក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់អំពីភាពមិនច្បាស់លាស់មួយចំនួន ក៏ដូចជាចង់ស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តិដូចដែលបានលើកឡើងពីខាងលើស្រាប់។ លើសពីនេះទៅទៀត គឺដើម្បីពង្រឹង និងពង្រីកនូវសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀតដែលទាក់ទងនិងវិស័យព្រហ្មទណ្ឌនេះ ពិសេសគឺនីតិវិធីព្រហ្មទណ្ឌ។ ហើយចំពោះសមិទ្ធផល ដែលបានមកពីការសិក្សាស្រាវជ្រាវនេះសង្ឃឹមអាចក្លាយជាផ្នែកមួយនៃការរួមចំណែកក្នុងការអភិវឌ្ឍនូវវិស័យព្រហ្មទណ្ឌរបស់ ព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងជ្រើសរើសនូវឯកសារជាមូលដ្ឋានមួយចំនួនដើម្បីសរសេរជាសារណានេះឡើង ដែលឯកសារទាំងនោះរួមមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ជាឯកសារគោល និងមានឯកសារច្បាប់ដទៃមួយចំនួនទៀតដូចជា រដ្ឋធម្មនុញ្ញចាស់ ព្រះរាជក្រឹត្យ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័នដែលទាក់ទងទៅនឹងប្រធានបទ ជាឯកសារបន្ទាប់បន្សំសម្រាប់ជាជំនួយស្មារតីដែលពាក់ព័ន្ធទៅនឹងប្រធានបទ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះការជ្រើសរើសប្រធានបទខាងលើមកធ្វើការសិក្សាស្រាវជ្រាវ ព្រោះថាប្រធានបទមួយនេះពិតជាមានសារៈសំខាន់ណាស់ចំពោះបណ្ដាអ្នកច្បាប់ អ្នកសិក្សាស្រាវជ្រាវអំពីវិស័យច្បាប់ និស្សិតដែលសិក្សាមុខវិជ្ជានីតិសាស្ត្រនៅមហាវិទ្យាល័យច្បាប់នានា ដោយបានផ្ដល់ជាឯកសារសម្រាប់ការស្រាវជ្រាវឱ្យបានស៊ីជម្រៅនៅក្នុងការអនុវត្តជាក់ស្ដែងរបស់អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៅអមសាលាឧទ្ធរណ៍ និងអាចបែងចែកឱ្យដាច់ពីតួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការទៅតាមកម្រិតថ្នាក់។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា អត្ថាធិប្បាយ។ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយធ្វើការប្រមូលនូវព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដែលមានប្រភពត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធិភាពខ្ពស់ដូចជាការបកស្រាយរបស់នីតិករ អ្នកមានបទពិសោធន៍នៅក្នុងវិស័យច្បាប់នេះផ្ទាល់ ស្នើសុំមតិយោបល់ពីអ្នកមានជំនាញការខាងច្បាប់ព្រហ្មទណ្ឌ ពិសេសគឺលោកសាស្ត្រាចារ្យដែលជាអ្នកដឹកនាំ ណែនាំផ្ទាល់ និងច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា និងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ជាបន្តទៀតដើម្បីឆ្លើយតបទៅនឹងប្រធានបទ **តួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍** យើងសូមធ្វើការបែងចែកប្រធានបទនេះជា២ជំពូកធំៗគឺ៖

- ជំពូក១៖ សញ្ញាណទូទៅនៃសាលាជម្រះក្ដី និងអង្គការអយ្យការ
- ជំពូក២៖ តួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍។

ដោយជំពូកនីមួយៗនឹងមានការបកស្រាយយ៉ាងលម្អិតនៅទំព័របន្តបន្ទាប់៖

# ជំពូកទី១

## សញ្ញាណទូទៅនៃសាលាជម្រះក្តី និងអង្គការអយ្យការ

# ជំពូកទី១
# សញ្ញាណទូទៅនៃសាលាជម្រះក្តី និងអង្គការអយ្យការ

## ផ្នែកទី១៖ សាលាជម្រះក្តី

នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា[5] ត្រង់មាត្រា ៥១ថ្មី បានកំណត់ថាអំណាចសំខាន់បីរបស់រដ្ឋត្រូវបានបែងចែកដាច់ពីគ្នា អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ អំណាចតុលាការនេះផងដែរត្រូវតំណាងដោយ សាលាជម្រះក្តី ដែលប្រព័ន្ធសាលាជម្រះក្តីនៅកម្ពុជាត្រូវបានបែងចែកចេញជា ០៣ (បី) ថ្នាក់ ឬ ០២ (ពីរ) ជាន់។[6] សាលាជម្រះក្តីជាន់ទាបមានមួយថ្នាក់ គឺ សាលាដំបូងរាជធានី~ខេត្ត[7] និងជាន់ខ្ពស់មាន២ថ្នាក់គឺ សាលាឧទ្ធរណ៍តំបន់ និងតុលាការកំពូល។ ប្រព័ន្ធតុលាការ ឬប្រព័ន្ធសាលាជម្រះក្តីនៅកម្ពុជាមានអំណាចឯករាជ្យមួយក្នុងការជំនុំជម្រះគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។[8] មកដល់បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានតុលាការកំពូលមួយ សាលាឧទ្ធរណ៍តំបន់៤ និងសាលាដំបូងរាជធានី~ខេត្ត២៥។[9]

### កថាខណ្ឌទី១ ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាជម្រះក្តី

ការកាត់ក្តីរកយុត្តិធម៌ គឺកើតមានឡើងជាយូរណាស់មកហើយ តែអំណាចក្នុងការរកយុត្តិធម៌ខុសត្រូវសខ្មៅ ត្រូវបានប្រគល់ និងបង្កើតជាអំណាចតុលាការមួយ។ ឆ្លងតាមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាឆ្នាំ១៩៤៧~១៩៧០ សម័យសង្គមរាស្ត្រនិយម មាត្រា ៩៥ បានចែងអំពីការរៀបចំភារៈនៃអំណាចតុលាការ។ ក្រោយមករដ្ឋធម្មនុញ្ញសាធារណៈរដ្ឋខ្មែរ ឆ្នាំ១៩៧០~១៩៧៥ ក៏បានចែងអំពីអំណាចតុលាការចាប់ពីមាត្រា ៨០ ដល់មាត្រា ៨៨។ ពាក្យតុលាការកំពូលក៏ត្រូវបានប្រើក្នុងសម័យកាលនោះដូចបានកំណត់ត្រង់មាត្រា ៨១ថា៖

> *អំណាចតុលាការ ជាអំណាចប្រកបដោយឥស្សរភាព អំណាចតុលាការរក្សាការពារ*
> *អនាគត។ អំណាចតុលាការការពារសិទ្ធិ និងសេរីភាពពលរដ្ឋ។អំណាចនេះត្រូវ*

---

[5] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា១៥០ ថ្មី (មាត្រា១៣១ ចាស់) កថាខណ្ឌទី១ វាក្យខណ្ឌទី១

[6] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា៣។

[7] តុលាការយោធា ក៏ត្រូវបានចាត់ចូលជាសាលាជម្រះក្តីជាន់ទាបផងដែរ ដោយតុលាការនេះមានលក្ខណៈពិសេស ទទួលដោះស្រាយតែទៅលើរឿងក្តីដែលមានចរិតលក្ខណៈ ជាប្រភេទបទល្មើសយោធា។ តុលាការយោធាមានតែមួយប៉ុណ្ណោះ គឺមានទីតាំងក្នុងរាជធានីភ្នំពេញ ប៉ុន្តែមានយុត្តាធិការលើគ្រប់សំណុំរឿងបទល្មើសយោធាទូទាំងប្រទេស ។

[8] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា៤។

[9] ព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០២១ ដែលមាន ៦ ប្រការ បានត្រាស់បង្គាប់ឱ្យដាក់ដំណើរការសាលាដំបូងខេត្តកែបចាប់ពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០២១ ដោយនៅអមសាលាដំបូងខេត្តកែបមានអយ្យការមួយស្របតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំអង្គតុលាការ និងច្បាប់ជាធរមានពាក់ព័ន្ធដទៃផ្សេងទៀត។

*បានប្រគល់ជូនទៅតុលាការកំពូល និងទៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។*

ក្រោយមកប្រទេសកម្ពុជាត្រូវបានធ្លាក់ចូលក្នុងគ្រោះមហន្តរាយដ៏ធំធេងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ០៦ ខែមករា ឆ្នាំ១៩៧៩ ដែលប្រជាជនកម្ពុជាស្គាល់ជាទូទៅថា របបប៉ុលពត ដែលក្នុងរយៈពេល ០៣ឆ្នាំ ០៨ខែ ២០ថ្ងៃនៃរបបនេះអ្វីៗត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងក្នុងនោះប្រព័ន្ធតុលាការក៏ត្រូវបានលុបបំបាត់ចោលទាំងស្រុងដែរ។ ក្រោយរំដោះថ្ងៃទី ០៧ ខែមករា ឆ្នាំ១៩៧៩ កម្ពុជាបានចាប់ផ្តើមកសាងប្រទេសរបស់ខ្លួនតាំងពីបាតដៃទទេ ហើយនៅអំឡុងឆ្នាំ១៩៨២ ដែលប្រទេសកម្ពុជានាពេលនោះមានឈ្មោះថាសាធារណរដ្ឋប្រជាមានិតកម្ពុជា ពាក្យតុលាការកំពូលបានលេចឡើងជាថ្មីម្តងទៀត។

**ក. តុលាការកំពូល**

នៅប្រទេសកម្ពុជានៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ស្ថាប័នតុលាការនៅពេលនោះមានឈ្មោះថាតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល។[10] តុលាការនេះត្រូវបានអនុម័តបង្កើតដោយរដ្ឋសភាសាធារណៈរដ្ឋប្រជាមានិតកម្ពុជាតាមក្រឹត្យលេខ ២៨ ក្រចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥។[11] ហើយរាល់សកម្មភាពកិច្ចការរបស់តុលាការនេះត្រូវកំណត់ដោយច្បាប់ដាច់ដោយឡែកផ្សេងមួយទៀតគឺ ក្រឹត្យលេខ ៣៤ក្រ. ស្តីពី ការចាត់តាំងនឹងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ក៏ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៧។ មកដល់សម័យរដ្ឋកម្ពុជាក្នុងឆ្នាំ១៩៩៣ ប្រទេសយើងបានបង្កើតច្បាប់ស្តីពី ការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដោយច្បាប់នេះ បានរៀបចំរចនាសម្ព័ន្ធតុលាការនៅកម្ពុជាសារជាថ្មី។

ចំពោះច្បាប់ទាំង៣ ខាងលើដែលពាក់ព័ន្ធនឹងតុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូលនេះមានមាត្រាមួយចំនួនធំត្រូវបាននិរាករណ៍ដោយច្បាប់ក្រោយៗផង និងដោយច្បាប់ផ្សេងៗផងជាពិសេសគឺមាត្រាទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហានីតិវិធីដោយសារមាន ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦មកជំនួស រីឯរចនាសម្ព័ន្ធការងារគឺរក្សាដដែល។ នៅក្នុងឆ្នាំ២០១៤ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាត្រូវបានអនុម័តដែលជាកំណែទម្រង់ស៊ីជម្រៅមួយនៃប្រព័ន្ធយុត្តិធម៌ ក៏ដូចជាប្រព័ន្ធតុលាការនេះ។ សព្វថ្ងៃតុលាការកំពូលមានតែមួយប៉ុណ្ណោះនៅកម្ពុជាគឺ ស្ថិតនៅរាជធានីភ្នំពេញ។

---

[10] កុយ នាម, *ការសិក្សាប្រៀបធៀបអំពីតុលាការកំពូល,* (២០១៧), ទំព័រ១។

[11] គេហទំព័រ តុលាការកំពូល និងមហាអយ្យការ,ប្រវត្តិសង្ខេបនៃការបង្កើតតុលាការកំពូល និង មហាអយ្យការអមតុលាការកំពូល. អាចរកបាននៅ៖ http://www.supremecourt.gov.kh/about (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)

❖ សមាសភាពរបស់តុលាការកំពូលៈ

សមាសភាពរដ្ឋបាល និងសមាសភាពជំនុំជម្រះក្តីរបស់តុលាការកំពូលបានកំណត់នៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិនីតិវិធីជាធរមានផ្សេងទៀត។[12] សមាសភាពរដ្ឋបាលរបស់តុលាការកំពូលមានប្រធាន ០១ (មួយ) រូប អនុប្រធានមួយចំនួន ចៅក្រម ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងមន្ត្រីជំនាញផ្នែកច្បាប់មួយចំនួនផ្សេងទៀត ដែលបម្រើការងារនៅតុលាការកំពូល។ បច្ចុប្បន្នប្រធានតុលាការកំពូលគឺ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ឌិត មន្ទី។[13]

សមាសភាពជំនុំជម្រះក្តីរបស់តុលាការកំពូលគឺ អាស្រ័យទៅលើប្រភេទនៃបណ្តឹង និងប្រភេទនៃរឿងក្តី (សភាជំនាញ)។ បណ្តឹងដែលតុលាការកំពូលមានសមត្ថកិច្ចដោះស្រាយមាន បណ្តឹងសាទុក្ខ និងបណ្តឹងសើរើ។[14] សមាសភាពជំនុំជម្រះក្តីរបស់តុលាការកំពូលមានការកំណត់ និងបែងចែកទាំងពីសម័យសាធារណៈរដ្ឋខ្មែរមកដែលនៅពេលនោះចៅក្រមប្រធានត្រូវគេហៅថា ចាងហ្វាង។[15]

តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយវិវាទក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ពោលគឺគ្រប់សាលាជម្រះក្តីក្នុងផ្ទៃប្រទេស និងតាមការកំណត់របស់ច្បាប់ដែលអាស្រ័យទៅលើប្រភេទនៃរឿងក្តី ស្របទៅតាមសភាជំនាញ និងអនុវត្តទៅតាមនីតិវិធីដែលមានជាធរមាន។[16]




[12] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥៩

[13] គេហទំព័រ តុលាការកំពូល និងមហាអយ្យការ, រចនាសម្ព័ន្ធតុលាការកំពូល: http://www.supremecourt.gov.kh/judge

[14] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៦២

[15] រដ្ឋធម្មនុញ្ញសាធារណៈរដ្ឋខ្មែរ, ៣០ មេសា ១៩៧២, ជំពូក៧ អំណាចតុលាការ មាត្រា ៨៦ តុលាការកំពូល

[16] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥៧ មាត្រា ៦១ មាត្រា ៦៤ មាត្រា៦៥ មាត្រា ៦៦ និងមាត្រា ៦៧







**ខ. សាលាឧទ្ធរណ៍**

ដូចដែលបានលើកឡើងពីខាងលើ បើទោះបីជាក្នុងរដ្ឋធម្មនុញ្ញនៅសម័យសាធារណៈរដ្ឋកម្ពុជាបានចែងថាមានតុលាការថ្នាក់ក្រោមតុលាការកំពូលក៏ដោយ តែឯកសារជាច្រើនត្រូវបានបាត់បង់ រហូតដល់ឆ្នាំ១៩៩៣ ក្នុងសម័យរដ្ឋកម្ពុជាទើបមានច្បាប់ចែងច្បាស់ពីសាលាឧទ្ធរណ៍ ក៏ដូចជាការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័នមួយនេះ។[17] ចាប់តាំងពីរដ្ឋកម្ពុជា រហូតមកដល់មុនថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ កម្ពុជាមានសាលាឧទ្ធរណ៍តែមួយគត់ បើទោះបីច្បាប់កំណត់ថាអាចមានសាលាឧទ្ធរណ៍តំបន់។ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យចំនួនបីបានប្រកាសឱ្យដាក់ដំណើរការសាលាឧទ្ធរណ៍តំបន់ថ្មីបីបន្ថែម ក៏ដូចជាព្រះរាជក្រឹត្យស្ដីពីការដាក់ដំណើរការសាលាឧទ្ធរណ៍ភ្នំពេញដោយមានការកែប្រែដែនសមត្ថកិច្ច។

[17] ច្បាប់ស្ដីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្ដីនៃរដ្ឋកម្ពុជា, ក្រឹត្យលេខ ០៦ រក្រ, ០៦ កុម្ភៈ ១៩៩៣, មាត្រា ១ មាត្រា ៣ មាត្រា ១០ មាត្រា ១១ មាត្រា ១២ និងមាត្រា ១៣

គួរបញ្ជាក់ផងដែរថា សាលាឧទ្ធរណ៍តំបន់ទាំង៤មានៈ **សាលាឧទ្ធរណ៍ភ្នំពេញ** ដែលមានទីតាំងនៅរាជធានីភ្នំពេញ ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងរាជធានីភ្នំពេញ និងខេត្តកណ្តាល ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។[18] **សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ** មានសមត្ថកិច្ចមានសមត្ថកិច្ចដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ចាម សាលាដំបូងខេត្តកំពង់ធំ សាលាដំបូងខេត្តព្រះវិហារ សាលាដំបូងខេត្តក្រចេះ សាលាដំបូងខេត្តស្ទឹងត្រែង សាលាដំបូងខេត្តរតនគិរី សាលាដំបូងខេត្តមណ្ឌលគិរី សាលាដំបូងខេត្តព្រៃវែង សាលាដំបូងខេត្តស្វាយរៀង សាលាដំបូងខេត្តត្បូងឃ្មុំ ឬករណីសំណុំរឿង ដែលតុលាការកំពូលបានបង្វិលមកវិញ។[19] **សាលាឧទ្ធរណ៍តំបន់បាត់ដំបង** មានសមត្ថកិច្ចដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ឆ្នាំង សាលាដំបូងខេត្តពោធិ៍សាត់ សាលាដំបូងខេត្តបាត់ដំបង សាលាដំបូងខេត្តប៉ៃលិន សាលាដំបូងខេត្តបន្ទាយមានជ័យ សាលាដំបូងខេត្តឧត្តរមានជ័យ សាលាដំបូងខេត្តសៀមរាប ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។[20] **សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ** មានសមត្ថកិច្ចមានសមត្ថកិច្ចដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តតាកែវ សាលាដំបូងខេត្តកំពត និងអយ្យការអមសាលាដំបូងខេត្តកំពត សាលាដំបូងខេត្តកំពង់ស្ពឺ សាលាដំបូងខេត្តកោះកុង សាលាដំបូងខេត្តព្រះសីហនុ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។[21]

❖ សមាសភាពរបស់សាលាឧទ្ធរណ៍ៈ

សមាសភាពរដ្ឋបាល និងសមាសភាពជំនុំជម្រះក្តីរបស់សាលាឧទ្ធរណ៍បានកំណត់នៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិនីតិវិធីជាធរមានផ្សេងទៀត។[22] សមាសភាពរដ្ឋបាលរបស់សាលាឧទ្ធរណ៍មានប្រធាន ០១ (មួយ) រូប អនុប្រធានមួយចំនួន ចៅក្រម

[18] ព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ, លេខ នស/រកត/០៨១៩/១៣០០, ១៧ សីហា ២០១៩

[19] ព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ, លេខ នស/រកត/០៨១៩/១៣០១, ១៧ សីហា ២០១៩

[20] ព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង, លេខ នស/រកត/០៨១៩/១៣០២, ១៧ សីហា ២០១៩

[21] ព្រះរាជក្រឹត្យស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ, លេខ នស/រកត/០៨១៩/១៣០៣, ១៧ សីហា ២០១៩

[22] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា៣៦ មាត្រា៣៨ មាត្រា៣៩ មាត្រា៤៣ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៧

ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងមន្ត្រីជំនាញផ្នែកច្បាប់មួយចំនួនផ្សេងទៀត ដែលបម្រើការងារនៅសាលាឧទ្ធរណ៍។ បច្ចុប្បន្នប្រធានសាលាឧទ្ធរណ៍ភ្នំពេញគឺ ឯកឧត្តម សេង ស៊ីវុត្ថា។[23] ប្រធានសាលាឧទ្ធរណ៍តំបន់បាត់ដំបង សព្វថ្ងៃគឺ ឯកឧត្តម សម ប៊ុនថុន។ សម្រាប់សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំមាន ឯកឧត្តម ម៉ុង មុនីចរិយា ជាប្រធាន។[24] ឯសាលាឧទ្ធរណ៍តំបន់ព្រះសីហនុមាន ឯកឧត្តម សុខ កល្យាណ ជាប្រធាន។[25]

សមាសភាពជំនុំជម្រះក្តីរបស់សាលាឧទ្ធរណ៍ ចំពោះបណ្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមរបស់សាលាដំបូងត្រូវសម្រេចសេចក្តីដោយចៅក្រម ០៣ (បី) រូប សម្រាប់គ្រប់ប្រភេទនៃរឿងក្តី ០១ (មួយ) រូបជាប្រធាន ០២ (ពីរ) រូបជាចៅក្រមប្រឹក្សាដែលមានសមត្ថភាព និងជំនាញទៅតាមប្រភេទនៃរឿងក្តី។ មានតំណាងមហាអយ្យការ ០១ (មួយ) រូប ក្រឡាបញ្ជី ០១ (មួយ) រូប ជាលេខាកត់ត្រា (ជំនួយការកត់ត្រា) មេធាវីរបស់គូក្តី ជាអ្នកចូលរួម បើសិនជាមាន។




សមាសភាពជំនុំជម្រះក្តីរបស់សាលាឧទ្ធរណ៍ ចំពោះរឿងក្តីណាដែលបានបង្វិលពីតុលាការកំពូលមកវិញ នោះសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះដោយចៅក្រម ០៥ (ប្រាំ) រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះលើកមុន។

[23] ព្រះរាជក្រឹត្យស្តីពីការផ្ទេរ និងតែងតាំងមុខតំណែង ប្រធាន អនុប្រធាន និងចៅក្រម, លេខ នស/រកត/០៥២១/៤០៩, មាត្រា ១ ចំណុចទី ២

[24] ព្រះរាជក្រឹត្យស្តីពីការតែងតាំង ប្រធាន អនុប្រធាន សាលាឧទ្ធរណ៍តំបន់, លេខ នស/រកត/០២២០/២០៩, មាត្រា ១ ចំណុចទី ១ និង ចំណុចទី ២

[25] ព្រះរាជក្រឹត្យស្តីពីការតែងតាំងមុខតំណែងជាប្រធាន និងចៅក្រម នៃសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ, លេខ នស/រកត/០៧២០/៧៧៣, មាត្រា ១ ចំណុចទី ១




សាលាឧទ្ធរណ៍ មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីគ្រប់ប្រភេទដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេង។ សាលាឧទ្ធរណ៍មានសិទ្ធិជំនុំជម្រះអង្គហេតុ និងអង្គច្បាប់ដូចសាលាដំបូងដែរ។ មានសិទ្ធិស៊ើបអង្កេត ស្វែងរកភស្តុតាង និងបដិសេធ កែប្រែតម្កល់រាល់ការសម្រេចរបស់តុលាការថ្នាក់ក្រោម។

**គ. សាលាដំបូងរាជធានី-ខេត្ត**

ក្រោយពីកម្ពុជាទទួលបានឯករាជ្យ មានលទ្ធភាពក្នុងការគ្រប់គ្រងប្រទេសដោយខ្លួនឯងវិញបាន កម្ពុជាបានបង្កើតនូវច្បាប់ជាច្រើនសម្រាប់ការគ្រប់គ្រង អនុវត្ត និងអភិវឌ្ឍន៍ជាតិ។ ក្នុងនោះអំណាចតុលាការក៏ត្រូវបានបង្កើតឡើងបើទោះបីជាមិនទាន់មានការបែកចែង ០២ (ពីរ) ជាន់ថ្នាក់នៃតុលាការក៏ដោយ។ រហូតមកដល់សម័យសាធារណៈរដ្ឋខ្មែរ ទោះបីជានៅក្នុងរដ្ឋធម្មនុញ្ញមានបានលើកឡើងពីតុលាការកំពូល តុលាការជាន់ខ្ពស់ ជាន់ទាប មានច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងអយ្យការអមតុលាការប្រជាជនកំពូល ថែមទៀតផងក៏ដោយ ប៉ុន្តែមិនមានឯកសារណាបញ្ជាក់អំពីតុលាការជាន់ទាប ដូចជាសាលាដំបូងឡើយ។ លុះមកដល់សម័យរដ្ឋកម្ពុជា មានឯកសារមួយចំនួនបានសរសេរតាក់តែងឡើងទាក់ទងនឹងការបែកចែងជាន់ថ្នាក់នៃប្រព័ន្ធតុលាការដែលក្នុងនោះមានតុលាការជាន់ទាប ដែលបច្ចុប្បន្នស្គាល់ថាជាសាលាដំបូងរាជធានី-ខេត្ត។ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ចាប់ពីមាត្រា ៧៩ ដល់ មាត្រា ៨៥ បានចែងពីសាលាជម្រះក្តី។ ដោយយោងតាម រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ត្រូវបានបង្កើតឡើងដោយរដ្ឋសភានៃរដ្ឋកម្ពុជា[26] និងប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋ[27] ក្នុងនោះមានច្បាប់មួយគឺ ក្រឹត្យលេខ០៦ រក្រ ចុះថ្ងៃ

[26] រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា, ២៥ មិថុនា ១៩៨១, មាត្រា ៤៦

[27] រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា, ២៥ មិថុនា ១៩៨១, មាត្រា ៦០ថ្មី

ទី០៦ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីរដ្ឋកម្ពុជា។ ក្នុងច្បាប់នោះបានបញ្ជាក់ថាវត្តមានសាលាជម្រះក្តីជាន់ទាបចាប់ផ្តើមមានពិតប្រាកដពីពេលនោះមក ត្រង់មាត្រា២ នៃច្បាប់នេះចែងថាតុលាការខេត្តក្រុង និងតុលាការយោធាជាសាលាជម្រះក្តីជាន់ទាប។ សព្វថ្ងៃសាលាដំបូងរាជធានី-ខេត្តមាន២៥ ដោយសារថ្មីៗសាលាដំបូងខេត្តកែបនឹងត្រូវដាក់ឱ្យដំណើរការចាប់ពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០២១ នេះតទៅ។[28]

❖ សមាសភាពរបស់សាលាដំបូង៖

សមាសភាពរដ្ឋបាល និងសមាសភាពជំនុំជម្រះក្តីរបស់សាលាដំបូងបានកំណត់នៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិនីតិវិធីជាធរមានផ្សេងទៀត។[29] សមាសភាពរដ្ឋបាលរបស់សាលាដំបូងមានប្រធាន ០១ (មួយ) រូប អនុប្រធានមួយចំនួន ចៅក្រម ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងមន្ត្រីជំនាញផ្នែកច្បាប់មួយចំនួនផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង។

សមាសភាពជំនុំជម្រះក្តីរបស់សាលាដំបូងគឺអាស្រ័យលើប្រភេទនៃក្តី ដែលសាលាដំបូងរាជធានី-ខេត្តមានតុលាការជំនាញ៤ គឺតុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ តុលាការពាណិជ្ជកម្ម និងតុលាការការងារ។[30] តុលាការជំនាញនីមួយៗនៃសាលាដំបូង សម្រេចសេចក្តីដោយមានចៅក្រមទោល ០១ (មួយ) រូប ឬដោយក្រុមប្រឹក្សា ដោយអនុលោមតាមបទប្បញ្ញត្តិពីស្តីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិពីនីតិវិធីជាធរមានផ្សេងទៀត។ ប៉ុន្តែសម្រាប់តុលាការជំនាញផ្នែកពាណិជ្ជកម្ម និងការងារការសម្រេចសេចក្តីសមាសភាពជំនុំជម្រះមានលក្ខណៈពិសេស។




[28] ព្រះរាជក្រឹត្យស្តីពីការដាក់ដំណើរការ សាលាដំបូងខេត្តកែប, លេខ នស/រកត/០៤២១/៣៤៥ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២១

[29] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ១៣ មាត្រា ១៥ មាត្រា ១៦ មាត្រា ២០ មាត្រា ២១ មាត្រា ២៣ និងមាត្រា ២៦

[30] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា ១៤


ចៅក្រម
តំណាងអយ្យការ
ក្រឡាបញ្ជី
សម្រាប់ជំនុំជម្រះក្ដីលើរឿងក្ដីពាណិជ្ជកម្មកម្មវត្ថុបណ្ដឹងមានតម្លៃ
ក្រោម១០០.០០០.០០០ (មួយរយលាន)រៀល


ទីប្រឹក្សា(ពាណិជ្ជករ)
ចៅក្រម
ចៅក្រម
ចៅក្រម
ទីប្រឹក្សា(ពាណិជ្ជករ)
តំណាងអយ្យការ
ក្រឡាបញ្ជី
សម្រាប់ជំនុំជម្រះក្ដីលើរឿងក្ដីពាណិជ្ជកម្មកម្មវត្ថុបណ្ដឹងមានតម្លៃ
ចាប់ពី១.០០០.០០០.០០០(មួយពាន់លាន)រៀលឡើងទៅ


ទីប្រឹក្សា(និយោជិត)
ចៅក្រម
ទីប្រឹក្សា(និយោជក)
តំណាងអយ្យការ
ក្រឡាបញ្ជី
សម្រាប់ជំនុំជម្រះក្ដីលើរឿងវិវាទការងារ

**កថាខណ្ឌទី២៖ ប្រព័ន្ធរដ្ឋបាលសាលាជម្រះក្តី**

បើទោះបីជាសាលាជម្រះក្តី ជាកន្លែងសម្រាប់ជំនុំជម្រះកាត់ក្តី ស្វែងរកយុត្តិធម៌ក៏ពិតមែន ប៉ុន្តែនៅគ្រប់ជាន់ថ្នាក់នៃសាលាជម្រះក្តី សុទ្ធតែមានប្រព័ន្ធរដ្ឋបាលមួយដែលអង្គភាពរដ្ឋបាលនោះស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ។ រដ្ឋបាលសាលាជម្រះក្តីនៅគ្រប់ជាន់ថ្នាក់មាន លេខាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋាន ដែលនៅថ្នាក់សាលាដំបូង អង្គភាពរដ្ឋបាលហៅថា លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមានថ្នាក់ស្មើនឹងនាយកដ្ឋាន។ ចំណែកឯនៅថ្នាក់សាលាឧទ្ធរណ៍ហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ និងនៅថ្នាក់តុលាការកំពូលហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ដែលអគ្គលេខាធិការដ្ឋានរដ្ឋបាលទាំងពីរមានថ្នាក់ស្មើនឹងអគ្គនាយកដ្ឋាន។ ដោយសារតែអង្គភាពរដ្ឋបាលទាំងនេះស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ធ្វើឱ្យក្រសួងមានសិទ្ធិត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ តាមរយៈអគ្គនាយកដ្ឋានរដ្ឋបាលតុលាការនៃក្រសួងយុត្តិធម៌ជាសេនាធិការ។ ដំណើរការប្រព្រឹត្តទៅ និងការគ្រប់គ្រងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់ត្រូវធ្វើតាមលិខិតបទដ្ឋានគតិយុត្តិ និងសេចក្តីណែនាំរបស់ក្រសួង។[31]

**ក. លេខាធិការដ្ឋាន**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង មិនត្រឹមតែជាអ្នកចាត់ចែងការងារសាលាដំបូងទេ ថែមទាំងចាត់ចែងកិច្ចការអយ្យការដែលនៅអមផងដែរ។ កិច្ចការដែលលេខាធិការសាលាដំបូងត្រូវធ្វើគឺ៖

- ចាត់ចែងការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ និងរបាយការណ៍ជាប្រចាំជូនប្រធានសាលាដំបូង និងព្រះរាជអាជ្ញា
- រៀបចំ គ្រប់គ្រងការងាររដ្ឋបាល សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- រៀបចំគម្រោងថវិកាជូនប្រធានសាលាដំបូង និងព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងសម្រេច រួចអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- បញ្ជូនសាលក្រមរបស់សាលាដំបូង និងរបាយការណ៍ការងារបុគ្គលិក និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌។

សមាសភាពនៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង មានប្រធាន ០១ (មួយ) រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។ ប្រធាន និងអនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ

[31] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ១០ និងមាត្រា ១១

ដែលប្រធានត្រូវតែងតាំងដោយអនុក្រឹត្យ និងមន្ត្រីថ្នាក់ដទៃទៀតតែងតាំងដោយប្រកាស។ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង អាចត្រូវបានបែងចែកជាការិយាល័យតាមចំនួនការងារ ចាំបាច់ជាក់ស្តែង។ ហើយប្រធាន និងអនុប្រធានការិយាល័យ ត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិច ០៣ (បី) ឆ្នាំ។

**ខ. អគ្គលេខាធិការដ្ឋាន**

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ និងតុលាការកំពូល មិនត្រឹមតែជាអ្នកចាត់ចែងការងារសាលាជម្រះក្តីជាន់ខ្ពស់ទាំងពីរនេះទេ ថែមទាំងចាត់ចែងកិច្ចការមហាអយ្យការដែលនៅអមផងដែរ។ កិច្ចការដែលអគ្គលេខាធិការដ្ឋានរដ្ឋបាលត្រូវធ្វើគឺ៖

- ចាត់ចែងការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ និងរបាយការណ៍ជាប្រចាំជូនប្រធានសាលាជម្រះក្តីរៀងខ្លួន និងអគ្គព្រះរាជអាជ្ញា
- រៀបចំ គ្រប់គ្រងការងាររដ្ឋបាល សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាជម្រះក្តីរៀងខ្លួន និងមហាអយ្យការដែលនៅអម
- រៀបចំគម្រោងថវិកាជូនប្រធានសាលាជម្រះក្តីរៀងខ្លួន និងអគ្គព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងសម្រេច រួចអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- បញ្ជូនសាលដី របស់សាលាជម្រះក្តីរៀងខ្លួន និងរបាយការណ៍ការងារបុគ្គលិក និងហរិញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌។

សមាសភាពនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការកំពូល មានអគ្គលេខាធិការ ០១ (មួយ) រូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិច ០៧ (ប្រាំពីរ) ឆ្នាំ ដែលអគ្គលេខាធិការត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ ចំណែកឯអគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ តែងតាំងដោយអនុក្រឹត្យ ហើយមន្ត្រីថ្នាក់ក្រោមដទៃទៀតតែងតាំងដោយប្រកាស។ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ និងតុលាការកំពូលអាចត្រូវបានបែងចែកជានាយកដ្ឋាន តាមចំនួនការងារចាំបាច់ជាក់ស្តែង។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធានការិយាល័យ និងអនុប្រធានការិយាល័យ ត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិច ០៣ (បី) ឆ្នាំ។

## ផ្នែកទី២៖ អង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថានប័នមួយរបស់រដ្ឋសម្រាប់ដំណើរការបណ្តឹងសាធារណៈ ឬបណ្តឹងព្រហ្មទណ្ឌ។ ហើយក្នុងរឿងក្តីព្រហ្មទណ្ឌនេះ បើយោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថាមានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[32] ហើយមានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្តី។[33] អង្គការអយ្យការ គឺជាស្ថាប័នមួយដែលមានតួនាទីដាច់ដោយឡែកពីតុលាការ[34] ថ្វីត្បិតតែស្ថាប័ននេះនៅក្នុងបរិវេណតុលាការក៏ពិតមែន តែស្ថាប័នអយ្យការនេះ មានអ្នកដឹកនាំដាច់ដោយឡែកផ្សេងពីតុលាការ។ ក៏ប៉ុន្តែមន្ត្រីជាន់ខ្ពស់ដែលតំណាង និងបម្រើការងារនៅក្នុងស្ថាប័នទាំងពីរនេះ សុទ្ធសឹងតែជាអ្នកចេញពីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សាលាភូមិន្ទចៅក្រមដូចគ្នា គ្រាន់តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានបែងចែកឱ្យបំពេញមុខងារផ្សេងៗគ្នាតែប៉ុណ្ណោះ។[35] លើសពីនេះទៅទៀតរដ្ឋធម្មនុញ្ញ នៃសាធារណៈរដ្ឋខ្មែរត្រង់មាត្រា ៨៣ ច្បាប់ស្តីពីការរៀប និងការប្រព្រឹត្តទៅនៃសាលាជម្រះក្តីរដ្ឋកម្ពុជា ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ ក៏ធ្លាប់កំណត់រចនាសម្ព័ន្ធរបស់អង្គការអយ្យការបច្ចុប្បន្នផងដែរ។[36]

ចៅក្រមអយ្យការ គឺសំដៅទៅដល់អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។[37]

❖ គោលបំណង និងអត្ថប្រយោជន៍ នៃអង្គការអយ្យការ

ការបង្កើតស្ថាប័នអយ្យការ គោលបំណងគឺចង់ឱ្យប្រទេសកម្ពុជាមានដំណើរការ ស្ថេរភាព សណ្តាប់ធ្នាប់សន្តិសុខសង្គម ឱ្យប្រជាពលរដ្ឋទទួលបានយុត្តិធម៌ដ៏ត្រឹមត្រូវ និងមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយគោរពតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្សតាមរយៈសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។[38] ស្ថាប័ន ឬអង្គការអយ្យការអមសាលាជម្រះក្តីនៅកម្ពុជាទាំង ០៣

---

[32] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា ១៣១ថ្មី (មាត្រា ១១២ចាស់)

[33] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា ១២៩ថ្មី(មាត្រា ១១០ចាស់) វាក្យខណ្ឌទី ១

[34] អង្គការសហប្រជាជាតិប្រចាំកម្ពុជា, *លិខិតុបករណ៍អន្តរជាតិស្តីពីចៅក្រម ព្រះរាជអាជ្ញា និងមេធាវី៖ គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា* (ភ្នំពេញ៖ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិនៅកម្ពុជា, ២០០៧), ២៤ ចំណុចទី ១០

[35] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, លេខ នស/រកម/០៧១៤/០១៧, ១៦ កក្កដា ២០១៤, មាត្រា ១៨

[36] កុយនាម និងឡុង បញ្ញាវុធ, *អយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀប*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ សមាគមច្បាប់ខ្មែរ, ២០០៦), ទំព័រ៧២។

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៨

[38] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា ៣១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១

(បី) ថ្នាក់ រួមមានសាលាដំបូងរាជធានី~ខេត្ត តុលាការយោធា សាលាឧទ្ធរណ៍ តុលាការកំពូល។ អង្គការអយ្យការនេះមានភារកិច្ច ស្វែងរកជនល្មើស ប្រមូលភស្តុតាង ចោទប្រកាន់ជនល្មើស បញ្ជូនជនល្មើសទៅតុលាការកាត់ទោស និងតាមដានការអនុវត្តសាលក្រមរបស់តុលាការ។ នៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង មានតែអង្គការអយ្យការតែមួយគត់ដែលបំពេញតួនាទីដោយព្រះរាជអាជ្ញា ជាអ្នកធ្វើបណ្តឹងអាជ្ញា តំណាងឱ្យផលប្រយោជន៍សង្គមជាតិទាំងមូល។ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់លើគ្រប់បទល្មើស ដែលបញ្ជូនមកឱ្យខ្លួនតាមរយៈ ពាក្យបណ្តឹងទោលរបស់ជនរងគ្រោះ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌។ ពិសេសជាងនេះទៅទៀតនោះអង្គការអយ្យការគឺ អង្គការឯករាជ្យ ទោះបីស្ថិតនៅអមសាលាជម្រះក្តីក៏ដោយ ក៏មិនស្ថិតក្រោមអំណាចឬចំណុះសាលាជម្រះក្តីដែលអមនោះទេ។ ហើយព្រះរាជអាជ្ញាក្នុងការបំពេញភារកិច្ចរបស់ខ្លួន ត្រូវឈរលើគោលការណ៍សំខាន់ៗ ដូចជា គោលការណ៍អវិភាគ គឺសំដៅដល់ការបំពេញមុខងាររបស់សមាជិកម្នាក់ៗ នៃអង្គការអយ្យការដើម្បីផលប្រយោជន៍សមូហភាព ពោលគឺនៅមុខតុលាការ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងតែងតែប្រើពាក្យ តំណាងអយ្យការ ព្រោះគាត់មិនធ្វើការក្នុងនាមខ្លួនឯងផ្ទាល់ទេ តែក្នុងនាមអង្គភាពរបស់ខ្លួន។ គោលការណ៍ឯកភាព សំដៅដល់ការបំពេញការងារក្រោមការគ្រប់គ្រង និងដឹកនាំតែមួយ។ ចុងក្រោយគឺគោលការណ៍ឯករាជ្យភាព មានន័យថាព្រះរាជអាជ្ញានៅអមតុលាការណាមួយ មិននៅក្រោមអំណាចតុលាការនោះទេ។ តុលាការគ្មានអំណាចអ្វីមកត្រួតពិនិត្យកិច្ចការរបស់អយ្យការនោះទេ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការមិនអាចសរសេរិះគន់ ឬបន្ទោសថាព្រះរាជអាជ្ញាធ្វើនេះមិនត្រូវ ឬដូច្នេះមិនល្អយ៉ាងណានោះទេ។ តុលាការមិនអាចបង្គាប់បញ្ជាថាឱ្យព្រះរាជអាជ្ញាត្រូវចោទបទល្មើសនេះ ឬចង្អុលថាជននោះត្រូវតែចោទប្រកាន់តាមដែលខ្លួនយល់ឃើញនោះទេ។[39] ត្រូវអនុវត្តមុខងាររបស់ខ្លួនដោយមិនលម្អៀង ការពារផលប្រយោជន៍សាធារណៈ រក្សាការសម្ងាត់នៃរឿងក្តី ពិនិត្យមើលទិដ្ឋភាព និងក្តីបារម្ភរបស់ជនរងគ្រោះនៅពេលដែលមានការប៉ះពាល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ គោលបំណងដែលសំខាន់នោះគឺ ប្រើប្រាស់នូវវិធានការផ្សេងៗដែលមានលក្ខណៈកែលម្អផង និងបង្ក្រាបរាល់បទល្មើសដែលកើតឡើងបង្កឱ្យមានផលប៉ះពាល់ រំខានដល់ការអភិវឌ្ឍសង្គមជាតិទាំងមូល។

### កថាខណ្ឌទី១៖ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តី

ដូចដែលយើងដឹងហើយថា ប្រព័ន្ធតុលាការឯករាជ្យរបស់កម្ពុជាចាប់ផ្តើមលេចចេញជារូបរាងវិញក្រោយទទួលបានឯករាជ្យពីបារាំង ហើយវាជាកត្តាមួយដែលធ្វើឱ្យយើងអនុវត្តតាមច្បាប់ស៊ីវិល (Civil Law) ដែលមាន

[39] កុយនាម និងឡុង បញ្ញាវុធ, *អយ្យការ៖ ប្រវត្តិ និងការសិក្សាប្រៀបធៀប*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ សមាគមច្បាប់ខ្មែរ, ២០០៦), ទំព័រ៧៥។

ប្រព័ន្ធនៃការរកភស្តុតាងអាំងគីស៊ីទ័រ គឺតួនាទីក្នុងការរកភស្តុតាងដាក់បន្ទុកក្នុងរឿងក្តីនីមួយៗជាសមត្ថកិច្ចរបស់រដ្ឋ ទើបបង្កើតឱ្យមានអង្គការអយ្យការអមសាលាជម្រះក្តី។

**ក. មហាអយ្យការអមតុលាការកំពូល**

នៅក្នុងសម័យប្រទេសកម្ពុជាឆ្នាំ១៩៤៧~១៩៧០ គ្មានឡើយអង្គការអយ្យការ លុះមកដល់សម័យសាធារណៈរដ្ឋ ក្រោមការគ្រប់គ្រងរបស់សេនាប្រមុខ លន់ នល់ ក្នុងរដ្ឋធម្មនុញ្ញមានចែងអំពីចៅក្រមជម្រះក្តី និងចៅក្រមអយ្យការ ហើយបានបញ្ជាក់ទៀតផងថាចៅក្រមទាំង២ប្រភេទនេះ មានលក្ខន្តិកៈដោយឡែកពីគ្នា។ រហូតមកដល់សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ទើបតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពី ការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូលដែលត្រូវបានប្រកាសឱ្យប្រើតាមក្រឹត្យលេខ២៨ក្រចុះថ្ងៃទី៣១ខែកក្កដាឆ្នាំ១៩៨៥។ បន្តមកឆ្នាំ១៩៨៧មានច្បាប់មួយទៀតពាក់ព័ន្ធនឹងតុលាការកំពូលនេះគឺក្រឹត្យ-ច្បាប់លេខ ៣៤ក្រ.ចស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល។ ហើយបច្ចុប្បន្នតុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ដូចនេះមហាអយ្យការអមសាលាជម្រះក្តីនេះក៏មានតែមួយដែរ។ បច្ចុប្បន្នអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលនេះគឺ លោកជំទាវ ជា លាង។[40]

**ខ. មហាអយ្យការអមសាលាឧទ្ធរណ៍តំបន់**

បើទោះបីជាក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា មានតុលាការប្រជាជនកំពូលក៏ពិតមែន ប៉ុន្តែគ្មានឯកសារណាមួយអាចបញ្ជាក់បានថាមានសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍នោះទេ។ កន្លងមកដល់ សម័យរដ្ឋកម្ពុជា ទើបមានក្រឹត្យលេខ០៦ រក្រ ចុះថ្ងៃទី០៦ កុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីរដ្ឋកម្ពុជា ដែលបញ្ជាក់ថា នៅអមសាលាជម្រះក្តីជាន់ខ្ពស់មានមហាអយ្យការមួយនៅអម។[41] ក្រោយព្រះរាជក្រឹត្យចំនួនបីដែលបានឡាយព្រះហស្តលេខាដោយព្រះករុណាព្រះបាទព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការប្រកាសឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ចំនួន ០៣ (បី) បន្ថែមទៀត ដែលនាំឱ្យអង្គការអយ្យការអមសាលាឧទ្ធរណ៍តំបន់ក៏បានបង្កើតចំនួន ០៣ (បី) បន្ថែមទៀតផងដែរ។ អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញគឺ ឯកឧត្តម អ៊ុក សាវុធ។[42] អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលា

[40] ព្រះរាជក្រឹត្យស្តីពីការតែងតាំង, លេខ នស/រកត/០៦០៩/៦៧៤, មាត្រា ១ ចំណុចទី ១

[41] ច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, ក្រឹត្យលេខ ០៦ រក្រ, ០៦ កុម្ភៈ ១៩៩៣, មាត្រា ៥

[42] ព្រះរាជក្រឹត្យស្តីពីការតែងតាំង, លេខ នស/រកត/០៦០៩/៦៧៤, មាត្រា ១ ចំណុចទី ២

ឧទ្ធរណ៍តំបន់ត្បូងឃ្មុំ គឺ ឯកឧត្តម ហួត វុទ្ធី។[43] អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ គឺ ឯកឧត្តម សរ យសថាវរៈ។[44] អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង គឺ ឯកឧត្តម នួន សាន។[45]

**គ. អយ្យការអមសាលាដំបូងរាជធានី~ខេត្ត**

បើយោងតាមក្រឹត្យក្រឹត្យលេខ០៦ រក្រ ចុះថ្ងៃទី ០៦ កុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីរដ្ឋកម្ពុជា អយ្យការអមសាលាដំបូងរាជធានី~ខេត្តចាប់ផ្តើមមានរូបរាងមួយច្បាស់លាស់ និងមានចែងអំពីសកម្មភាព ភារកិច្ច និងដំណើរការប្រព្រឹត្តទៅនៃអយ្យការថ្នាក់ទាបមួយនេះ។[46]

**កថាខណ្ឌទី២៖ សមត្ថកិច្ចនៃស្ថាប័នអយ្យការ**

ដើម្បីធានាឱ្យបាននូវយុត្តិធម៌ លុបបំបាត់ចោលនូវទិដ្ឋភាពនិទណ្ឌភាព ភាពអសកម្ម និងដំណើរការប្រព្រឹត្តទៅនៃអង្គការអយ្យការមានភាពរលូន គោលការណ៍សំខាន់ៗមួយចំនួនត្រូវបានបង្កើតឡើងសម្រាប់អង្គការអយ្យការដោយគោលការណ៍ទាំងនោះមានដូចជា៖

- គោលការណ៍ឯកភាព
- គោលការណ៍អវិភាគ
- គោលការណ៍នៃការទទួលខុសត្រូវ និង
- គោលការណ៍មិនអាចបណ្តឹងជិតចិត្ត

អង្គការអយ្យការ មានមុខងារ ធ្វើបណ្តឹងអាជ្ញា និងសុំអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ សមត្ថកិច្ចនៃស្ថាប័នគឺអនុវត្តដោយមនុស្សដែលជាតំណាង ឬបុគ្គលិក។ ដោយសារតែព្រះរាជអាជ្ញា គឺជាអ្នកដែលតំណាងឱ្យស្ថាប័នអយ្យការ ដូចនេះសមត្ថកិច្ចនៃអង្គការអយ្យការប្រៀបដូចជាសិទ្ធិ និងអំណាចដែលនឹង

[43] ព្រះរាជក្រឹត្យស្តីពីការតែងតាំងអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់, លេខ នស/រកត/០២២០/២១១, មាត្រា ១ ចំណុចទី ១

[44] ព្រះរាជក្រឹត្យស្តីពីការតែងតាំងអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់, លេខ នស/រកត/០២២០/២១១, មាត្រា ១ ចំណុចទី ២

[45] ព្រះរាជក្រឹត្យស្តីពីការតែងតាំងមុខតំណែង, លេខ នស/រកត/០៧២០/៧៦៨, មាត្រា ១

[46] ច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, ក្រឹត្យលេខ ០៦ រក្រ, ០៦ កុម្ភៈ ១៩៩៣, ជំពូកទី ២ មាត្រា ៦ ដល់មាត្រា ៨

ត្រូវប្រគល់ឱ្យព្រះរាជអាជ្ញាដូចគ្នា។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូង ដែលខ្លួនបំពេញការងារ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។[47]

មុខងាររបស់អយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឱ្យអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៅអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[48]

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឱ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវចូលរួមអនុវត្តមុខងារនេះក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានសិទ្ធិចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ។[49]

ដូចបានរៀបពីសមាសភាពនៃអង្គអយ្យការខាងលើរួចមកហើយថា ក្រៅពីចៅក្រមអយ្យការ ស្ថាប័នអយ្យការអាចដំណើរការទៅបានត្រូវការ ការចូលរួមពីសំណាក់មន្ត្រីរដ្ឋបាល និងក្រឡាបញ្ជីដែលធ្វើការទំនាក់ទំនងរវាងអង្គការតុលាការ និងអង្គការអយ្យការ។

**គ. មន្ត្រីរដ្ឋបាល**

យើងមើលឃើញថា ទោះបីគ្មានច្បាប់ណាបានចែង ឬកំណត់ពីមន្ត្រីរដ្ឋបាលនៃអង្គការអយ្យការក៏ដោយ តែបើយោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការមាត្រា ៣២ មាត្រា ៥២ និងមាត្រា ៧១ បានកំណត់ពីតួនាទី និងភារកិច្ចរបស់មន្ត្រីរដ្ឋបាលដែលបម្រើការជូន និងទំនាក់ទំនងជាមួយព្រះរាជអាជ្ញាដូចជា៖

- ចាត់ចែងការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ និងរបាយការណ៍ជាប្រចាំជូន អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញា
- រៀបចំ គ្រប់គ្រងការងាររដ្ឋបាល សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់អយ្យការ និងមហាអយ្យការដែលនៅអម
- រៀបចំគម្រោងថវិកាជូន អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងសម្រេច រួចអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត

[47] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៣០ និងមាត្រា ៣១

[48] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥១

[49] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៦៩ និងមាត្រា ៧០

- បញ្ជូនសាលក្រម និងសាលដី របស់សាលាជម្រះក្ដីរៀងខ្លួន និងរបាយការណ៍ការងារបុគ្គលិក និងហរិញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌។

**ខ. ក្រឡាបញ្ជី**

ក្រឡាបញ្ជី សំដៅលើឋានន្តរស័ក្តិរបស់មន្ត្រីជាន់កណ្ដាលខាងតុលាការ ជាស្មៀនសម្រាប់កាន់កាប់បញ្ជី និងសំណុំរឿងផ្សេងៗជាដើម។ ដោយយោងតាម វចនានុក្រម សម្ដេចព្រះមហាសុមេធាធិបតិ ជួនណាត តាមន័យច្បាប់ក្រឡាបញ្ជី គឺជាលេខាធិការផ្ទាល់របស់ចៅក្រម និងព្រះរាជអាជ្ញា ក្នុងការជួយសម្រួលដល់ការងារបច្ចេកទេសផ្នែកនីតិវិធីរឿងក្ដី ដែលច្បាប់តម្រូវជាចាំបាច់ ត្រូវតែមាន។ ក្រឡាបញ្ជីនៃស្ថាប័នអយ្យការស្ថិតនៅក្រោមការបង្គាប់ និងដឹកនាំរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលខ្លួនស្ថិតនៅអមសម្រាប់កិច្ចការផ្នែកយុត្តាធិការ ហើយបំពេញតួនាទីផ្នែករដ្ឋបាល និងចំណាត់ការលើសំណុំរឿងដូចជា៖

- ការធ្វើកំណត់ហេតុ
- ការធ្វើសេចក្ដីព្រាងដីកា
- ការចុះលេខសំណុំរឿងឯកសារផ្សេងៗ ។ល។[50]

ក្រឡាបញ្ជី ជាមន្ត្រីរាជការក្របខណ្ឌក្រសួងយុត្តិធម៌ដែលមានតួនាទី ជាជំនួយការ របស់ព្រះរាជអាជ្ញា និងចៅក្រមនៅគ្រប់ដំណាក់កាល។ ក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់តួនាទីចម្បងដល់ក្រឡាបញ្ជីជាអ្នកធ្វើកំណត់ហេតុស្ដាប់ចម្លើយនៅដំណាក់កាលឯកសារ កំណត់ហេតុស្ដាប់ ឬសួរចម្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងជាអ្នកធ្វើកំណត់ហេតុសវនាការនៅដំណាក់កាលជំនុំជម្រះ។

❖ តួនាទីក្រឡាបញ្ជីនៅដំណាក់កាលចៅក្រមអយ្យការ តំណាងឱ្យស្ថាប័នអយ្យការ

ក្រឡាបញ្ជីក៏ត្រូវបានកំណត់ឱ្យមានឋានានុក្រមផងដែរគឺ នាយកក្រឡាបញ្ជីអង្គការតុលាការ និងអង្គការអយ្យការ គឺជានាយកឋានានុក្រមលើក្រឡាបញ្ជីទាំងឡាយ ដែលបម្រើការងារនៅសាលាជម្រះក្ដី និងអង្គការអយ្យការជាមួយគ្នា។[51] ក្រឡាបញ្ជីជាអ្នកធ្វើការកត់ត្រារាល់ព័ត៌មាន តាមរយៈការសួរ ឬស្ដាប់ចម្លើយរបស់ជនជាប់សង្ស័យ ឬជនល្មើស ឬដើមបណ្ដឹង ឬសាក្សី ក្នុងកំណត់ហេតុដែលមានការដឹកនាំ ធ្វើកំណត់ហេតុ ដោយព្រះរាជអាជ្ញា។ ទម្រង់កំណត់ហេតុសម្រាប់ទិដ្ឋភាពនៃការអនុវត្តគឺ មានការចុះហត្ថលេខារបស់ក្រឡាបញ្ជីអមតំណាងអយ្យការ។ ប៉ុន្តែក្នុងដំណាក់កាលនេះ មិនបាច់មានក្រឡាបញ្ជីក៏បានដែរ។ ក្រឡាបញ្ជីអង្គការអយ្យការជួយដល់ចៅក្រមអយ្យការ នៅគ្រប់ដំណាក់កាលនៃនីតិវិធីអយ្យការ តាមភារកិច្ចដែលមាន

[50] លោកសាស្ត្រាចារ្យជួន ប៊ុនធី, នីតិវិធីព្រហ្មទណ្ឌ អង្គការអយ្យការ

[51] មាត្រា ៩ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជីឆ្នាំ២០១៦

ចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី សម្រាប់នៅដំណាក់កាលអយ្យការនេះ ក្រឡាបញ្ជីមានភារកិច្ចសំខាន់រួមមានដូចតទៅ ៖

- ទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ឬពីសាធារណជន ឬពីជនអនាមិក
- សរសេរកំណត់ហេតុ តាមការសាកសួររបស់អយ្យការទៅលើជនសង្ស័យ ឬសាក្សី

ទទួលវត្ថុតាងយកមករក្សាទុក (ចុះបញ្ជីក្នុងសៀវភៅវត្ថុតាង)

- ព្រាងដីកាផ្សេងៗជូនព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង
- ត្រូវចុះទៅបំពេញបេសកកម្មការងារ ជាមួយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងទៅពិនិត្យកន្លែងកើតហេតុ ឆែកឆេរលំនៅឋាន និងប្រតិបត្តិការផ្សេងទៀតរបស់តំណាងអយ្យការ។ ក្នុងករណីសំណុំរឿងដែលមានជនសង្ស័យមកជាមួយ ក្នុងដំណាក់កាលនេះក្រឡាបញ្ជីត្រូវសរសេរចុះក្នុងសៀវភៅបណ្តឹងព្រហ្មទណ្ឌ តាមសេចក្តីពិស្តារនៃការចាប់ខ្លួន រួចសរសេរនៅក្របសំណុំរឿងនៅថ្ងៃទី ខែ ឆ្នាំ ឃាត់ខ្លួន។ ប៉ុន្តែនៅក្នុងករណីទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ និងធ្វើការពិនិត្យលើឯកសារទូទៅ។

# ជំពូកទី២

## តួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍

# ជំពូកទី២

# តួនាទី និងសិទ្ធិអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍

## ផ្នែកទី១៖ តួនាទីរបស់ចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍

### កថាខណ្ឌទី១៖ លក្ខណៈសម្បត្តិ

#### ក. ជំនាញវិជ្ជាជីវៈ

រាល់ការបំពេញមុខងារណាមួយនៅក្នុងស្ថាប័ន ជាដំបូងត្រូវតែឆ្លងកាត់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាមុនសិន តាមដំណាក់កាលនីមួយៗ។ ដើម្បីចង់ក្លាយខ្លួនទៅជាព្រះរាជអាជ្ញា បេក្ខជនត្រូវ គោរព និងបំពេញតាមគោលការណ៍ច្បាប់ដែលមានចែង ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ។ ព្រះរាជអាជ្ញា គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការ ជាអ្នកទទួលបន្ទុកស្វែងរក បទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះក្នុងនាមផលប្រយោជន៍សង្គម។ អង្គការអយ្យការក៏ធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។

#### ខ. ការជ្រើសរើស

ការជ្រើសរើស និងការបណ្តុះបណ្តាលព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយការបណ្តុះបណ្តាលចៅក្រម។ យោងតាមគោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា រដ្ឋត្រូវធានាថា បុគ្គលដែលត្រូវបានជ្រើសរើសឱ្យធ្វើជាព្រះរាជអាជ្ញាត្រូវតែ ជាបុគ្គលដែលមានសុចរិតភាព មានសមត្ថភាព មានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានគុណសម្បត្តិ។ ដើម្បីបានជាប់ជាជម្រើសក្លាយជាសិស្សព្រះរាជអាជ្ញា បេក្ខជនត្រូវតែបំពេញឱ្យបានតាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិខ្មែរពីកំណើត៖ បានជាមានការកំណត់ថាព្រះរាជអាជ្ញាត្រូវតែមានសញ្ជាតិខ្មែរពីកំណើត ព្រោះព្រះរាជអាជ្ញាជាអ្នកតំណាងឱ្យរដ្ឋ ការពារប្រយោជន៍ជូនប្រជាពលរដ្ឋ ដូចនេះនៅពេលព្រះរាជអាជ្ញាមានសញ្ជាតិតែមួយទៅនឹងអ្នកដែលគាត់ត្រូវតំណាងឱ្យ គាត់នឹងបានយល់កាន់តែច្បាស់ពីសុខទុក្ខ និងស្ថានភាពជាក់ស្តែងដែលកើតឡើងពីឆន្ទៈនៃមនុស្សជាតិរួមតែមួយ។
- មានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ (សែសិប) ឆ្នាំ យ៉ាងច្រើនចំពោះបេក្ខជនមន្ត្រីរាជការ។

- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ៖ បានជាមានតម្រូវការបរិញ្ញាបត្រច្បាប់ ព្រោះតួនាទីព្រះរាជអាជ្ញាជាតួអង្គមួយ ដែលដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តច្បាប់ ដូចនេះបរិញ្ញាបត្រច្បាប់ជាសក្ខីកម្មមួយបញ្ជាក់ គាត់មានចំណេះដឹងផ្នែកច្បាប់មួយកម្រិតហើយ។
- មិនដែលមានទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋ៖ ដោយហេតុថាព្រះរាជអាជ្ញាមានតួនាទីក្នុងការកំណត់ពីទោស ឬចោទប្រកាន់ជនដែលបានប្រព្រឹត្តល្មើសនឹងបញ្ញត្តិច្បាប់ពីបទល្មើសអ្វីមួយ ដូចនេះគាត់ត្រូវតែជាគំរូដែលមានភាពស្អាតស្អំ សម្រាប់ចង្អុលបង្ហាញដល់ប្រជាពលរដ្ឋឱ្យគោរពច្បាប់ឱ្យបានខ្ជាប់ខ្ជួន។
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន៖ ដោយសារតែតួនាទីរបស់ព្រះរាជអាជ្ញាភ្ជាប់មកជាមួយមុខងារ ស្វែងរកភស្តុតាង បង្ក្រាប ទប់ស្កាត់បទល្មើសកុំឱ្យរីករាលដាលក្នុងសង្គម ដូចនេះគាត់ត្រូវមានសុខភាព និងសម្បទាមាំមួនដែលជាកត្តាចម្បងដើម្បីឱ្យការអនុវត្តការងារប្រព្រឹត្តទៅកាន់តែរលូន។[52]

**គ. ការបណ្តុះបណ្តាល**

ព្រះរាជអាជ្ញា និងចៅក្រម គឺត្រូវឆ្លងកាត់ការបណ្តុះបណ្តាលបឋមដូចគ្នាខាងវិជ្ជាជីវៈនៅសាលាភូមិន្ទចៅក្រម ដែលមានរយៈពេល ០២ (ពីរ) ឆ្នាំ ដែលរយៈពេល ០១ (មួយ) ឆ្នាំ ទទួលបានការបណ្តុះបណ្តាលផ្នែកទ្រឹស្តីនៃវិជ្ជាជីវៈចៅក្រម និងព្រះរាជអាជ្ញា និងព្រមទាំងឆ្លងកាត់កម្មសិក្សាដែលត្រូវបានកំណត់ រយៈពេល ០១ (មួយ) ឆ្នាំ ទៀតសម្រាប់ការអនុវត្តជាក់ស្តែងនៅតាមអង្គការអយ្យការនានាក្នុងដែនដីព្រះរាជាណាចក្រកម្ពុជា។

**ឃ. ការតាំងស៊ប់ក្នុងក្របខណ្ឌ**

ព្រះរាជអាជ្ញាកម្មសិក្សាដែលបានបំពេញកម្មសិក្សាចប់ដោយជោគជ័យត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**កថាខណ្ឌទី២៖ ថ្នាក់ និងឋានន្តរស័ក្តិ**

**ក. ការតែងតាំង**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយ ព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្អាកពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះ ព្រះរាជាអាជ្ញាទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើរខាងលើ។ ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាង ព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ អំពីកិច្ចការខាងលើនេះ។

[52] ច្បាប់ស្តីពីលក្ខន្តិកនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៨២

នៅពេលដែលទទួលការបានការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ សិស្សព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្តុះបណ្តាលប្រកបដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះរាជអាជ្ញាកម្មសិក្សា ក្នុងឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ បន្ទាប់ពីបំពេញកម្មសិក្សាចប់សព្វគ្រប់ហើយ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូង។ ក្របខណ្ឌព្រះរាជអាជ្ញារួមមាន ០៣ (បី) ឋានន្តរស័ក្តិ៖

- ឧត្តមព្រះរាជអាជ្ញា
- វរៈព្រះរាជអាជ្ញា
- អនុព្រះរាជអាជ្ញា។[53]

ថ្នាក់សម្រាប់ឋានន្តរស័ក្តិទាំងបីខាងលើនៃ ចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានរៀបចំបែងចែកដូចខាងក្រោមតទៅទៀត៖

- ឋានន្តរស័ក្តិអនុចៅក្រម ឬអនុព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី៣ ដែលជាឋានន្តរស័ក្តិទាបបំផុតដែលមាន៤ (បួន) ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ ៤ (បួន) ដល់លេខ ១ (មួយ)។
- ឋានន្តរស័ក្តិវរៈចៅក្រម ឬវរៈព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី២ ដែលជាឋានន្តរស័ក្តិខ្ពស់បន្ទាប់ដែលមាន ៤ (បួន) ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ ៤ (បួន) ដល់លេខ ១ (មួយ)។
- ឋានន្តរស័ក្តិឧត្តមចៅក្រម ឬឧត្តមព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី១ ដែលជាឋានន្តរស័ក្តិខ្ពស់បំផុតដែលមាន ៦ (ប្រាំ មួយ) ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ ៦ (ប្រាំ មួយ) ដល់លេខ ១ (មួយ)។[54]

ច្បាប់បានកំណត់ថា អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវតែមានឋានន្តរស័ក្តជាឧត្តមព្រះរាជអាជ្ញាថ្នាក់ខ្ពស់បំផុត ពោលគឺឧត្តមព្រះរាជអាជ្ញាថ្នាក់លេខ១។ ចំណែក អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញាអមតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចមានឋានន្តរស័ក្តជាឧត្តមព្រះរាជអាជ្ញាពីថ្នាក់លេខ៦ ដល់លេខ២។ ចំពោះអគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចមានឋានន្តរស័ក្តជាឧត្តមព្រះរាជអាជ្ញា ឬវរៈព្រះរាជអាជ្ញា។ ដោយឡែកព្រះរាជអាជ្ញាអមសាលាដំបូង អាចមានឋានន្តរស័ក្តជាវរៈព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង អាចមានឋានន្តរស័ក្តជាវរៈព្រះរាជអាជ្ញា ឬអនុព្រះរាជអាជ្ញាឡើងទៅ។[55]

[53] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៧៨

[54] ព្រះរាជក្រឹត្យស្តីពីឋានន្តរស័ក្ត និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកត/០៥១៥/៣៩៨, ០៨ ឧសភា ២០១៥, មាត្រា ៨

[55] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៩៥

ដូចនេះការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមអតីតភាព ស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ។ លក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិតាមវេនជ្រើសរើស និងតាមអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

មូលហេតុក្នុងការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញាត្រូវផ្អែកគោលការណ៍មួយចំនួនដូចខាងក្រោមនេះ ៖

- ការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចល្អ
- កិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើឱ្យប៉ះពាល់ទៅដល់កិត្តិយសនៃអង្គចៅក្រម
- ការឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។

បានន័យនៅក្នុងពេលបំពេញការងារ ព្រះរាជអាជ្ញាដែលបានខិតខំបំពេញការងារបានល្អ សីលធម៌ល្អ ឬទទួលបានសញ្ញាបត្រក្រោយឧត្តមសិក្សានោះ នឹងត្រូវទទួលការលើកទឹកចិត្តដោយធ្វើការដំឡើងថ្នាក់ថែម ១ (មួយ) ថ្នាក់។ បើក្នុងករណីចាំបាច់នោះ ព្រះរាជអាជ្ញាអាចធ្វើការដំឡើងថ្នាក់បានដោយធ្វើការប្រលង។ ការវាយតម្លៃលើសីលធម៌ កិរិយាមាយាទ សមត្ថភាព និងទិដ្ឋភាពនៃការងារធ្វើឡើងជារៀងរាល់ឆ្នាំតាមរយៈព្រឹត្តិបត្រឯកត្តជន និងមានការដាក់ពិន្ទុដូចមានចែងក្នុងច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៨៧។

**ខ. ការផ្លាស់ប្តូរ**

ការផ្លាស់ប្តូរ ផ្ទេរភារកិច្ចរបស់ព្រះរាជអាជ្ញា គឺជារឿងធម្មតានៅក្នុងអាជីពរបស់ព្រះរាជអាជ្ញាស្របតាមការដឹកនាំរបស់រាជរដ្ឋាភិបាល ដើម្បីធានាភារកិច្ចដំណើរការ ការងារឱ្យកាន់ល្អប្រសើរ និងមានប្រសិទ្ធិភាពខ្ពស់សំដៅដល់ការលើកកម្ពស់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ ពិសេសដើម្បីធានាឱ្យមានការកាត់ក្តី ដោយឥតលម្អៀង ដោយត្រឹមត្រូវ និងយុត្តិធម៌។ ជាការពិតណាស់ព្រះរាជអាជ្ញាក្នុងមួយអាណត្តិ ០៤ (បួន) ឆ្នាំម្តង ត្រូវមានការផ្លាស់ប្តូរស្ថាប័នអយ្យការដែលគាត់នៅអម ដោយគោរពទៅតាមច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងទិសដៅកុំឱ្យព្រះរាជអាជ្ញាមានទំនាក់ទំនងមនោសញ្ចេតនា ចាក់ឬស ចាក់គល់នៅក្នុងតំបន់នីមួយៗ ដែលខ្លួនបំពេញការងារ និងដើម្បីកុំឱ្យប្រព្រឹត្តអំពើពុករលួយ ដូចនេះទើបមានការផ្លាស់ប្តូរពីតំបន់មួយ ទៅតំបន់មួយ ឬពីខេត្តមួយ ទៅខេត្តមួយទៀត។

**គ. ការផ្តាច់ពីមុខងារ**

ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឱ្យផ្តាច់ពីមុខងារព្រះរាជអាជ្ញាបានតាមការស្នើសុំរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន។

ក្នុងករណីចាំបាច់ ដែលត្រូវទៅបំពេញការងារជាបណ្ដោះអាសន្ននៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម ព្រះរាជអាជ្ញាអាចសុំផ្ដាច់ពីមុខងារ។

ក្នុងរយៈពេលនៃការអនុញ្ញាតឱ្យផ្ដាច់ពីមុខងារព្រះរាជអាជ្ញានោះ ត្រូវបានបន្តទទួលបានប្រាក់បៀវត្ស ព្រមទាំងសិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែពុំមានប្រាក់បំណាច់មុខងារ និងប្រាក់រង្វាន់ផ្សេងទៀតនៃមុខងារដើមរបស់ខ្លួនទេ។

**ឃ. ការដាក់ឱ្យនៅក្រៅក្របខណ្ឌ**

ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឱ្យ ដាក់ឱ្យនៅក្រៅក្របខណ្ឌព្រះរាជអាជ្ញាបាន តាមការស្នើសុំរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន។

ករណីចាំបាច់ដែលត្រូវ បំពេញការងារជាបណ្ដោះអាសន្ននៅក្នុងសហគ្រាសសាធារណៈ ឬនៅតាមអង្គការអន្តរជាតិ ព្រះរាជអាជ្ញា អាចសុំនៅក្រៅក្របខណ្ឌ។

ព្រះរាជអាជ្ញាដែលបានដាក់ឱ្យនៅក្រៅក្របខណ្ឌ ពុំមានសិទ្ធិទទួលប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងារដើមរបស់ខ្លួន។

**ង. ការដាក់ឱ្យនៅទំនេរ និងលុបចោល**

ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេច និងលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រអំពីការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ព្រះរាជអាជ្ញា អាចត្រូវបានផ្អាកពីមុខងារបណ្ដោះអាសន្ន ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងករណីដែលព្រះរាជអាជ្ញានោះ កំពុងជាប់នីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម។

ព្រះរាជអាជ្ញា អាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ក្នុងករណីព្រះរាជអាជ្ញានោះទទួលទណ្ឌកម្មវិន័យថ្នាក់ទី ២ (ពីរ) ឬនៅពេលដែលព្រះរាជអាជ្ញានោះបានបោះបង់ការងារឬអវត្តមានលើសពី ៣០ (សាមសិប) ថ្ងៃ ដោយអនុវត្តតាមមាត្រា ៥២ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឬដោយសាមីខ្លួនសុំលាឈប់ជាស្ថាពរ។[56]

ក្នុងករណីចាំបាច់ មានមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាអាចស្នើសុំនៅទំនេរ គ្មានប្រាក់បៀវត្សសម្រាប់រយៈពេលកំណត់ណាមួយ តាមពាក្យស្នើសុំរបស់សាមីខ្លួន។

លក្ខខណ្ឌដែលអនុញ្ញាតឱ្យនៅទំនេរគ្មានប្រាក់បៀវត្ស តាមការស្នើសុំរបស់សាមីខ្លួនបាន លុះត្រាតែព្រះរាជអាជ្ញានោះ បានបំពេញមុខងារក្នុងក្របខណ្ឌយ៉ាងតិច ០៤ (បួន) ឆ្នាំ សិនដោយមិនគិតពីព្រះរាជអាជ្ញា

[56] ច្បាប់ស្ដីពីលក្ខន្តិកនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៩០

ដែលត្រូវទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី ២ (ពីរ)។ ការអនុញ្ញាតឱ្យនៅទំនេរគ្មានប្រាក់បៀវត្ស អាចធ្វើឡើងតាមរយៈពេលម្តង ០១ (មួយ) ឆ្នាំ ឬម្តង ០២ (ពីរ) ឆ្នាំ។ ការអនុញ្ញាតឱ្យនៅទំនេរនេះ អាចធ្វើបានតែពីរដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះមិនត្រូវឱ្យលើសពី ០៤ (បួន) ឆ្នាំឡើយ។ ពាក្យសុំដាក់ឱ្យនៅទំនេរត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន។ ពាក្យនេះត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ចែងតាមនីតិវិធី។[57]

ការលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ដោយអនុលោមតាមបញ្ញត្តិច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬទបញ្ញានៃបេឡាសោធននិវត្តន៍។[58]

ទណ្ឌកម្មខាងវិន័យត្រូវបានបែងចែកជាពីរថ្នាក់ ៖

❖ ថ្នាក់ទី ១ (មួយ)៖

- ការស្តីបន្ទោសផ្ទាល់មាត់
- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈពេលតែមិនត្រូវឱ្យលើសពី ០២ (ពីរ) ឆ្នាំ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលព្រះរាជអាជ្ញារូបនោះមានឈ្មោះនៅក្នុងតារាងរួចមកហើយ។

❖ ថ្នាក់ទី ២ (ពីរ)៖

- ការផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម
- ការព្យួរពីការងារមិនឱ្យមានប្រាក់បៀវត្ស ក្នុងរយៈពេលមិនលើសពី ០១ (មួយ) ឆ្នាំ
- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ
- ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ
- ការបញ្ឈប់ពីមុខងារដោយបង្ខំ
- ការបណ្តេញចេញពីក្របខណ្ឌ។

ដើម្បីធ្វើទណ្ឌកម្មថ្នាក់ទី ២ (ពីរ) នេះ ត្រូវធ្វើដោយព្រះរាជក្រឹត្យដោយការសម្រេចរួចមកហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

[57] ច្បាប់ស្តីពីលក្ខន្តិកនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៩១

[58] ច្បាប់ស្តីពីលក្ខន្តិកនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៩៤

## ផ្នែកទី២៖ សិទ្ធិ និងអំណាចចៅក្រមអយ្យការនៃមហាអយ្យការអមសាលាឧទ្ធរណ៍

### កថាខណ្ឌទី១៖ ចំពោះកិច្ចការផ្ទៃក្នុង

#### ក. ស្ថាប័នសាមី

ទំនាក់ទំនងជាមួយព្រះរាជអាជ្ញាទាំងអស់ក្នុងមហាអយ្យការអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅក្នុងការងារផ្សេងៗ នៃមហាអយ្យការ និងអង្គជំនុំជម្រះ។[59] អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់ក្នុងដែនដីនៃសាលាឧទ្ធរណ៍ ធ្វើអធិការកិច្ចទៅអង្គការអយ្យការទាំងឡាយដែលឋិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍។[60] ឧទាហរណ៍ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំត្រូវឃ្លាំមើលការអនុវត្តច្បាប់ និងអាចធ្វើអធិការកិច្ចទៅអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ឬក្រចេះបាន ព្រោះសាលាដំបូងខេត្តទាំងពីរឋិតនៅក្រោមដែនដីសមត្ថកិច្ចរបស់មហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ។ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីពិនិត្យមុនពេលសវនាការ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចាត់តាំង អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តងជាតំណាងមហាអយ្យការនៅក្នុងសវនាការ។

#### ខ. មន្ត្រីរដ្ឋបាល

ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍អាចទំនាក់ទំនងមន្ត្រី នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍សម្រាប់ជំនួយផ្នែកបច្ចេកទេសដល់កម្មវិធីការងាររបស់ខ្លួន អនុវត្តគម្រោងថវិកាតាមដែលខាងអគ្គលេខាធិការដ្ឋានរដ្ឋបាលបានរៀបចំជូន ត្រួតពិនិត្យពីរបាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុដែលបានផ្ញើជូនដោយអគ្គលេខាធិការដ្ឋានរដ្ឋបាល និងចាត់ចែងការងារចាំបាច់ផ្សេងៗមួយចំនួនដល់មន្ត្រីរដ្ឋបាល នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍។[61]

---

[59] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥១

[60] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៤

[61] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ រកម/ ០៧១៤/ ០១៥, ១៦ កក្កដា ២០១៤, មាត្រា ៥២

### គ. បណ្ដឹងទាស់ចំពោះសាលដីកាចេញដោយកំបាំងមុខ

សាលដីកាកំបាំងមុខ គឺជាសាលដីកាសម្រេចសេចក្ដីមួយ នៅពេលសវនាការ ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលនោះទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនខ្លួនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ។ សាលដីកា ត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ ប៉ុន្តែសាលដីកាកំបាំងមុខនេះ ត្រូវឱ្យដំណឹងដល់សាមីជនទាំងនោះ ហើយសាលដីកានេះអាចប្ដឹងទាស់បាន។

❖ បុគ្គលដែលអាចបណ្ដឹងទាស់៖

ក្នុងរឿងក្ដីមានតែពិរុទ្ធជនទេ អាចប្ដឹងទាស់ចំពោះសាលដីកាដែលសម្រេចដោយកំបាំងមុខខ្លួន។[62] ប៉ុន្តែត្រូវធ្វើតាមតំណាងមេធាវី ឬតំណាងឪពុក ម្ដាយ និងអាណាព្យាបាលសម្រាប់ពិរុទ្ធជនដែលជាអនីតិជន។[63]

❖ ទម្រង់នៃបណ្ដឹងទាស់៖

បណ្ដឹងទាស់នេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលសម្រេចចេញសាលដីកា ឬនៅចំពោះមុខអគ្គព្រះរាជអាជ្ញា និងមន្ត្រីមានសមត្ថកិច្ច។[64] ក្រោយពីទទួលបានពាក្យប្ដឹងទាស់ហើយអគ្គព្រះរាជអាជ្ញា និងមន្ត្រីមានសមត្ថកិច្ច បញ្ជូនសំណុំរឿងនោះភ្លាមទៅសាលាឧទ្ធរណ៍ ដែលបានប្រកាសចេញសាលដីកា។ [65]

❖ រយៈពេលនៃបណ្ដឹងទាស់៖

បណ្ដឹងត្រូវប្ដឹងទាស់បានក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីពេលសាលដីកំបាំងមុខត្រូវបានឱ្យដំណឹង និងប្រគល់ដល់ដៃពិរុទ្ធផ្ទាល់ ឬពេលដែលពិរុទ្ធបានដឹងដំណឹងអំពីសាលដីកំបាំងមុខនេះ ទោះសាលដីកាពុំបានប្រគល់ឱ្យដល់ដៃពិរុទ្ធជនផ្ទាល់ក៏ដោយ។[66]

❖ អានុភាពនៃបណ្ដឹងទាស់៖

កាលណាមានបណ្ដឹងទាស់ទៅនឹងសាលដីកាទាំងមូល សាលដីកានោះនឹងត្រូវចាត់ទុកជាអសារបង់ មិនថាទោសពិន័យជាប្រាក់ ឬទោសជាប់ពន្ធនាគារដែលត្រូវអនុវត្តទេ ត្រូវបានព្យួរ។ ហើយរឿងក្ដីនោះត្រូវលើកមកជំនុំជម្រះម្ដងទៀតនៅមុខសាលាឧទ្ធរណ៍ដដែល។[67]

---

[62] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤០៩

[63] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១០ កថាខណ្ឌទី២

[64] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១០ កថាខណ្ឌទី១

[65] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១០ កថាខណ្ឌទី៣

[66] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១២

[67] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១៤ និង មាត្រា៤១៥

បណ្តឹងទាស់ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅចំពោះមុខអគ្គព្រះរាជអាជ្ញា និងមានការបញ្ជូនទៅសាលាឧទ្ធរណ៍ដែលបានចេញសាលដីកាដោយអគ្គព្រះរាជអាជ្ញា ក្នុងគោលបំណងសម្រួលបន្ទុកដល់ពិរុទ្ធជនដោយសារការមិនបានបង្ហាញមុខក្នុងសវនាការ អាចមកពីកត្តាប្រធានសក្តិ។ ក្នុងករណីនេះអគ្គព្រះរាជអាជ្ញាជួយបញ្ជូនពាក្យប្តឹងទាស់ទៅសាលាឧទ្ធរណ៍ដែលបានចេញសាលដីកា ដើម្បីការពារប្រយោជន៍មនុស្សជាតិ និងសិទ្ធិមនុស្សជារួម។

## កថាខណ្ឌទី២ ចំពោះសេចក្តីសម្រេចរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង

### ក. បណ្តឹងឧទ្ធរណ៍

#### ១. បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម

ក្រោយសេចក្តីសម្រេចចុងក្រោយនៃសវនាការជំនុំជម្រះនៅសាលាដំបូងបានចេញមកហើយ ក្នុងនោះមានការអនុញ្ញាតបើកផ្លូវប្តឹងតវ៉ា ព្រោះថាចៅក្រមជំនុំជម្រះ ក៏ជាមនុស្សធម្មតាដូចយើងទាំងអស់គ្នាដែរ ក្នុងការធ្វើសេចក្តីសម្រេច វិនិច្ឆ័យ តែងតែជៀសមិនផុតពីការបង្កើតនូវកំហុស ដោយបច្ចេកទេសក្តី ដោយអចេតនាក្តី។ ប៉ុន្តែកំហុសនោះហើយ អាចបំពានដល់សិទ្ធិរបស់ភាគី ឬសណ្តាប់ធ្នាប់សង្គម និងអាចធ្វើឱ្យមានការបាត់បង់ទំនុកចិត្តជាសាធារណៈពីសំណាក់ប្រជាពលរដ្ឋ ចំពោះប្រព័ន្ធតុលាការ ឬប៉ះពាល់ដល់យុត្តិធម៌សង្គម។ ហេតុនេះតម្រូវឱ្យមានប្រព័ន្ធមួយ សម្រាប់ត្រួតពិនិត្យនូវសេចក្តីសម្រេចចុងក្រោយរបស់សាលាដំបូង គឺការប្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់មួយថ្នាក់ទៀតគឺ សាលាឧទ្ធរណ៍។ ក្នុងករណីដែលមានភាគី ពុំមានការមិនសុខចិត្ត និងការសម្រេចក្តីរបស់តុលាការថ្នាក់ដំបូង ឬតុលាការរាជធានី~ខេត្ត។ បណ្តឹងឧទ្ធរណ៍ ជាបណ្តឹងមិនយល់ស្របជាមួយសេចក្តីសម្រេចរបស់សាលាជម្រះក្តីជាន់ទាប ទៅសាលាជម្រះក្តីជាន់ខ្ពស់។ ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវយកទៅដាក់នៅតុលាការដែលចេញសាលក្រមនោះ ហើយតុលាការនឹងបញ្ជូនពាក្យបណ្តឹងទៅសាលាឧទ្ធរណ៍ជាបន្ទាន់។

❖ បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍ ឬប្តឹងឧទ្ធរណ៍បាន[68]៖

- ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូង
- អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអម សាលាឧទ្ធរណ៍
- ពិរុទ្ធជន[69]
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី[70]

[68] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧៥

[69] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧៦ កថាខណ្ឌទី២

[70] ក្រមនីតិវិធិព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧៦ កថាខណ្ឌទី៣

- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី[71]

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥ ទាក់ទងនឹងបុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បាន ចំពោះពិរុទ្ធយើងអាចចែកចេញជា ពិរុទ្ធជនដែលជានីតិជន និងពិរុទ្ធជនជាអនីតិជនហើយសិទ្ធិនៃការធ្វើបណ្តឹងក៏មានលក្ខណៈខុសគ្នាផងដែរ។ ដោយពិរុទ្ធជនជានីតិជន ដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើង អាចប្តឹងបានដោយខ្លួនឯង ឬពឹងអ្នកតំណាងឱ្យប្តឹងជំនួស ដែលអ្នកតំណាងស្របច្បាប់គឺមេធាវី ហើយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍។ ចំណែក ឯពិរុទ្ធជនជាអនីតិជន ដែលមានអាយុ ១៤ (ដប់បួន) ឆ្នាំ ឡើងដល់ ១៨ (ដប់ប្រាំបី) ឆ្នាំ អ្នកដែលអាចប្តឹងបានមាន ឪពុកម្តាយ អាណាព្យាបាល ដោយមិនចាំបាច់មានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍ទេ ឬមេធាវីដែលមានការផ្ទេរសិទ្ធិពីឪពុក ម្តាយ អាណាព្យាបាលឱ្យជួយធ្វើជំនួស។ ហើយចំពោះដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី អាចធ្វើការប្តឹងឧទ្ធរណ៍តាមរយៈតំណាងមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ធ្វើបណ្តឹងជំនួស ដោយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍។ សម្រាប់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី អាចឱ្យតំណាងមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ធ្វើបណ្តឹងនេះឡើយ ហើយត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍។ ចុងក្រោយ ចំពោះពិរុទ្ធជនដែលជាប់ឃុំអាចសម្តែងការមិនពេញចិត្តនឹង សេចក្តីសម្រេចដោយការធ្វើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[72]

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម គឺសាលាដំបូង។[73] ដោយឡែកបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយអគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ហើយអគ្គព្រះរាជអាជ្ញា ក៏ត្រូវចុះហត្ថលេខាលើលិខិតប្តឹងឧទ្ធរណ៍នោះផងដែរ។[74]

❖ រយៈពេលនៃបណ្តឹងឧទ្ធរណ៍៖

- ការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ ឯអគ្គព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល ០៣ (បី) ខែ ដែលគិតចាប់ពីពេលប្រកាសសាលក្រម។
- ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវធ្វើក្នុងរយៈពេល ១ (មួយ) ខែ។

---

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧៦ កថាខណ្ឌទី៤

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧៧

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧៦

[74] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៧៩

- ករណីសាលក្រមចំពោះមុខ រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍ ផ្តើមគិតពីពេលប្រកាសសាលក្រម
- ករណីសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍ ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឱ្យដំណឹងធ្វើតាមវិធីណាក៏ដោយ។[75]

❖ នីតិវិធីនៅចំពោះមុខសាលាឧទ្ធរណ៍

ការបញ្ជូនសំណុំរឿងទៅឧទ្ធរណ៍ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងរៀបចំសំណុំរឿងដើម្បី បញ្ជូនទៅសាលាឧទ្ធរណ៍។ ក្រឡាបញ្ជី ត្រូវផ្ញើរនៅក្នុងរយៈពេលដ៏ខ្លីបំផុតជូនទៅដល់ការិយាល័យក្រឡាបញ្ជី នៃសាលាឧទ្ធរណ៍នូវៈ

- សំណុំរឿងនៃនីតិវិធី
- សេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នីមួយៗ ដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម
- សេចក្តីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។ ការកំណត់កាលបរិច្ឆេទនៃសវនាការ និងរយៈពេលជំនុំជម្រះ នៅពេលសំណុំរឿងទៅដល់សាលាឧទ្ធរណ៍។

ប្រធានសភាព្រហ្មទណ្ឌផ្ទៀងផ្ទាត់មើលថា តើទម្រង់បែបបទនៃបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវឬទេ និងកំណត់កាលបរិច្ឆេទនៃសវនាការ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលសមស្រប។ ក្នុងករណីប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់តុលាការជាន់ដំបូង ស្តីពីការឃុំខ្លួនជនជាប់ចោទ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសំណុំរឿង។[76]

❖ អានុភាពបណ្តឹងនៃបណ្តឹងឧទ្ធរណ៍

- អានុភាពផ្ទេរនៃបណ្តឹងឧទ្ធរណ៍ សំណុំរឿងត្រូវបានផ្ទេរជូនសាលាឧទ្ធរណ៍នៅក្នុងដែនដែលកំណត់ដោយលិខិតប្តឹងឧទ្ធរណ៍ និងតាមឋានៈរបស់អ្នកប្តឹងឧទ្ធរណ៍។ បានន័យថាបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមសាលាដំបូង ត្រូវផ្ទេរជូនសាលាឧទ្ធរណ៍តំបន់ដែលមានសមត្ថកិច្ច។ ឧទាហរណ៍ សាលក្រមចេញដោយសាលាដំបូងខេត្តសៀមរាប ត្រូវបានគេធ្វើបណ្តឹងឧទ្ធរណ៍តវ៉ា ដូចនេះបណ្តឹងឧទ្ធរណ៍នេះត្រូវផ្ទេរមកសាលាឧទ្ធរណ៍តំបន់បាត់ដំបង។[77]
- អានុភាពនៃបណ្តឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម នៅក្នុងរយៈពេលប្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែជនជាប់ចោទដែលជាប់ឃុំ បានចូលបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារ នៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើ

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៨១ និងមាត្រា ៣៨២

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៨៦ ដល់មាត្រា ៣៩៦

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៩៧

សេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច។ ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចឱ្យរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឱ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ ត្រង់ចំនុចនេះបានន័យថា កន្លងមកបើជនជាប់ ធ្លាប់បានជាប់ឃុំខ្លួនបណ្តោះអាសន្ន ០៣ (បី) ខែ ហើយសាលក្រមរបស់សាលាដំបូងកំណត់ថាដាក់ពន្ធនាគារជននោះ ០៣ (បី) ខែ ក្នុងពេលប្តឹងឧទ្ធរណ៍ ព្រះរាជអាជ្ញាអាចធ្វើការដោះលែងជនជាប់ចោទបាន។ ប៉ុន្តែបើកន្លងមកជនជាប់ ធ្លាប់បានជាប់ឃុំខ្លួនបណ្តោះអាសន្ន ០៣ (បី) ខែ ហើយសាលក្រមរបស់សាលាដំបូងកំណត់ថាដាក់ពន្ធគារជននោះ ០១ (មួយ) ឆ្នាំ ជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់បណ្តឹងឧទ្ធរណ៍ចប់សព្វគ្រប់។ រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជាអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ។[78]

- អានុភាពបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញា ទណ្ឌកម្មអាចត្រូវបានតុលាការសម្រេចបន្ថែម ឬបន្ថយទណ្ឌកម្មនៃទោស។ ដោយឡែក អានុភាពបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយពិរុទ្ធជន ឬអ្នកតំណាងស្របច្បាប់តុលាការសម្រេចទណ្ឌកម្មនៅដដែល ឬបន្ថយ (មិនសម្រេចដំឡើងទណ្ឌកម្មឡើយ)។[79]

### ២. បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា

នៅដំណាក់កាលចៅក្រមស៊ើបសួរមានតែដីកាសម្រេច របស់ចៅក្រមស៊ើបសួរទេ ដែលអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បាន។ ចំពោះនីតិវិធីគ្មានការប្តឹងឧទ្ធរណ៍ មានតែប្តឹងសុំមោឃភាព។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។[80] ដីកាសម្រេចរបស់ចៅក្រមស៊ើបសួររួមមាន៖

- ដីកាបដិសេធពាក្យសុំឱ្យធ្វើកិច្ចស៊ើបសួរ
- ដីកាមិនព្រមប្រគល់វត្ថុដែលចាប់យកទៅឱ្យម្ចាស់ដើមវិញ
- ដីកាបដិសេធពាក្យឱ្យធ្វើកោសល្យវិច័យ
- ដីកាបដិសេធពាក្យឱ្យធ្វើកោសល្យវិច័យបន្ថែម ឬសុំធ្វើប្រតិកោសល្យវិច័យ

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៩៨
[79] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៣៩៩ និងមាត្រា ៤០០
[80] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៦៦

- ដីកាស្តីពីរឿងឃុំខ្លួនបណ្ដោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ ។
- ដីកាមិនព្រមស៊ើបសួរ
- ដីការកំណត់ចំនួនប្រាក់កក់
- ដីកាប្រកាសមិនទទួលពាក្យបណ្ដឹងដោយមានការតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី
- ដីកាផ្គួនទោសដើមបណ្ដឹងរដ្ឋប្បវេណី
- ដីកាបដិសេធពាក្យឱ្យធ្វើកោសល្យវិច័យបន្ថែម ឬសុំធ្វើប្រតិកោសល្យវិច័យ និង
- ដីកាដំណោះស្រាយ។[81]

សមត្ថកិច្ចក្នុងការដោះស្រាយបណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ គឺមានតែសភាស៊ើបសួរ បាននន័យថាអគ្គព្រះរាជអាជ្ញា ត្រូវតែបញ្ជូនពាក្យប្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ក្នុងរយៈពេល ០១ (មួយ) ខែ យ៉ាងយូរគិតពីពេលប្រកាសដីកា។[82]

មូលហេតុដែលព្រះរាជអាជ្ញាអាចធ្វើការបណ្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ គឺដើម្បីធានាថាការអនុវត្តការងាររបស់ចៅក្រមស៊ើបសួរគឺ ត្រឹមត្រូវ មិនបំពាន ឬរំលោភសិទ្ធិ ទោះបុគ្គលនោះជាពិរុទ្ធជនក៏ដោយ។ ឧទាហរណ៍ ការចេញដីកាឱ្យឃុំខ្លួនជាបណ្ដោះអាសន្នមកលើពិរុទ្ធ តែពិរុទ្ធនោះជាស្ត្រី និងជាមេគ្រួសារមានកូនតូច ក្នុងបន្ទុក។ ដោយមើលឃើញភាពមិនចាំបាច់ក្នុងការឃុំខ្លួនបណ្ដោះអាសន្នបែបនេះ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអាចធ្វើការបណ្ដឹងឧទ្ធរណ៍ចំពោះដីកានោះបាន ដោយសារព្រះរាជអាជ្ញាមិនត្រឹមតែមានតួនាទីក្នុងការធ្វើបណ្ដឹងអាជ្ញាដាក់បន្ទុកជនល្មើសទេ ថែមទាំងមានតួនាទីការពារសិទ្ធិ ធ្វើការដោះបន្ទុក ស្វែងរកយុត្តិធម៌ដល់ជនល្មើស និងអនីតិជន។

**ខ. ការតម្កល់រឿងទុកឥតចាត់ការ**

បន្ទាប់ពីទទួលបានពាក្យប្ដឹងបរិហារ ពាក្យប្ដឹងពីប្រជាពលរដ្ឋ ឬក៏ការបញ្ជូនសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែង និងពិចារណាថាតើគួរសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងថា ពេលណាគួរធ្វើបណ្ដឹងអាជ្ញា និងពេលណាមិនគួរធ្វើទៅបាន ព្រោះកម្ពុជាបានអនុវត្តប្រព័ន្ធកាលានុវត្តភាពនៃបណ្ដឹងអាជ្ញា។[83] ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា អំពើដែលគេប្ដឹងមកមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬគ្មានភស្តុតាងណាមួយឱ្យជឿថា ពិតជា

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៦៧ និងមាត្រា ២៦៨

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២៧០ កថាខណ្ឌទី ១

[83] ឯកឧត្តម កើត រិទ្ធ, *មេរៀនសង្ខេបស្តីពីនីតិវិធីព្រហ្មទណ្ឌ*, នីតិកោសល, រៀបរៀង (២០២០), ទំព័រ៥ អាចរកបាននៅ៖ https://www.facebook.com/1812462692130749/posts/2758586860851656/ (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)

បទល្មើសកើតឡើងមែននោះ (គ្មានធាតុផ្សំទាំងបីនៃបទល្មើស) មានន័យថាអំពើប្រព្រឹត្តនោះមិនមែនជា បទល្មើសឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលច្បាប់កំណត់ផ្តន្ទាទោស ឬក៏គ្មានពិរុទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ដូច្នេះព្រះរាជអាជ្ញានឹងចេញដីកាតម្កល់រឿងទុកឥតចាត់ការ ដោយមានសំអាងច្បាប់ និងសំអាងហេតុ។ ការសម្រេចតម្កល់រឿងទុកឥតចាត់ការដើម្បីជៀសវាងការប្តឹងផ្តល់ដោយគ្មានមូលដ្ឋានច្បាប់។ ការតម្កល់រឿងទុកឥតចាត់ការ គឺជាគុណវិបត្តិមួយនៃប្រព័ន្ធកាលានុវត្តភាពនៃបណ្តឹងអាជ្ញា ពោលគឺព្រះរាជអាជ្ញាបានប្រើប្រាស់អំណាចរបស់ខ្លួនជ្រុល។ ដូចនេះបើទោះបីជាមានការតម្កល់រឿងទុកឥតចាត់ការក៏ដោយ ក៏ច្បាប់អនុវត្តឱ្យមានការប្តឹងតវ៉ាពីសំណាក់ម្ចាស់បណ្តឹងមកកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្រោយមានការជូនជាដំណឹងពីដីកាតម្កល់រឿងទុកឥតចាត់ការក្នុងរយៈពេល ០២ (ពីរ) ខែ។ តំណាងអយ្យការអមសាលាដំបូងត្រូវបញ្ជូនសំណុំរឿងភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថាការតវ៉ាមានមូលហេតុត្រឹមត្រូវ ត្រូវចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាសាលាដំបូងឱ្យធ្វើការចោទប្រកាន់។ ផ្ទុយទៅវិញបើអគ្គព្រះរាជអាជ្ញាយល់ឃើញថាការតវ៉ាពុំមានមូលហេតុត្រឹមត្រូវ ត្រូវទុកសេចក្តីសម្រេចរបស់សាលាដំបូងយកជាការបានហើយត្រូវឱ្យដំណឹងនេះដល់អ្នកប្តឹងតវ៉ា។[84] ការតម្កល់រឿងទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ។[85]

**គ. ចំពោះព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង**

អនុលោមតាមមាត្រា ៥១ កថាខណ្ឌទី ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់បាន ដោយ អនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន បានន័យថា នៅពេលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បានដឹងច្បាស់ ឬបានតាមដានពីរឿងក្តីណាមួយដែលបច្ចុប្បន្នស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃអយ្យការអមសាលាដំបូង តែអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មើលឃើញពីដំណោះស្រាយ ឬទុច្ចរិតភាពនៃពុរិទ្ធជន គាត់អាចបញ្ជាឱ្យព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់ទោសទៅតាមការយល់ឃើញរបស់គាត់ផ្ទាល់។

**កថាខណ្ឌទី៣៖ ចំពោះមន្ត្រីនគរបាលយុត្តិធម៌**

ទាក់ទងទៅនឹងការប្រព្រឹត្តទៅរបស់អង្គភាពនេះ ព្រះរាជអាជ្ញាអាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឱ្យបំពេញភារកិច្ច ទាំងឡាយដែលខ្លួនយល់ថា មានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការល្អនៃនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាច ធ្វើអធិការកិច្ចគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌។ គាត់ក៏អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យ វិធានការឃាត់ខ្លួន ជាពិសេសការគោរពទម្រង់ច្បាប់ និងការកាន់

[84] សេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ-អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១

កាប់ទីកន្លែងឃាត់ខ្លួន។ ប្រធានអង្គភាពនគរបាល យុត្តិធម៌មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូប ត្រូវគោរពតាមអធិបញ្ញា របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

ក្នុងករណីមាន បណ្តឹងព្រហ្មទណ្ឌណាមួយកំពុងចាត់ការដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវការសុំយោបល់ ឬសុំការអនុញ្ញាតពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និង ភ្នាក់ងារនគរបាលយុត្តិធម៌ ហេតុនេះ ទោះជាក្នុងករណីនៃការបើកស៊ើបអង្កេតបឋម ឬស៊ើបអង្កេតជាក់ស្តែងក៏ដោយ មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវមានការសុំយោបល់ និងការអនុញ្ញាតពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង លើកិច្ចការងាររបស់ខ្លួនជាដាច់ខាត។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទទួលដំណឹងពីកំហុសរបស់មន្ត្រីនគរបាលយុត្តិធម៌ តាមរបាយការណ៍ ពីព្រះរាជអាជ្ញា ឬពីចៅក្រមស៊ើបសួរ បន្ទាប់មកអគ្គព្រះរាជអាជ្ញា ប្រកាសជូនដំណឹងដល់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិដើម្បីចាប់ដំណើរការនីតិវិធីវិន័យ។

ក្នុងករណីអគ្គព្រះរាជអាជ្ញា យល់ឃើញថាកំហុស ប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ណាម្នាក់មានសភាព ធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញា មានសិទ្ធិប្រកាសចេញនូវវិធានការរួមមាន ការដាក់វិន័យទៅលើមន្ត្រីនគរបាលយុត្តិធម៌ដែលបានប្រព្រឹត្តកំហុសមានកម្រិតដូចតទៅ៖

- ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត
- និងហាមមិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។[86]

### កថាខណ្ឌទី៤៖ ចំពោះតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

#### ក. បណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខគឺជា បណ្តឹងដែលធ្វើឡើងនៅពេលដែលអគ្គព្រះរាជអាជ្ញា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬតំណាងស្របច្បាប់មិនសុខចិត្តចំពោះសាលដីការបស់សាលាឧទ្ធរណ៍។ សេចក្តីសម្រេចដែលអាចធ្វើបណ្តឹងសាទុក្ខបានមានដូចជា សាលដីកានៃសភាស៊ើបសួរ ដោយគិតទាំងរឿងធ្វើបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។ ប៉ុន្តែវិធីតវ៉ានេះមិនអាចធ្វើបានទេចំពោះសាលដីកានៃការស៊ើបសួរ ដែលបង្គាប់ឱ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះនោះ។[87]

❖ បណ្តឹងសាទុក្ខអាចត្រូវធ្វើដោយ៖

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៦៦

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១៧

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ជនជាប់ចោទ ឬពិរុទ្ធជន
- បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន
- ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

បណ្ដឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល។[88]

❖ មូលហេតុនៃបណ្ដឹងសាទុក្ខ

តុលាការកំពូលអាចបដិសេធសេចក្ដីសម្រេចក្នុងករណីដូចតទៅ ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថភាពនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្ដឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្ដឹងសុំនេះ ធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានសំអាងហេតុ
- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្ដីសម្រេច។[89]

❖ រយៈពេលដើម្បីធ្វើបណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេលដូចតទៅ ៖

- ០១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍
- ១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
- ០៥ (ប្រាំ) ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន។

កាលណាសាលដីកាដែលប្ដឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្ដើមគិតពីការប្រកាសសាលដីកា។ កាលណាសាលដីកាដែលប្ដឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះ

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១៨

[89] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤១៩

មុខរយៈពេលត្រូវផ្ដើមគិតពីការឱ្យដំណឹង។ កាលណាសាលដីកាសម្រេចកំបាំងមុខ រយៈពេលត្រូវផ្ដើមគិតពីការផុតរយៈពេលប្ដឹងទាស់។[90]

**ខ. ចំពោះអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល**

យោងតាមមាត្រា ៧៦ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ជារៀងរាល់ឆ្នាំអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវធ្វើរបាយការណ៍អំពីបទល្មើស សកម្មភាពការងាររបស់ខ្លួន និងសកម្មភាពការងាររបស់អយ្យការអមសាលាដំបូងទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

**កថាខណ្ឌទី៥៖ ទំនាក់ទំនងការងារផ្សេងៗជាមួយស្ថាប័នជាតិ និងអន្តរជាតិ**

**ក. ស្ថាប័នជាតិ**

ជារៀងរាល់ឆ្នាំ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានកាតព្វកិច្ចមួយដោយត្រូវធ្វើរបាយការណ៍អំពីបទល្មើស សកម្មភាពការងាររបស់ខ្លួន និងសកម្មភាពការងាររបស់អយ្យការអមសាលាដំបូងទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[91] លើសពីនេះអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាទាំងអស់ នៃមហាអយ្យការអមសាលាឧទ្ធរណ៍ដែលកំពុងបំពេញមុខងារ មានបំណងចង់ផ្សព្វផ្សាយអត្ថបទ ឬការសរសេរសំណៅឯកសារណាមួយជាសាធារណៈត្រូវសុំការអនុញ្ញាជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឱ្យត្រួតពិនិត្យដើម្បីបញ្ចៀសកំហុសដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ។[92] ព្រះរាជអាជ្ញាក៏អាចចូលរួមជាមួយជាស្ថាប័នជាតិ ឬស្ថាប័នក្នុងស្រុកមួយចំនួនក្នុងវិស័យច្បាប់ ឬផ្ដល់ជាបទសម្ភាសន៍ដល់សារព័ត៌មានក្នុងស្រុក ដោយព្រះរាជអាជ្ញាដើរតួជាអ្នកផ្សព្វផ្សាយពីចំណេះដឹងទាក់ទងនឹងច្បាប់ទៅដល់មនុស្សគ្រប់មជ្ឈដ្ឋាន។ ជាឧទាហរណ៍ សមាគមន៍សាលាត្រាជូ[93] បានអញ្ជើញព្រះរាជអាជ្ញាមួយរូបមកធ្វើជាវាគ្មិនដើម្បីចែករំលែកបទពិសោធន៍ ក៏ដូចជាចំណេះផ្នែកច្បាប់របស់គាត់ទាក់ទងនឹងវិជ្ជាជីវៈតុលាការ ព្រះរាជអាជ្ញា។ លើសពីនេះទៅទៀតព្រះរាជអាជ្ញាអាចបំពេញមុខងារជាគ្រូឧទ្ទេសនាមតាមគ្រឹះស្ថានសិក្សាបាន។[94]

---

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៤២០

[91] ច្បាប់ស្តីពីលក្ខន្តិកនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៧៦

[92] ច្បាប់ស្តីពីលក្ខន្តិកនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ៩៦

[93] សមាគមន៍សាលាត្រាជូ, គោលបំណង និងបេសកកម្ម៖ ជាសមាគមន៍អគ្គដែលប្រមូលផ្ដុំអ្នកច្បាប់ជាតិ ឬអន្តរជាតិដែលសមត្ថភាព និងមានគោលបំណងចង់អភិវឌ្ឍន៍ និងសហប្រតិបិត្តការណ៍ ដើម្បីអភិវឌ្ឍន៍វិស័យច្បាប់នៅកម្ពុជា។ https://salatraju.com/About%20us/Objectifs%20and%20Missions (ចូលទស្សនាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១)

[94] ច្បាប់ស្តីពីលក្ខន្តិកនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា ១០៦

**ខ. ស្ថាប័នអន្តរជាតិ**

ក្រៅពីការសហប្រតិបត្តិការជាមួយស្ថាប័នជាតិ ព្រះរាជអាជ្ញាក៏បានធ្វើសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាល ពិសេសប៉ូលីសអន្តរជាតិផងដែរ ក្នុងការដោះស្រាយរឿងក្តីដែលមានលក្ខណៈពាក់ព័ន្ធជាអន្តរជាតិដូចជា សំណុំរឿងបទល្មើសលាងលុយខ្មៅ ការគេចពន្ធ និងជួញដូរខុសច្បាប់តាមច្រកព្រំដែន បទល្មើសក្នុងវិស័យព័ត៌មានវិទ្យាដូចជាការលួចទិន្នន័យធនាគារ ឯកសារសម្ងាត់ ដែលកម្ពុជាយើងនៅមានបទសោធន៍តិចតួចត្រូវការ ការណែនាំ សហការណ៍ជាមួយអន្តរជាតិ និងអាចមានការផ្លាស់ប្តូរបទពិសោធន៍ការងារនៅក្រៅប្រទេស ដែលជាអ្នកតំណាងឱ្យប្រទេសកម្ពុជា។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការអាន និងស្រាវជ្រាវកន្លងមកអំពីប្រធានបទខាងលើរួចហើយ យើងបានយល់ដឹងបន្ថែម អំពីចំណុចដែលមានសារៈសំខាន់ជាច្រើនទាក់ទងនឹងតួនាទីរបស់ចៅក្រមអយ្យការ នៃមហាអយ្យការអមសាលាឧទ្ធរណ៍ ថាមានលក្ខណៈសំខាន់មួយផ្នែកធំក្នុងពេលបច្ចុប្បន្ន។ ជាទូទៅចៅក្រមអយ្យការ ដែលតំណាងឱ្យស្ថាប័នអយ្យការមិនថាស្ថិតនៅអមសាលាជម្រះក្តីថ្នាក់ណានោះទេ មានតួនាទីជាអ្នកអនុវត្តនូវបណ្តឹងអាជ្ញាដើម្បីការពារប្រយោជន៍សាធារណៈ អនុវត្តនូវសេចក្តីសម្រេចខាងព្រហ្មទណ្ឌ តាមមាត្រា ២៧ ដែលមានកំណត់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

តាមការសិក្សាស្រាវជ្រាវមកពី ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាកន្លងមក ការបែងចែកតាមឋានានុក្រមនៃអង្គការអយ្យការដែលមាននៅអមតុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូងនៃព្រះរាជាណាចក្រកម្ពុជា បានបែងចែកតាមដំណាក់កាល។ ការសិក្សាផ្តោតសំខាន់ទៅលើគោលការណ៍របស់ចៅក្រមអយ្យការដែលមានតួនាទី ទៅលើបញ្ហានានាដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ខ្លួន។ យើងបានសិក្សាពីដំណាក់កាលជ្រើសរើសព្រះរាជអាជ្ញា ឆ្លងកាត់ការប្រឡងប្រជែង បណ្តុះបណ្តាល ជំនាញ ប្រកបទៅដោយចំណេះវិជ្ជា និងក្រមសីលធម៌វិជ្ជាជីវៈមុននឹងឈានចូលទៅបម្រើការងារវិស័យច្បាប់ក្នុងសង្គម នេះហើយជាចំណុចដ៏សំខាន់ដើម្បីឱ្យការជ្រើសរើស ពោរពេញ ដោយគុណភាព តម្លាភាព។ ព្រះរាជអាជ្ញា ទាំងអស់អនុវត្តការងារជូនសង្គមជាតិដោយប្រាជ្ញាស្មារតី។ ជាការពិតណាស់ ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ក៏មានមុខងារ តួនាទី សិទ្ធិអំណាច គឺប្រហាក់ប្រហែលគ្នាទៅនឹង ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងដែរ។ លើសពីនេះទៅទៀតព្រះរាជអាជ្ញាក៏ត្រូវបានទទួលការដំឡើងថ្នាក់ ដំឡើងឋានន្តរស័ក្តិស្របតាមកិច្ចការ លក្ខខណ្ឌ ទាំងឡាយដែលខ្លួនបានបំពេញចំពោះការផ្លាស់ប្តូរ ការផ្អាច់មុខងារ សុំនៅក្រៅក្របខណ្ឌ និងលុបឈ្មោះចេញ ធ្វើឡើងតាមច្បាប់កំណត់។ ជាពិសេសព្រះរាជអាជ្ញា អនុវត្តសិទ្ធិអំណាចខ្លួនទៅលើមន្ត្រីនគរបាលយុត្តិធម៌ ចូលរួមធ្វើកិច្ចការងារក្នុងសង្គមមានដំណើរការគ្រប់គ្រងល្អនៃនគរបាលយុត្តិធម៌ ហើយអាចធ្វើអធិការកិច្ចគ្រប់ពេលនៅអង្គភាពមន្ត្រីនគរបាលយុត្តិធម៌ រួមទាំងពេលធ្វើបណ្តឹងឧទ្ធរណ៍ ឆន្ទានុសិទ្ធិលើការតម្កល់រឿងទុកគតចាត់ការ និងបណ្តឹងសាទុក្ខ។

ដូចដែលបានរៀបរាប់ខាងលើ ព្រះរាជអាជ្ញាត្រូវបានប្រគល់នូវសិទ្ធិអំណាចដ៏ធំធេងជាកត្តាដែលជម្រុញឱ្យការជ្រើសរើសព្រះរាជអាជ្ញាដាច់ខាតត្រូវតែជាបុគ្គលដែលមានសមត្ថភាព ចំណេះដឹងច្បាស់លាស់ផ្នែកសង្គម និងផ្នែកច្បាប់ ដើម្បីធានាថារាល់ការអនុវត្តនីតិវិធីប្រកបដោយភាពត្រឹមត្រូវ និងប្រសិទ្ធិភាព។ ព្រោះថាបើនៅពេលព្រះរាជអាជ្ញាធ្វើការសម្រេចអ្វីមួយតាមនីតិវិធីមានកំហុសឆ្គង ដោយសារការខ្វះខាត

ចំណេះដឹង វាអាចជះឥទ្ធិពលដល់សង្គមទាំងមូល។ ជាហេតុដែលការប្រលងជ្រើសរើសសិស្សព្រះរាជអាជ្ញាមានលក្ខណៈសម្រិតសម្រាំង និងប្រកួតប្រជែងខ្លាំង ដើម្បីជម្រាញ់យកនូវបញ្ញាវ័ន្តផ្នែកច្បាប់ដែលមានសមត្ថភាព និងគុណភាពដើម្បីបម្រើការ និងស្វែងរកយុត្តិធម៌ឱ្យបានដល់ប្រជាពលរដ្ឋ។

*ប្រសិនបើការសម្រេចចិត្តរបស់ព្រះរាជអាជ្ញាធ្វើទៅមានកំហុសឆ្គង*
*ជនរងគ្រោះនឹងមិនអាចទទួលបាននូវយុត្តិធម៌ ឬមនុស្សស្លូតត្រង់ម្នាក់*
*នឹងក្លាយទៅជាការជនរងគ្រោះ។ ហើយក្នុងករណីដែលព្រះរាជអាជ្ញាខ្វះសមត្ថភាព*
*ជនដែលបានប្រព្រឹត្តល្មើសទៅនឹងច្បាប់ អាចនឹងរួចផុតពីការទទួលទោស។*

ការស្រាវជ្រាវ អស់រយៈពេលជាយូរ ទាក់ទងនឹងប្រធានបទខាងលើនេះ ពួកយើងពិតជាអារម្មណ៍រំភើប និងត្រេកអរដែលបានជ្រើសរើសប្រធានបទមួយនេះ ពីព្រោះបានសិក្សាទៅលើមុខងារនីមួយៗបន្ថែមទៀតឱ្យកាន់តែច្បាស់ អង្គការអយ្យការ និងអំណាចរបស់ព្រះរាជអាជ្ញាគ្រប់ជាន់ថ្នាក់ ពិសេសគឺសាលាឧទ្ធរណ៍។ ទន្ទឹមនឹងការសោមនស្សដែលយើងខ្ញុំបានយល់កាន់តែច្បាស់ពីមុខងាររបស់ចៅក្រមអយ្យការ តាមរយៈការខិតខំស្រាវជ្រាវរបស់យើងខ្ញុំកន្លងមក ក៏យើងខ្ញុំមើលឃើញនូវបញ្ហាប្រឈមមួយចំនួន ដែលប្រជាជនមូលដ្ឋានមួយចំនួនតូចនៅតែមានការភ័ន្តច្រឡំទាក់ទងនឹងតួនាទីរបស់ព្រះរាជអាជ្ញា។ ជាក់ស្តែងពួកគាត់យល់ច្រឡំថាមេធាវីដែលជាអ្នកតំណាងអាណត្តិរបស់គាត់មានសិទ្ធិធ្វើការចោទប្រកាន់ជនល្មើសពីបទល្មើសណាមួយ។ ផ្ទុយទៅវិញក្នុងរឿងក្តីព្រហ្មទណ្ឌមេធាវីតំណាងរបស់គាត់ត្រឹមតែដើរតួជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ បញ្ហាចោទមួយទៀតគឺ ទាក់ទងនឹងមុខងារ តួនាទីរបស់ចៅក្រមអយ្យការ ឬព្រះរាជអាជ្ញា ជាមួយហ្នឹងចៅក្រមជំនុំជម្រះ ដោយមូលហេតុមានពាក្យបច្ចេកទេសក្នុងវិស័យច្បាប់បានប្រើប្រាស់ថាជា ចៅក្រមឈរ និងចៅក្រមអង្គុយ។ បន្ថែមលើការភ័ន្តច្រឡំទាក់ទងនឹង តួនាទី មុខងារនេះ ឯកសណ្ឋានរបស់ចៅក្រមអយ្យការ និងចៅក្រមជំនុំជម្រះក៏ជាកត្តាមួយដែលធ្វើឱ្យមានការភ័ន្តច្រឡំ ព្រោះថាយើងបានលើកឡើងជារឿយៗថាចៅក្រមអយ្យការ មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាលាជម្រះក្តីណាមួយដែលខ្លួននៅអមទេ ប៉ុន្តែស្របពេលគ្នានេះ ពណ៌នៃឯកសណ្ឋានរបស់ចៅក្រមអយ្យការ និងចៅក្រមជំនុំជម្រះគឺមានលក្ខណៈដូចគ្នា ដែលធ្វើឱ្យមហាជនទូទៅមានការយល់ច្រឡំ។ ពិសេសនៅពេលមានសវនការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលមានវត្តមានទាំងចៅក្រមអយ្យការ និងចៅក្រមជំនុំជម្រះដែលមានឯកសណ្ឋានដូចគ្នា នេះបើតាមកត្តាចិត្តវិទ្យា វាអាចក្លាយជាការដាក់សម្ពាធមួយដល់ខាងមេធាវី ឬអ្នកតំណាងអាណត្តិរបស់ចុងចម្លើយ និងជនជាប់ចោទ។ លក្ខណៈសម្បត្តិដែលអាចក្លាយជាចៅក្រម មិនថាជាចៅក្រមអសនៈ ឬចៅក្រមឈរនោះទេ លក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាត្រង់ចំណុចអាយុរបស់បេក្ខភាព ពុំទាន់ល្អប្រសើរនៅឡើយ។ មួយទៀត គឺបញ្ហាកកស្ទះសំណុំរឿង

ដោយសារតែ ប្រមុខរាជរដ្ឋាភិបាលបានចេញយន្តការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមគ្រប់សាលាដំបូងរាជធានី-ខេត្ត បន្ទាប់ពីបានចេញសាលក្រមនៅសាលាដំបូងហើយ សាលក្រមមួយចំនួនមានការមិនពេញចិត្ត ក៏បានប្តឹងមកសាលាឧទ្ធរណ៍ ជាហេតុដែលមានបណ្តឹងឧទ្ធរណ៍កើនឡើងជាបន្តបន្ទាប់បង្កជាការកកស្ទះនៅសាលាឧទ្ធរណ៍ម្តង។ នេះហើយជាបញ្ហាដែលបច្ចុប្បន្ននេះនៅតាមសាលាឧទ្ធរណ៍គ្រប់តំបន់មានការរាំងស្ទះខ្លាំង។ ជាចុងក្រោយ បញ្ហាដែលតែងតែកើតមានជារឿយៗមួយផ្នែកទៀតនោះគឺ ទំនាក់ទំនង ការសហការណ៍គ្នារវាងចៅក្រមអយ្យការ និងមន្ត្រីពាក់ព័ន្ធដទៃទៀតក្នុងពេលអនុវត្តផ្ទាល់ហាក់ដូចជាមិនទាន់បានគោរព និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមគោលការណ៍ដែលច្បាប់បានចែងនៅឡើយទេ។

បញ្ហាដែលបានរៀបរាប់ខាងលើ គឺសុទ្ធតែជារនាំង ចំណុចស្រអាប់ ដែលរាជរដ្ឋាភិបាលកម្ពុជាគួរយកចិត្តទុកដាក់ក្នុងការសម្អាត និងវិធានការណ៍ដ៏មានប្រសិទ្ធភាពណាមួយក្នុងការជម្រះនូវចំណុចទាំងនោះចោលឱ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន។ ក៏ព្រោះតែបញ្ហាទាំងនោះ ប្រៀបដូចជាដុំខ្លាញ់ក្នុងសរសៃឈាមនៃវិស័យច្បាប់ វាធ្វើឱ្យមានការកកស្ទះ រារាំងមន្ត្រីពាក់ព័ន្ធក្នុងការស្វែងរកយុត្តិធម៌ ក៏ដូចជាពន្យឺតដល់ការអនុវត្តកាតព្វកិច្ច ប៉ះពាល់សេរីភាព សិទ្ធិមនុស្ស និងការជឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌កម្ពុជា។

# អនុសាសន៍

បញ្ហាធំៗដែលត្រូវការដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងឱ្យទាន់ពេលវេលានោះរួមមានដូចជា ការភ័ន្តច្រឡំតួនាទីមេធាវីទៅនឹងព្រះរាជអាជ្ញា ការភ័ន្តច្រឡំតួនាទីចៅក្រមជំនុំជម្រះទៅនឹងព្រះរាជអាជ្ញា ឯកសណ្ឋានព្រះរាជអាជ្ញា និងចៅក្រម កត្តាអាយុក្នុងលក្ខន្តិកៈប្រលង និងក្លាយជាចៅក្រម ឬព្រះរាជអាជ្ញា ការកកស្ទះសំណុំរឿង ការអនុវត្តកាតព្វកិច្ចរបស់មន្ត្រីពាក់ព័ន្ធដែលជះឥទ្ធិពលដល់ការអនុវត្តកាតព្វកិច្ចរបស់ព្រះរាជអាជ្ញា និងចុងក្រោយការសហការណ៍របស់ព្រះរាជអាជ្ញាជាមួយមន្ត្រីពាក់ព័ន្ធ។ ក្នុងនាមជានិស្សិត និងជាធនធានក្នុងសង្គម យើងខ្ញុំទាំងពីរសូមធ្វើការផ្ដល់ជាអនុសាសន៍ និងសំណូមពរមួយចំនួនដែលអាចដោះស្រាយនូវបញ្ហាប្រឈមដែលបានលើកឡើងខាងលើ៖

- រាជរដ្ឋាភិបាល និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ គប្បីបង្កើតឱ្យមានការផ្សព្វផ្សាយជាសារធារណៈឱ្យបានទូលំទូលាយ និងជាប្រចាំ អាចក្រោមទិដ្ឋភាពជារូបភាព វីដេអូ អត្ថបទច្បាប់ សារព័ត៌មាន កិច្ចសម្ភាសន៍ សិក្ខាសាលា។ល។ យើងធ្លាប់ឃើញមានការផលិតជាវីដេអូផ្សព្វផ្សាយកន្លងមក នៅពេលក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌទើបអនុម័តឱ្យប្រើប្រាស់ ប៉ុន្តែវីដេអូទាំងនោះគឺពិបាកស្វែងរកយកមកធ្វើជាឯកសារ ឬស្ដាប់ និងមើលសម្រាប់ជាពុទ្ធិណាស់ ព្រោះវាមានអាយុជាងមួយទសវត្សរ៍កន្លះទៅហើយ។ ចំណែកច្បាប់ថ្មីៗ តែទើបតែបានអនុម័តបន្តបន្ទាប់មកទៀត នៅមិនទាន់បានផ្សព្វផ្សាយឱ្យបានដល់គ្រប់មជ្ឈដ្ឋានបានដឹង បានយល់នៅឡើយទេ។ ពិសេសទាក់ទងបញ្ហាដែលមានការភ័ន្តច្រឡំពីសមត្ថកិច្ចរបស់មេធាវីតំណាងអាណត្តិថាមានសមត្ថកិច្ចធ្វើការចោទប្រកាន់ជនសង្ស័យ ឬជនប្រព្រឹត្តល្មើសនិងច្បាប់ពីបទល្មើសណាមួយដែលច្បាប់បានចែង។

- ទាក់ទងនឹងបញ្ហាឯកសណ្ឋានដែលមានពណ៌ និងសណ្ឋានដូចគ្នារបស់ចៅក្រមជំនុំជម្រះ និងចៅក្រមអយ្យការ យើងខ្ញុំសុំផ្ដល់ជាយោបល់ ក៏ដូចជាការស្នើសុំដល់មន្ត្រីមានសមត្ថិភាពពាក់ព័ន្ធ កាន់ការផ្នែកនេះធ្វើការប្ដូរពណ៌ឯកសណ្ឋាន។ ព្រោះថាបើនៅតែមានការរក្សាទុកទម្រង់ឯកសណ្ឋានបែបនេះ វាអាចជះឥទ្ធិពល និងរូបភាពមិនល្អមកលើភាពយុត្តិធម៌របស់ចៅក្រមអយ្យការ និងចៅក្រមជំនុំជម្រះនៅពេលសម្រេចសេចក្ដីដោយសារតែលក្ខណៈដូចគ្នានេះ មើលទៅហាក់បីដូចជាចៅក្រមអយ្យការ និងចៅក្រមជំនុំជម្រះឈរលើខ្សែតែមួយ ជាបក្ខពួកគ្នា ហើយវាក្លាយជាកត្តាសម្ពាធផ្លូវចិត្ត និងការគិតរបស់មេធាវីតំណាងអាណត្តិរបស់ចុងចម្លើយ។ ឧទាហរណ៍ នៅក្នុងសវនាការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌករណីបណ្ដឹងសាទុក្ខលើកទី២ ដែលមានក្រុមប្រឹក្សាជំនុំជម្រះ ០៩ (ប្រាំបួន) រូប បូករួមចៅក្រមអយ្យការ ០១ (មួយ) រូប ដែលមានឯកសណ្ឋានពណ៌ក្រហមដូចគ្នា ចំណែកឯខាងមេធាវីតំណាងអាណត្តិរបស់ចុងចម្លើយមានតែ ០១ (មួយ) រូប ឬច្រើនក្ដី ក៏នៅតែទទួលរងនូវសម្ពាធផ្លូវចិត្តតាមរូបភាពនៃឯកសណ្ឋានរួចទៅហើយ។ ដើម្បីឱ្យមានភាពយុត្តិធម៌ មិនថារូបភាពខាងក្រៅ

ឬឆន្ទៈខាងក្នុងទេនោះ ឯកសណ្ឋានរបស់ចៅក្រមអយ្យការ និងចៅក្រមជំនុំជម្រះ គប្បីមានការកែប្រែ ផ្លាស់ប្តូរឱ្យមានលក្ខណៈខុសគ្នា។

• បញ្ហាលក្ខខណ្ឌអាយុរបស់បេក្ខភាពដែលអនុញ្ញាតឱ្យប្រឡងប្រជែងដើម្បីក្លាយជាសិស្សចៅក្រម និងសិស្សព្រះរាជអាជ្ញា ក្រោយរយៈពេលបណ្តុះបណ្តាល ២ (ពីរ) ឆ្នាំ អាចនឹងក្លាយជាចៅក្រម ព្រះរាជអាជ្ញានោះ ពុំទាន់មានភាពល្អប្រសើរនោះ ត្រង់ចំណុចថាការកំណត់យក ឬអនុញ្ញាតឱ្យបេក្ខភាពដែលមានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំយ៉ាងច្រើន មកធ្វើជាអ្នកជំនុំជម្រះក្តី វិនិច្ឆ័យ ឬក៏តំណាងឱ្យរដ្ឋក្នុងស្វែងរកភស្តុតាង ស៊ើបអង្កេត និងធ្វើការចោទប្រកាន់ជនល្មើសពីបទល្មើសអ្វីមួយដូចមានចែងក្នុងច្បាប់នោះ វាហាក់បីដូចមិនសមរម្យ ព្រោះគាត់អាចនៅមានភាពខ្វះខាតខាងផ្នែកបទពិសោធន៍សង្គមជាក់ស្តែង។ ខាងផ្នែកសមត្ថភាព ចំណេះដឹង ប្រាជ្ញា យើងជឿថាគាត់មានសព្វគ្រប់ហើយ នៅខ្វះតែបទពិសោធន៍ជីវិត។ ឧទាហរណ៍ ចៅក្រមជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីករណីបណ្តឹងលែងលះ គាត់អាចធ្វើការវិនិច្ឆ័យទៅតាមតែច្បាប់បានកំណត់ក៏បាន ប៉ុន្តែក្នុងរឿងក្តីលែងលះ ពេលខ្លះក៏ត្រូវការ ការយល់ពីស្ថានភាពជីវិតគ្រួសារ មនោសញ្ចេតនា មកដោះស្រាយ។ ស្របពេលគ្នានេះបើចៅក្រមពុំទាន់បានឆ្លងកាត់បទសោធន៍នេះផងថាតើ គាត់អាចធ្វើការវិនិច្ឆ័យឱ្យមានសុក្រិត្យភាពបែបណាទៅ។ ដូចឯកឧត្តម កេង សុម៉ារិទ្ធ ធ្លាប់មានប្រសាសន៍ក្នុងសិក្ខាសិលាស្តីពី វិជ្ជាជីវៈចៅក្រម៖

*រឿងក្តីមួយរឿងគ្រាន់តែជាសំណុំរឿងមួយប៉ុណ្ណោះសម្រាប់ចៅក្រម*
*ប៉ុន្តែរឿងក្តីមួយរឿងគឺជាជោគវាសនា និងអាយុជីវិតរបស់ភាគីនៃរឿងក្តី។*

ដូចនេះចៅក្រម ព្រះរាជអាជ្ញាគប្បីជាបុគ្គលដែលមានមិនត្រឹមតែសមត្ថភាព ចំណេះដឹង ប្រាជ្ញា ប៉ុណ្ណោះទេ គប្បីមានបទពិសោធន៍សង្គម និងបទពិសោធន៍ជីវិតបរិបូរណ៍ថែមទៀតផងដែរ។

• ដំណោះស្រាយចំពោះភាពចម្រូងចម្រាសនៃការសហការណ៍រវាងចៅក្រមអយ្យការ និងមន្ត្រីពាក់ព័ន្ធគ្រប់ជាន់ថ្នាក់គឺ សំណូមពរឱ្យ៖

❖ មន្ត្រីនគរបាលយុត្តិធម៌

▪ ជាដំបូងត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ គោលការណ៍ វិជ្ជាជីវៈ ត្រូវគោរពតាមនីតិវិធី ដែលចែងក្នុងច្បាប់ បំពេញការងារឱ្យបានល្អប្រសើរជូនដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់។

▪ គប្បីស្វែងរកភស្តុតាង ឱ្យបានច្បាស់លាស់ ល្អិតល្អន់ ស្របតាមជំនាញ ជៀសវាង បង្ករផលលំបាកក្នុងការឃាត់ខ្លួន កសាងសំណុំរឿង បញ្ជូនទៅដំណាក់កាលចៅក្រមស៊ើបសួរ មានការភាន់ច្រលំ ខាតពេលផលប្រយោជន៍ក្នុងការសួរចម្លើយ ហើយរកភស្តុតាងបន្ថែមពីលើ។

▪ ជាពិសេស គឺមិនត្រូវបង្ខិតបង្ខំ ប្រើប្រាស់អំពើហិង្សា គំរាមកំហែង សព្វសារពើ បង្ករឱ្យមានផលប៉ះពាល់ផ្លូវចិត្ត ស្មារតី ក្នុងការផ្តល់ចម្លើយ ដោយមានគំនាប ពុំហ៊ានសារភាព តាមដំណើរនៃអង្គហេតុ ហើយមួយវិញទៀត

កសាងសំណុំរឿង តាមតែខ្លួនឯងបានយល់ឃើញនឹងគិត និងមិនត្រូវបំផ្លើសអង្គហេតុ ដើម្បីការស៊ើបអង្កេតឱ្យបានឆាប់រហ័ស។ ព្រោះកំហុសទាំងនោះធ្វើឱ្យការអនុវត្តកាតព្វកិច្ច ឬកិច្ចការរបស់ព្រះរាជអាជ្ញាមានភាពលំអៀង ឬមានកំហុស អាចក្លាយជាការផ្តល់ឱកាសឱ្យជនសង្ស័យរួចខ្លួនពីការចោទប្រកាន់។

❖ ចៅក្រមអយ្យការ

▪ ត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយឯករាជ្យ និងឯករាជ្យភាពនៅចំពោះមុខតុលាការ មានន័យថា ព្រះរាជអាជ្ញា

▪ នៅអមតុលាការណាមួយ មិននៅក្រោមអំណាចតុលាការនោះទេ។ តុលាការគ្មានអំណាចអ្វីមកត្រួតពិនិត្យកិច្ចការរបស់អយ្យការនៅទេ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការមិនអាចសរសេរិះគន់ ឬបន្ទោសថាព្រះរាជអាជ្ញាធ្វើនេះមិនត្រូវ ឬដូច្នេះមិនល្អយ៉ាងណាៗនោះទេ។ តុលាការមិនអាចបង្គាប់បញ្ជាឱ្យ ព្រះរាជអាជ្ញាត្រូវចោទបទល្មើសនេះ ឬចង្អុលថាជននោះត្រូវតែចោទប្រកាន់តាមដែលខ្លួនយល់ឃើញនោះទេ។ ការធ្វើដូច្នេះជាការបំពានអំណាច តែតុលាការអាចរ៉ាយរាប់ជាសំងាត់ ពីការមិនសប្បាយចិត្តរបស់ខ្លួនទៅថ្នាក់លើរបស់ព្រះរាជអាជ្ញា។

▪ ព្រះរាជអាជ្ញា ត្រូវស្រាវជ្រាវអង្គហេតុឱ្យបានគ្រប់ជ្រុងជ្រោយ មិនត្រូវជឿជាក់លើកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌ទាំងស្រុងទេ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុរួច បញ្ជូន ទៅព្រះរាជអាជ្ញាពិនិត្យថាមានពិរុទ្ធភាព ក៏គ្មានពិរុទ្ធភាព បើគ្មានពិរុទ្ធភាពត្រូវដោះលែងជននោះឱ្យសេរីភាពឡើងវិញ ជាហេតុនាំឱ្យព្រះរាជអាជ្ញាខាតពេលវេលា ។

▪ ព្រះរាជអាជ្ញា ត្រូវគោរពតាមនីតិវិធី ដែលច្បាប់បានចែងឱ្យមានម៉ឺងម៉ាត់ អស់ពីសមត្ថភាព និងសតិសម្បជញ្ញៈរបស់ខ្លួនដែលយល់ថាជារឿងដែលត្រឹមត្រូវហើយស្វែងរកប្រយោជន៍ ជូនសង្គមជាតិ ដើម្បីធានាឱ្យបានសន្តិភាព។

▪ ការចោទប្រកាន់ ត្រូវតែមាន តម្លាភាព សុក្រឹតភាព ចំពោះបុគ្គលគ្រប់រូបដែលបានប្រព្រឹត្តល្មើសផ្ទុយពីច្បាប់បានចែងចូលជាធរមាន ទទួលបានភាពសាកសមនូវរាល់ទង្វើដែលជនទាំងឡាយបានប្រព្រឹត្តល្មើសនាំឱ្យរំខានដល់ការរស់នៅក្នុងសង្គម ប៉ះពាល់ សិទ្ធិ សេរីភាព ប្រយោជន៍ បុគ្គលដទៃទៀត ។

▪ ហើយត្រូវតែចោទប្រកាន់ រាល់បទល្មើសទាំងឡាយណាដែលច្បាប់បានចែងដល់ តួនាទី សិទ្ធិ និងអំណាច មិនត្រូវខ្លាចនូវអំណាចបុគ្គលណាម្នាក់ ធ្វើការចោទប្រកាន់ត្រឹមត្រូវតាមច្បាប់។

❖ សាលាឧទ្ធរណ៍

▪ បច្ចុប្បន្ននៅប្រទេសកម្ពុជាសាលាឧទ្ធរណ៍មានតែនៅរាជធានីមួយ និងឧទ្ធរណ៍តំបន់បី វាពិតជាបានជួយសម្រួលដល់ការស្វែងយុត្តិធម៌ និងបានធ្វើឱ្យសេវាយុត្តធម៌កាន់តែខិតជិតនឹងប្រជាពលរដ្ឋមែន។ ប៉ុន្តែគួរតែ

ត្រូវបង្កើតសាលាឧទ្ធរណ៍តំបន់បន្ថែមទៀត ព្រោះប្រជាពលរដ្ឋក្រីក្រ និងរស់នៅជនបទ ដែលពិបាកធ្វើដំណើរទៅតាមតំបន់នីមួយៗ មិនមានភាពងាយស្រួលក្នុងការធ្វើដំណើរ។

- ចំពោះសាលាឧទ្ធរណ៍ភ្នំពេញ គប្បីមានទីតាំងមួយឱ្យបានសមរម្យជាងពេលបច្ចុប្បន្ន ដោយហេតុថា សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញស្ថិតនៅក្នុងបរិវេណរបស់ក្រសួងយុត្តិធម៌នៅឡើយ ដែលរូបភាពខាងក្រៅមើលទៅដូចស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ក្រសួង។

- ការកកស្ទះ និងការកើនឡើងនៃបណ្ដឹងឧទ្ធរណ៍ ធ្វើឱ្យការឃុំខ្លួនរបស់ពិរុទ្ធជន មានរយៈពេលយូរ ឬលើសពីរយៈពេលដែលច្បាប់បានកំណត់ដែលប៉ះពាល់ដល់សិទ្ធិបុគ្គល និងប្រឆាំងទៅនឹងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស។

- មិនថាក្នុងការដោះស្រាយបញ្ហាកកសន្ទះសំណុំរឿង ឬបង្កើតបន្ថែមសាលាឧទ្ធរណ៍ដើម្បីបង្កើនឱ្យសេវាយុត្តិធម៌កាន់តែសម្បូណ៌បែបនោះទេ បើបុគ្គលិក ក្រឡាបញ្ជី មន្ត្រីបម្រើការ និងមន្ត្រីពាក់ព័ន្ធក្នុងការអនុវត្តកិច្ចការយុត្តិធម៌ពុំមានឆន្ទៈមោះមុត ប្ដេជ្ញាបម្រើការងារ និងស្វែងយុត្តិធម៌ឱ្យប្រជាពលរដ្ឋទេនោះ ប្រព័ន្ធយុត្តិធម៌កម្ពុជានៅតែទទួលរងការរិះគន់ ជំនឿជឿជាក់លើប្រព័ន្ធយុត្តិធម៌មិនមានការផ្លាស់ប្ដូរ តែបែរជាធ្វើឱ្យមានការខូតខាតកិត្យានុភាព កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។ ដូច្នេះបើទោះបីជាមានសាលាឧទ្ធរណ៍តំបន់នៅគ្រប់ទីកន្លែងពេញផ្ទៃប្រទេសក៏ប្រព័ន្ធយុត្តិធម៌គ្មានភាពប្រសើរឡើងឡើយ។

# ឯកសារយោង

# ឯកសារយោង

## ១ . ច្បាប់ និងបទដ្ឋានគតិយុត្ត

### ក. រដ្ឋធម្មនុញ្ញ

១. រដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៥៩។

២. រដ្ឋធម្មនុញ្ញ សាធារណៈរដ្ឋ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២។

៣. រដ្ឋធម្មនុញ្ញ សាធារណៈរដ្ឋប្រជាមានិតកម្ពុជា ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១។

៤. រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩។

៥. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ១៩៩៣។

### ខ. សន្ធិសញ្ញាអន្តរជាតិ

១. អង្គការសហប្រជាជាតិប្រចាំកម្ពុជា. ២០០៧ លិខិតុបករណ៍អន្តរជាតិស្តីពីចៅក្រម ព្រះរាជអាជ្ញា និង មេធាវីៈ គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា. ភ្នំពេញៈ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិនៅកម្ពុជា។

### គ. ក្រម

១. ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើសក្រម នីតិវិធីព្រហ្មទណ្ឌ។

### ឃ. ច្បាប់

១. ព្រះរាជក្រមលេខ លេខ នស/ រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

២. ព្រះរាជក្រមលេខ លេខ នស/ រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។

៣. ព្រះរាជក្រមលេខ លេខ នស/ រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

៤. ក្រឹត្យលេខ០៦ ក្រ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាព របស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា។

៥. ក្រឹត្យច្បាប់លេខ ៣៤ក្រ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ១៩៨៧ ប្រកាសឱ្យប្រើច្បាប់ស្តីពី ការចាត់តាំងនឹង សកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល។

**ខ. បទបញ្ជា**

១. ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ប្រកាសឱ្យដាក់ដំណើរការសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

២. ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ប្រកាសឱ្យដាក់ដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ។

៣. ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ប្រកាសឱ្យដាក់ដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង។

៤. ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ប្រកាសឱ្យដាក់ដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុនិងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ។

៥. ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៣៩៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពី ឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រម និងព្រះរាជអាជ្ញា។

៦. ព្រះរាជក្រឹត្យលេខ នស/រកត/០៤២១/៣៤៥ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ស្តីពីការដាក់ដំណើរការសាលាដំបូងខេត្តកែប។

៧. ព្រះរាជក្រឹត្យលេខ នស/រកត/០៥២១/៤០៩ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ស្តីពីការផ្ទេរ និងតែងតាំងមុខតំណែង ប្រធាន អនុប្រធាន និងចៅក្រម។ (ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ)

៨. ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៩ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការតែងតាំង ប្រធាន អនុប្រធាន សាលាឧទ្ធរណ៍តំបន់។ (ប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងបាត់ដំបង)

៩. ព្រះរាជក្រឹត្យលេខ នស/រកត/០៧២០/៧៧៣ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការតែងតាំងមុខតំណែងជាប្រធាន និងចៅក្រម នៃសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ។

១០. ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៦៧៤ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការតែងតាំង។(អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល)

១១. ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២១១ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការតែងតាំងអគ្គព្រះ

១២. រាជអាជ្ញា អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់។ (អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ)

១៣. ព្រះរាជក្រឹត្យលេខ នស/រកត/០៧២០/៧៦៨ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការតែងតាំងមុខតំណែង។ (អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង)

## ២. ឯកសារជាសៀវភៅ និងអត្ថបទ

### ក. សៀវភៅ


១. លោក កុយ នាម និង ឡុង បញ្ញាវុធ, អង្គការអយ្យការ (ប្រវត្តិ និងការប្រៀបធៀប), ភ្នំពេញ, បោះពុម្ពលើកទី១, ឆ្នាំ២០០៦។

២. លោក កុយ នាម, ការសិក្សាការប្រៀបធៀបអំពីតុលាការកំពូល, ឆ្នាំ២០១៧។

៣. ហាប់ ផល្ធី, របៀបផ្តល់ប្រភពឯកសារ (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៧). អាចរកបាននៅ៖ https://phalthy.wordpress.com/documentatio/ (ចូលទស្សនាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១)។

៤. ចក សម្បត្តិ, នីតិវិធីព្រហ្មទណ្ឌកម្ពុជា, (២០១៩), អាចរកបាននៅ៖ https://salatraju.com/post/448 (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)។

៥. លោកសាស្ត្រាចារ្យជួន ប៊ុនធី, នីតិវិធីព្រហ្មទណ្ឌ អង្គការអយ្យការ


### ខ. ឯកសារជាអត្ថបទ


១. University of South Carolina, Law Library. (2018). *Guide to International and Foreign Law Research* [ការណែនាំអំពីការស្រាវជ្រាវច្បាប់អន្តរជាតិនិងច្បាប់បរទេស]. អាចរកបាននៅ៖ https://guides.law.sc.edu/c.php?g=315476&p=2108388 (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២១)។

២. The World Bank. (Updated 2021). *Key Features of Common Law or Civil Law Systems* [លក្ខណៈសំខាន់ៗនៃប្រព័ន្ធច្បាប់ទូទៅឬប្រព័ន្ធច្បាប់ស៊ីវិល]. អាចរកបាននៅ៖ https://ppp.worldbank.org/public-private-partnership/legislation-regulation/framework-assessment/legal-systems/common-vs-civil-law (ចូលទស្សនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១)

៣. រចនាសម្ព័ន្ធតុលាការកំពូល, គេហទំព័រ តុលាការកំពូល និងមហាអយ្យការ. អាចរកបាននៅ៖ http://www.supremecourt.gov.kh/judge (ចូលទស្សនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១)។

៤. គោលបំណង និងបេសកកម្ម, សមាគមន៍សាលាត្រាជូ. អាចរកបាននៅ៖ https://salatraju.com/About%20us/Objectifs%20and%20Missions (ចូលទស្សនាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១) ។

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

១ លិខិតុបករណ៍អន្តរជាតិស្តីពីចៅក្រម ព្រះរាជអាជ្ញា និងមេធាវីៈ គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា

២ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា

៣ ច្បាប់ស្តីពី ការចាត់តាំងនឹងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល

៤ ព្រះរាជក្រឹត្យស្តីពី ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

៥ ព្រះរាជក្រឹត្យស្តីពី ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ

៦ ព្រះរាជក្រឹត្យស្តីពី ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង

៧ ព្រះរាជក្រឹត្យស្តីពី ការដាក់ដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុនិងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ

៨ ព្រះរាជក្រឹត្យស្តីពី ឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រម និងព្រះរាជអាជ្ញា

៩ ព្រះរាជក្រឹត្យស្តីពី ការដាក់ដំណើរការ សាលាដំបូងខេត្តកែប

១០ ព្រះរាជក្រឹត្យស្តីពី ការការផ្ទេរ និងតែងតាំងមុខតំណែង ប្រធាន អនុប្រធាន និងចៅក្រម (ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ)

១១ ព្រះរាជក្រឹត្យស្តីពី ការតែងតាំង ប្រធាន អនុប្រធាន សាលាឧទ្ធរណ៍តំបន់ (ប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងបាត់ដំបង)

១២ ព្រះរាជក្រឹត្យស្តីពី ការតែងតាំងមុខតំណែងជាប្រធាន និងចៅក្រម នៃសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ

១៣ ព្រះរាជក្រឹត្យស្តីពី ការតែងតាំង (អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល)

១៤ ព្រះរាជក្រឹត្យស្តីពី ការតែងតាំងអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ (អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ)

១៥ ព្រះរាជក្រឹត្យស្ដីពី ការតែងតាំងមុខតំណែង (អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង)

១៦ ពាក្យបណ្ដឹងឧទ្ធរណ៍

១៧ សេចក្ដីជូនដំណឹង និងសេចក្ដីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ

១៨ ព្រះរាជក្រឹត្យស្ដីពី ការកំណត់ងារសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាតាមមុខតំណែង, ឯកសណ្ឋានចៅក្រម ព្រះរាជអាជ្ញា

១៩ ឯកសណ្ឋានមេធាវី

# គោលការណ៍ណែនាំស្ដីពី

# តួនាទី

# របស់ព្រះរាជអាជ្ញា

# Guidelines on the role of Prosecutors

# គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា

*អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីអំពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី ២៧ ខែសីហា ដល់ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៩០ ។*

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍នៅលើពិភពលោក បានអះអាងពីការប្តេជ្ញាចិត្តរបស់ខ្លួន ថានឹងបង្កើតនូវលក្ខខណ្ឌដែលអាចរក្សាបាននូវភាពយុត្តិធម៌ និងបានប្រកាសតាមគោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយរបស់ខ្លួនអំពីការធ្វើឲ្យបានសម្រេចនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកស្ទួយនិងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដោយឥតមានការបែងចែកពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ

*ដោយហេតុថា* សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស បានតំកល់ទុកនូវគោលការណ៍សមភាពចំពោះមុខច្បាប់ ការសន្មត់ជាមុនថាគ្មានទោសពៃរ៍ និងសិទ្ធិទទួលការជំនុំជំរះក្តីដ៏ត្រឹមត្រូវ និងជាសាធារណៈមួយ ពីតុលាការឯករាជ្យ និងមិនលំអៀង

*ដោយហេតុថា* ជាញឹកញាប់ នៅមានចន្លោះមួយរវាងទស្សនៈយល់ឃើញវែងឆ្ងាយដែលកំណត់គោលការណ៍ទាំងនោះជាមូលដ្ឋាន និងស្ថានការណ៍ពិត

*ដោយហេតុថា* ការរៀបចំនិងការគ្រប់គ្រងយុត្តិធម៌ នៅតាមបណ្តាប្រទេសទាំងឡាយ ត្រូវតែធ្វើតាមគោលការណ៍ទាំងនោះ ហើយត្រូវខិតខំប្រឹងប្រែងធ្វើការបកស្រាយគោលការណ៍ទាំងនោះឲ្យក្លាយជាការពិតយ៉ាងពេញលេញ

*ដោយហេតុថា* ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានច្បាប់នានា ដែលទាក់ទងទៅនឹងការអនុវត្តតាមការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួន គួរតែលើកស្ទួយការគោរព និងការប្រតិបត្តិតាមរបស់ខ្លួនចំពោះគោលការណ៍ទាំងឡាយដែលបានពោលខាងលើ ដូច្នេះនាំឲ្យមានការចូលរួមចំណែកដើម្បីភាពយុត្តិធម៌ខាងព្រហ្មទណ្ឌដ៏សមរម្យ សមភាព និងដើម្បីប្រជាពលរដ្ឋ ឲ្យមានប្រសិទ្ធិភាពប្រឆាំងនឹងឧក្រិដ្ឋកម្ម

*ដោយហេតុថា* ជាការចាំបាច់ត្រូវធានាថា ព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិជំនាញដែលតម្រូវក្នុងការបំពេញមុខងាររបស់ខ្លួនឲ្យបានសម្រេច តាមរយៈរូបមន្តនៃការជ្រើសរើសដ៏ល្អប្រសើរ និងការហ្វឹកហ្វឺនផ្នែកច្បាប់ និងជំនាញ ហើយនិងតាមរយៈការផ្តល់នូវគ្រប់មធ្យោបាយចាំបាច់ ដើម្បី

គោលការណ៍ណែនាំដូចមានចែងខាងក្រោមនេះ ដែលត្រូវបានបរៀបចំឡើងយ៉ាងជាក់លាក់ដើម្បីជួយដល់រដ្ឋជាសមាជិកក្នុងការងាររបស់ខ្លួន ដើម្បីធានានិងលើកស្ទួយប្រសិទ្ធិភាព ភាពមិនលំអៀង និងភាពត្រឹមត្រូវរបស់ព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ គប្បីត្រូវបានគោរពតាម និងយកទៅពិចារណាដោយរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃនីតិកម្មជាតិ និងការអនុវត្តន៍របស់ខ្លួន ហើយគួរតែផ្សព្វផ្សាយដល់ព្រះរាជអាជ្ញា ព្រមទាំងអ្នកឯទៀតៗ ដូចជាចៅក្រម មេធាវី សមាជិកសាខាអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងសាធារណៈជនជាទូទៅ ។ គោលការណ៍ណែនាំបច្ចុប្បន្នត្រូវបានរៀបចំឡើងជាសំខាន់គឺសំដៅចំពោះព្រះរាជអាជ្ញាសាធារណៈ ក៏ប៉ុន្តែគោលការណ៍ទាំងនេះអនុវត្តបានដោយស្មើភាពគ្នា ក្នុងលក្ខណៈសមស្របចំពោះព្រះរាជអាជ្ញាទាំងឡាយដែលត្រូវបានតែងតាំងឡើងនៅលើមូលដ្ឋានពិសេសផងដែរ ។

## *លក្ខណៈសម្បត្តិ ការជ្រើសរើស និងការហ្វឹកហ្វឺន*

១. ជនទាំងឡាយដែលត្រូវបានជ្រើសរើសធ្វើជាព្រះរាជអាជ្ញា ត្រូវតែជាឯកត្តជនដែលមានសេចក្តីសុចរិតនិងមានសមត្ថភាព ព្រមទាំងមានការហ្វឹកហ្វឺន និងលក្ខណៈសម្បត្តិសមរម្យផង ។

២. រដ្ឋទាំងឡាយត្រូវធានាថា ៖

«ក» លក្ខណៈជ្រើសរើសព្រះរាជអាជ្ញា ត្រូវមានការការពារមិនឲ្យមានការតែងតាំងទាំងឡាយណាដែលឈរលើភាពលំអៀង ឬបុរេនិច្ឆ័យ ដោយបំបាត់ចោលនូវរាល់ការរើសអើងណាមួយប្រឆាំងនឹងបុគ្គលនៅលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត សញ្ជាតិដើម ឋានៈសង្គម ឬជាតិពន្ធ ទ្រព្យសម្បត្តិ ដើមកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀត លើកលែងតែការតំរូវឲ្យបេក្ខជនសំរាប់ការិយាល័យអយ្យការនោះ ត្រូវតែមានសញ្ជាតិនៃប្រទេសសាម៉ីប៉ុណ្ណោះ ដែលគេមិនត្រូវចាត់ទុកថាជាការរើសអើងឡើយ ។

«ខ» ព្រះរាជអាជ្ញាត្រូវមានការអប់រំ និងការហ្វឹកហ្វឺនត្រឹមត្រូវ ហើយត្រូវឲ្យយល់ដឹងអំពីឧត្តមគតិ និងករណីយកិច្ចប្រកបដោយសីលធម៌នៃតួនាទីរបស់ខ្លួន យល់ដឹងអំពីការការពាររដ្ឋធម្មនុញ្ញ និងច្បាប់ចំពោះសិទ្ធិរបស់ជនជាប់សង្ស័យនិងជនរងគ្រោះ ហើយក៏ត្រូវយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិផង ។

## *ឋានៈ និងលក្ខ័ណ្ឌនៃសេវាកម្ម*

៣. ក្នុងនាមជាភ្នាក់ងារដ៏សំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវរក្សាខ្ជាប់គ្រប់ពេលវេលានូវកិត្តិយសនិងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួន ។

៤. រដ្ឋត្រូវធានាថា ព្រះរាជអាជ្ញាមានលទ្ធភាពអាចបំពេញមុខងារតាមវិជ្ជាជីវៈរបស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបង្អាក់ ការយាយីរំខាន ការជ្រៀតជ្រែកមិនសមស្រប ឬដាក់ឲ្យទទួលខុសត្រូវខាងរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬវិស័យដទៃទៀតដោយមិនសមហេតុផល ។

៥. ព្រះរាជអាជ្ញា និងក្រុមគ្រួសាររបស់គេ ត្រូវតែមានកិច្ចការពារខាងផ្លូវកាយពីសំណាក់អាជ្ញាធរនៅពេលណាដែលសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេទទួលនូវការគំរាមកំហែង ដោយសារតែការបំពេញមុខងារជាព្រះរាជអាជ្ញានោះ ។

៦. ការកំណត់លក្ខណ្ឌសេវាកម្មដ៏សមហេតុផលរបស់ព្រះរាជអាជ្ញា ប្រាក់ទូទាត់គ្រប់គ្រាន់សំរាប់ការងារដែលបានធ្វើ និងនៅទីណាដែលអាចអនុវត្តបាន រយៈពេលកាន់មុខតំណែង ប្រាក់សោធន និងអាយុចូលនិវត្តន៍ ត្រូវតែមានចែងក្នុងច្បាប់ ឬវិធាន ឬបទបញ្ជាទាំងឡាយដែលបានចេញផ្សាយ ។

៧. ការតម្លើងឋានៈព្រះរាជអាជ្ញា នៅទីណាក៏ដោយដែលមានប្រព័ន្ធបែបនេះ ត្រូវផ្អែកលើកត្តាសត្យានុម័តនានា ជាពិសេសគឺលក្ខណៈសម្បត្តិខាងវិជ្ជាជីវៈ សមត្ថភាព សេចក្ដីសុចរិត និងបទពិសោធន៍ ហើយត្រូវសំរេចឲ្យបានស្របតាមនីតិវិធីត្រឹមត្រូវ និងមិនលំអៀង ។

## *សេរីភាពក្នុងការបញ្ចេញមតិ និងបង្កើតសមាគម*

៨. ព្រះរាជអាជ្ញា ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ គឺមានសិទ្ធិសេរីភាពក្នុងការបញ្ចេញ មតិជំនឿ ការបង្កើតសមាគម និងការប្រជុំ ។ ជាពិសេសព្រះរាជអាជ្ញាមានសិទ្ធិចូលរួមចំណែកក្នុងការពិភាក្សាជាសាធារណៈនូវរាល់បញ្ហាដែលទាក់ទងនឹងច្បាប់ ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ការជំរុញនិងការពារសិទ្ធិមនុស្ស ព្រមទាំងការចូលរួម ឬបង្កើតអង្គការប្រចាំតំបន់ អង្គការជាតិ ឬអន្តរជាតិ និងចូលរួមការប្រជុំរបស់គេ ដោយគ្មានការទទួលរងនូវការបាត់បង់ផលប្រយោជន៍ខាងវិជ្ជាជីវៈដោយសារតែមូលហេតុនៃសកម្មភាពស្របច្បាប់ ឬដោយសារសមាជិកភាពរបស់គេនៅក្នុងអង្គការស្របច្បាប់ណាមួយនោះឡើយ ។ ក្នុងការប្រើប្រាស់នូវសិទ្ធិទាំងអស់នេះ ព្រះរាជអាជ្ញាជានិច្ចជាកាលត្រូវប្រតិបត្តិខ្លួនឲ្យស្របតាមច្បាប់ និងបទដ្ឋានព្រមទាំងក្រមសីលធម៌ទាំងឡាយនៃវិជ្ជាជីវៈរបស់ខ្លួនដែលត្រូវបានគេទទួលស្គាល់ ។

៩. ព្រះរាជអាជ្ញា មានសិទ្ធិសេរីភាពក្នុងការចូលរួមនិងបង្កើតសមាគមវិជ្ជាជីវៈ ឬអង្គការដទៃទៀត ដើម្បីតំណាងឲ្យផលប្រយោជន៍របស់ខ្លួន ដើម្បីលើកស្ទួយការហ្វឹកហ្វឺនវិជ្ជាជីវៈ ហើយនិងដើម្បីការពារឋានៈរបស់ខ្លួន ។

១០. តួនាទីអយ្យការត្រូវតែចែកឱ្យដាច់ពីមុខងារតុលាការ ។

១១. ព្រះរាជអាជ្ញាត្រូវដើរតួយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ដែលច្បាប់អនុញ្ញាតិ ឬ ស្របតាមការអនុវត្តន៍ក្នុងស្រុក ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពក្នុងការសើបអង្កេតនានា ពិនិត្យមើលការអនុវត្តន៍សាលក្រម និងការបំពេញតួនាទីផ្សេងៗទៀត ដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ ។

១២. ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ មឹងម៉ាត់ និងឱ្យបានឆាប់រហ័ស ស្របតាមច្បាប់កំណត់ ហើយត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូរបស់មនុស្ស និងលើកកំពស់សិទ្ធិមនុស្ស ហេតុដូច្នេះ ត្រូវរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងមានភាពរលូន ។

១៣. ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ :

(ក) អនុវត្តមុខនាទីរបស់ខ្លួន ដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទវប្បធម៌ ជាតិសាសន៍ សាសនា ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត ។

(ខ) ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ ។

(គ) រក្សារឿងក្តីជាការសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬបើពុំដូច្នោះទេ គឺជាតំរូវការរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ ។

(ឃ) ពិនិត្យមើលពីទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះដល់ជនរងគ្រោះដើម្បីឱ្យស្របតាមសេចក្តីប្រកាសស្តីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះ ក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច ។

១៤. ព្រះរាជអាជ្ញាមិនត្រូវផ្តើមគំនិតចោទប្រកាន់ ឬបន្តចោទប្រកាន់ ឬមិនត្រូវខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីតំកល់រឿងមិនចាត់ការ នៅពេលដែលការស៊ើបអង្កេតដោយលំអៀងមួយបង្ហាញឱ្យឃើញថា ការចោទប្រកាន់នេះពុំមានមូលដ្ឋាន ។

១៥. ព្រះរាជអាជ្ញា ត្រូវផ្តល់ការយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញាចំពោះមន្ត្រីសាធារណៈ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសពីអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋដទៃទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយនិងការស៊ើបអង្កេតអំពីបទល្មើសទាំងនេះ នៅទីណាដែលមានការអនុញ្ញាតិដោយច្បាប់ ឬស្របទៅនឹងការអនុវត្តន៍តាមតំបន់ ។

១៦. នៅពេលណាដែលព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនជាប់ សង្ស័យដែលគេដឹងឬមានជំនឿលើមូលដ្ឋានសមហេតុផលថា ភស្តុតាងទាំងនោះបានមកដោយប្រើប្រាស់វិធីមិនស្របច្បាប់ ដែលអាចចាត់ទុកបានថាជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវអមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតនោះ ព្រះរាជអាជ្ញាត្រូវបដិសេធមិនប្រើភស្តុតាងបែបនោះប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬត្រូវជំរាបដល់តុលាការតាមនោះ ហើយត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថាអ្នកដែលទទួលខុសត្រូវចំពោះការប្រើវិធីបែបនោះ ត្រូវបាននាំខ្លួនមកកាន់តុលាការ ។

## *មុខការឆន្ទានុសិទ្ធ*

១៧. នៅបណ្តាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានប្រគល់ឲ្យនូវមុខការឆន្ទានុសិទ្ធិ ច្បាប់ វិធាន ឬបទបញ្ញាទាំងឡាយដែលបានចេញផ្សព្វផ្សាយ ត្រូវមានចែងអំពីគោលការណ៍ណែនាំដើម្បីលើកស្ទួយភាពយុត្តិធម៌ត្រឹមត្រូវ និងមិនប្រែប្រួលនៃវិធីធ្វើសេចក្តីសំរេចនានា ក្នុងដំណើរការធ្វើបណ្តឹងអាជ្ញា ដោយរួមទាំងការចាប់អនុវត្តន៍ ឬការលប់ចោលបណ្តឹងអាជ្ញានោះផង ។

## *ជំរើសផ្សេងៗក្នុងការធ្វើបណ្តឹងអាជ្ញា*

១៨. ស្របតាមច្បាប់ជាតិ ព្រះរាជអាជ្ញាត្រូវធ្វើការពិចារណាសមស្រប ក្នុង ការលប់ចោលបណ្តឹងអាជ្ញា បញ្ឈប់ការរឿងក្តីដោយមានភ្ជាប់លក្ខ័ណ ឬដោយឥតលក្ខ័ណ ឬដោយការបង្វែររឿងព្រហ្មទ័ណ្ឌចេញពីប្រព័ន្ធយុត្តិធម៌ជាផ្លូវការ ដោយគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់សង្ស័យនិងជនរងគ្រោះ ។ តាមគោលបំណងនេះ រដ្ឋទាំងឡាយត្រូវរិះរកលទ្ធភាពឲ្យបានពេញលេញក្នុងការអនុម័តយកតាមគំរោងការណ៍បង្វែរ ដែលមិនត្រឹមតែជួយសំរាលបន្ទុកដ៏ច្រើនលើសលប់របស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជៀសវាងបាននូវ ភាពអាប់យសពីការឃុំខ្លួនមុនការជំនុំជំរះក្តីពីដីកាចោទប្រកាន់ និងពីការកាត់ឲ្យជាប់ទោស ព្រមទាំងពីផលមិនល្អដែលអាចកើតមានពីការដាក់ឲ្យជាប់ពន្ធនាគារទៀតផង ។

១៩. នៅបណ្តាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានគេផ្តល់ឲ្យនូវមុខការឆន្ទានុសិទ្ធ ដូចជាការសំរេចថាតើត្រូវបណ្តឹងអាជ្ញាចំពោះយុវជនប្រព្រឹត្តបទល្មើសឬអត់នោះ គេត្រូវតែផ្តោតការពិចារណាពិសេសៗទាំងឡាយទៅលើប្រភេទនិងទម្ងន់នៃបទល្មើស ទៅលើកិច្ចការពារសង្គម ទៅលើបុគ្គលិកលក្ខណៈ និងសាវតារបស់យុវជននោះសិន ។ ក្នុងការធ្វើសេចក្តីសំរេចនោះ ព្រះរាជអាជ្ញា ជាពិសេសត្រូវពិចារណាអំពីជំរើសផ្សេងៗដែលអាចមាន ដើម្បីជំនួសឲ្យការធ្វើបណ្តឹងអាជ្ញាក្រោមច្បាប់ និងនីតិវិធីទាំងឡាយដែលពាក់ព័ន្ធស្តីពីយុត្តិធម៌សំរាប់យុវជន ។ ព្រះរាជអាជ្ញាត្រូវព្យាយាមខិតខំឲ្យអស់ពីលទ្ធភាពរបស់ខ្លួន ក្នុងការចាត់វិធានការធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជនតែនៅពេលណាដែលចាំបាច់ជាអប្បបរិមាប៉ុណ្ណោះ ។

## *ទំនាក់ទំនងជាមួយក្រសួង ឬស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល*

២០. ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពក្នុងការធ្វើបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាត្រូវខិតខំឲ្យអស់ពីសមត្ថភាពក្នុងកិច្ចសហការជាមួយនគរបាល តុលាការ មេធាវី អ្នកការពារក្តីសាធារណៈ ហើយនិងជាមួយក្រសួង ឬស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាល ។

## *ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យ*

២១. បទល្មើសនឹងវិន័យរបស់ព្រះរាជអាជ្ញា ត្រូវផ្អែកទៅលើច្បាប់ ឬបទបញ្ញាស្របច្បាប់នានា ។ បណ្តឹងតវ៉ាប្រឆាំងនឹងព្រះរាជអាជ្ញាដែលចោទថា ព្រះរាជអាជ្ញានោះបានប្រព្រឹត្តិយ៉ាងប្រត្យ័ក្សក្នុងលក្ខណៈមួយប្រាសចាកពីបទដ្ឋានវិជ្ជាជីវៈ ត្រូវតែដោះស្រាយឲ្យបានឆាប់រហ័ស និងត្រឹមត្រូវក្រោមនីតិវិធីសមស្រប ។ ព្រះរាជអាជ្ញាមានសិទ្ធិទទួលសវនាការដ៏ត្រឹមត្រូវមួយ ។ សេចក្តីសំរេច ត្រូវស្ថិតនៅក្រោមការពិនិត្យមើលឡើងវិញដែលប្រកបដោយឯករាជ្យភាព ។

២២. ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យលើព្រះរាជអាជ្ញា ត្រូវធានានូវការវាយតម្លៃ និងការសំរេចដែលមានសត្យានុម័ត ។ ការដាក់ទណ្ឌកម្ម នឹងត្រូវកំណត់សំរេចដោយស្របតាមច្បាប់ ស្របតាមបទវិន័យវិជ្ជាជីវៈ និងស្របតាមបទដ្ឋាន និងក្រមសីលធម៌ឯទៀតដែលបានបង្កើតឡើង ហើយនិងស្របទៅតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះផង ។

## *ការប្រតិបត្តិតាមគោលការណ៍ណែនាំ*

២៣. ព្រះរាជអាជ្ញាត្រូវគោរពតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះ ។ គេក៏ត្រូវបង្ការ ព្រមទាំងប្រឆាំងឲ្យបានសកម្មទល់នឹងការរំលោភណាមួយដែលកើតមាន ឲ្យអស់ពីលទ្ធភាពដែលខ្លួនអាចធ្វើទៅបានផងដែរ ។

២៨. ព្រះរាជអាជ្ញាទាំងឡាយណាដែលជឿដោយមានហេតុផលគួរជឿថា មានការរំលោភណាមួយទៅលើគោលការណ៍ណែនាំបច្ចុប្បន្នបានកើតឡើង ឬជិតនឹងកើតឡើងនោះ ត្រូវរាយការណ៍អំពីបញ្ហានោះដល់អាជ្ញាធរថ្នាក់លើរបស់ខ្លួន ហើយនៅទីណាដែលចាំបាច់ ត្រូវរាយការណ៍ដល់អាជ្ញាធរ ឬអង្គការសមស្របនានា ដែលត្រូវបានគេប្រគល់អំណាចឲ្យដើម្បីដោះស្រាយ ឬដើម្បីពិនិត្យមើលឡើងវិញ ។

# ច្បាប់

# ស្តីពី

# ការចាត់តាំង និង សកម្មភាព

# របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា

ក្រុមប្រឹក្សារដ្ឋ
៚៙៛

លេខ: ០៦ ក្រ

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល
៙៙៙៙៙៙

# ក្រឹត្យ
៚៙៛

## ក្រុមប្រឹក្សារដ្ឋ
## នៃ
## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៥

## សំរេច
៚៙៛

ប្រកាសអោយប្រើ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃ រដ្ឋកម្ពុជា ដែលរដ្ឋសភា នៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៣ នាសម័យប្រជុំលើកទី ២៤ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ១៩៩៣
ជ.ក្រុមប្រឹក្សារដ្ឋ
ប្រធាន
ហត្ថលេខា និង ត្រា : ហេង សំរិន

កន្លែងទទួល :

- ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
- គ្រប់ទីស្តីការរដ្ឋមន្ត្រីនិងស្ថាប័នថ្នាក់ប្រហាក់ប្រហែល
- គ្រប់គណៈកម្មាធិការប្រជាជនខេត្ត ក្រុង
- រដ្ឋកិច្ច
- កាលប្បវត្តិ - ឯកសារ

ដើម្បីចម្លងចែក
ក្រុមប្រឹក្សារដ្ឋ

ចាន់ វ៉េន

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

******

# ច្បាប់

## ស្តីពី

## ការចាត់តាំង និងសកម្មភាព

## របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

<u>មាត្រា១</u> . សាលាជំរះក្តីនៃរដ្ឋកម្ពុជាមាន :

- តុលាការខេត្ត ក្រុង
- តុលាការយោធា
- សាលាឧទ្ធរណ៍
- តុលាការកំពូល

<u>មាត្រា២</u> . តុលាការខេត្ត.ក្រុង និង តុលាការយោធា ជាសាលាជំរះក្តីជាន់ទាប ។

. តុលាការខេត្ត.ក្រុង ដែលត្រូវតាំងនៅខេត្ត.ក្រុង មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃខេត្ត.ក្រុងទាំងនោះ ។

. តុលាការយោធា ដែលត្រូវតាំងនៅក្រុងភ្នំពេញ មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃរដ្ឋកម្ពុជាទាំងមូល ។

<u>មាត្រា៣</u> . សាលាឧទ្ធរណ៍ និង តុលាការកំពូលដែលជាសាលាជំរះក្តីជាន់ខ្ពស់ ត្រូវតាំងនៅក្រុងភ្នំពេញ ។

សាលាឧទ្ធរណ៍ និង តុលាការកំពូល មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃរដ្ឋកម្ពុជាទាំងមូល ។

<u>មាត្រា៤</u> . សាលាជំរះក្តីគ្រប់ជាន់ថ្នាក់ ត្រូវជំនុំជំរះដោយផ្អែកលើច្បាប់ជាធរមាន និង ផ្អែកលើច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត ។

ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់ ចែងមិនបានច្បាស់ ឬច្បាប់មិនបានចែង ត្រូវជំនុំជំរះដោយផ្អែកទៅតាមទំនៀមទំលាប់ ប្រពៃណី វិចារណញ្ញាណ ឬ សមធម៌ ។

<u>មាត្រា៥</u> . នៅអមសាលាជំរះក្តីជាន់ទាបនីមួយៗ ត្រូវមានអយ្យការ និងនៅអមសាលាជំរះក្តីជាន់ខ្ពស់នីមួយៗ ត្រូវមានមហាអយ្យការ ។

ក្នុងរឿងព្រហ្មទណ្ឌ ក្រុមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើសេចក្តីសន្និដ្ឋានទោសដោយ

តាំងខ្លួនជាគូក្ដីដើមជាដរាប ។

ក្នុងរឿងរដ្ឋប្បវេណីនិងរឿងក្ដីផ្សេងៗទៀត ក្រុមអយ្យការជាគូក្ដីរណបគឺគ្រាន់តែជាអ្នកឱ្យយោបល់ បើយល់ឃើញថាជាការគួរ ។ ប៉ុន្តែក្នុងរឿងខ្លះដែលទាក់ទងរបៀបរៀបរយសាធារណៈ ក្រុមអយ្យការត្រូវតាំងខ្លួនជាគូក្ដីដើម ។

## ជំពូកទី ២

## តុលាការខេត្ត.ក្រុង

មាត្រា ៦ . តុលាការខេត្ត.ក្រុងមានសមត្ថកិច្ចជំនុំជំរះបើកផ្លូវឧទ្ធរណ៍នូវរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទរដ្ឋបាល និងវិវាទការងារ ។

តុលាការខេត្ត.ក្រុងជំនុំជំរះក្ដីមានចៅក្រមម្នាក់ និងត្រូវបំពេញដោយរដ្ឋអាជ្ញា ឬ រដ្ឋអាជ្ញារងម្នាក់ និងក្រឡាបញ្ជីម្នាក់ ។

មាត្រា ៧ . សាលក្រមសំរេចសេចក្ដីចំពោះមុខ បើកឱ្យប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតពីថ្ងៃកាត់សេចក្ដី ។

សាលក្រមកំបាំងមុខ បើកឱ្យប្ដឹងជំទាស់ក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ។ បើផុតកំណត់ប្ដឹងជំទាស់ អាចប្ដឹងឧទ្ធរណ៍បានក្នុងរយៈពីរខែ គិតពីថ្ងៃផុតកំណត់ប្ដឹងជំទាស់ ។

មាត្រា ៨ . បណ្ដឹងឧទ្ធរណ៍ មានអនុភាពផ្អាកជាបណ្ដោះអាសន្ននូវការអនុវត្តសាលក្រម ។

បណ្ដឹងឧទ្ធរណ៍ដែលទាក់ទងដល់សេចក្ដីសំរេចរបស់តុលាការ របស់ចៅក្រម ឬរបស់រដ្ឋអាជ្ញា ពុំមានអានុភាពផ្អាកសេចក្ដីសំរេចទាំងនោះទេ លើកលែងតែបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយរដ្ឋអាជ្ញា ក្នុងរឿងឃុំខ្លួន ឬ ដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ។

បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើនៅសាលាជំរះក្ដីដែលបានចេញសាលក្រមនោះ ។

អ្នកដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ ឬប្ដឹងជំទាស់ គឺរដ្ឋអាជ្ញា ឬជនទាំងឡាយដែលមានប្រយោជន៍ក្នុងរឿងក្ដីរួមមានគូក្ដី ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងបទរដ្ឋប្បវេណី ជនជាប់ចោទ មេធាវី ឬអ្នកការពារក្ដី ។

ក្រៅពីរឿងព្រហ្មទណ្ឌ បើរដ្ឋអាជ្ញាតាំងខ្លួនជាគូក្ដីដើម ទើបមានសិទ្ធិប្ដឹងឧទ្ធរណ៍បាន ។

## ជំពូកទី ៣

## តុលាការយោធា

មាត្រា ៩ . តុលាការយោធាមានសមត្ថកិច្ចជំនុំជំរះ បើកផ្លូវឧទ្ធរណ៍នូវបទល្មើសយោធា ។

បទល្មើសយោធា គឺជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធទៅនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ ។

ក្នុងករណីយោធិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញ ត្រូវតុលាការខេត្ត.ក្រុងជំនុំជំរះ ។

នីតិវិធីរបស់តុលាការយោធា ដូចគ្នានឹងនីតិវិធីរបស់តុលាការខេត្ត.ក្រុងដែរ ។

## ជំពូកទី ៤

## សាលាឧទ្ធរណ៍

<u>មាត្រា ១០</u>. សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ អំពីសាលក្រមរបស់ តុលាការខេត្ត ក្រុង និងតុលាការយោធា ដោយបើកផ្លូវឲ្យប្តឹងសារទុក្ខ ។

<u>មាត្រា ១១</u>. សមាសភាពជំនុំជំរះក្តីនៃសាលាឧទ្ធរណ៍ ត្រូវមានចៅក្រម ៣ នាក់ ដែលម្នាក់ធ្វើជាប្រធាន ។ សមាសភាពនៃសាលាជំរះក្តីនេះ ត្រូវបំពេញដោយអគ្គរដ្ឋអាជ្ញា ឬអគ្គរដ្ឋអាជ្ញារង ឬរដ្ឋអាជ្ញាម្នាក់នៃមហាអយ្យការ និង ក្រឡាបញ្ជីម្នាក់ ។

ក្នុងករណីជំនុំជំរះជាថ្មីឡើងវិញ សមាសភាពជំនុំជំរះក្តីនេះ ត្រូវមានចៅក្រម ៣ នាក់ ដែលម្នាក់ធ្វើជាប្រធាន ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជំរះលើកមុន ។

<u>មាត្រា ១២</u>. សាលដីកាសាលាឧទ្ធរណ៍សំរេចសេចក្តីចំពោះមុខ អាចប្តឹងសារទុក្ខបានក្នុងរយៈពេល ២ខែ គិតពីថ្ងៃកាត់សេចក្តី ។

សាលដីកាកំបាំងមុខ អាចប្តឹងជំទាស់បានក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ។ បើផុតកំណត់ប្តឹងជំទាស់ អាចប្តឹងសារទុក្ខបានក្នុងរយៈពេល ២ ខែ គិតពីថ្ងៃផុតកំណត់ប្តឹងជំទាស់ ។

<u>មាត្រា ១៣</u>. បណ្តឹងសារទុក្ខ មានអានុភាពផ្អាកជាបណ្តោះអាសន្ន នូវការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ ។ ប៉ុន្តែបណ្តឹងសារទុក្ខដែលទាក់ទងដល់ការឃុំខ្លួនជាបណ្តោះអាសន្ន ការដាក់ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ការតំកល់រឿងមិនចាត់ការ និង ការលើកលែងចោទប្រកាន់ ពុំមានអានុភាពផ្អាកការអនុវត្តសាលដីកាសាលាឧទ្ធរណ៍ឡើយ ។ បណ្តឹងសារទុក្ខត្រូវធ្វើនៅសាលាជំរះក្តីដែលបានចេញសាលដីកានោះ ។

អ្នកដែលមានសិទ្ធិប្តឹងសារទុក្ខ និងប្តឹងជំទាស់ គឺអគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ ឬជនដែលមានប្រយោជន៍ក្នុងរឿងទាំងឡាយរួមមាន : ភាគី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងបទរដ្ឋប្បវេណី ជនជាប់ចោទ មេធាវី អ្នកការពារ ។

## ជំពូកទី ៥

## តុលាការកំពូល

<u>មាត្រា ១៤</u>. តុលាកំពូលមានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងសារទុក្ខ អំពីសាលដីការបស់សាលាឧទ្ធរណ៍ ដោយជំនុំជំរះតែលើអង្គច្បាប់ មិនជំនុំជំរះអំពីអង្គហេតុទេ ។

ប៉ុន្តែក្នុងរឿងក្តីដែលមានបណ្តឹងសារទុក្ខជាលើកទី ២ សាលានេះត្រូវជំនុំជំរះរួមក្រុម ដោយជំនុំជំរះទាំងអង្គហេតុ និង អង្គច្បាប់ ។

<u>មាត្រា ១៥</u>. បណ្តឹងសើរើធ្វើបានចំពោះសាលក្រម ឬសាលដីកាស្ថាពរ ហើយដែលមានអំណាចដាច់ខាតហើយ ។

បណ្តឹងសើរើធ្វើបានក្នុងរឿងមជ្ឈិម និងរឿងឧក្រិដ្ឋ ក្នុងករណីមួយចំនួនដែលមានចែងក្នុងច្បាប់ ។

# ក្រុមប្រឹក្សារដ្ឋ



# ក្រឹត្យ- ច្បាប់

# ក្រឹត្យ-ច្បាប់លេខ ៣៤ ក្រ.ច

## ស្តីពី

## ការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល

## និងមហាអយ្យការអមតុលាការប្រជាជនកំពូល

ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៧

សម្រាប់ជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិតច្បាប់

នាំមកសិក្សាដោយ: ឈៀង សំណាង

២០២១

# I– ក្រុមប្រឹក្សារដ្ឋ

## ក្រឹត្យ – ច្បាប់

### ១– ក្រឹត្យ - ច្បាប់លេខ ៣៤ ក្រ.ច

ស្តីពី

ការចាត់តាំង និង សកម្មភាពរបស់តុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល

### ក្រុមប្រឹក្សារដ្ឋ

– បានឃើញរដ្ឋធម្មនុញ្ញ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ. ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ. ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និង មហាអយ្យការអមតុលាការប្រជាជនកំពូល ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ២៥ ក្រ. ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៨៥

– បានឃើញក្រឹត្យ – ច្បាប់ លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា

# សំរេច

## ជំពូកទី ១

## អំពីការចាត់តាំង និង សកម្មភាពរបស់តុលាការប្រជាជនកំពូល

មាត្រា ១ .— តុលាការប្រជាជនកំពូល ជាស្ថាប័នជំនុំជំរះខ្ពស់បំផុតនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

សកម្មភាពរបស់តុលាការប្រជាជនកំពូល មានទិសដៅពង្រឹងនីត្យានុកូលភាព ពង្រឹងសណ្ដាប់ធ្នាប់សង្គម ការពារផលប្រយោជន៍របស់សង្គម ការពារសិទ្ធិសេរីភាព និង ផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ និង ធានាអោយមានការអនុវត្តច្បាប់យ៉ាងត្រឹមត្រូវ និង ឯកភាពទូទាំងប្រទេសក្នុងក្របខ័ណ្ឌតុលាការ ព្រមទាំងមានទិសដៅអប់រំពលរដ្ឋ អោយមានស្មារតីស្មោះត្រង់ចំពោះមាតុភូមិ និង របបប្រជាធិបតេយ្យរបស់ប្រជាជន អោយមានឆន្ទៈគោរពយ៉ាងម៉ឺងម៉ាត់ និងត្រឹមត្រូវនូវរដ្ឋធម្មនុញ្ញ និង ច្បាប់របស់រដ្ឋ អោយគោរពវិន័យពលកម្មទ្រព្យសម្បត្តិសាធារណៈ សិទ្ធិសេរីភាពរបស់អ្នកដទៃ និង បទដ្ឋាននៃការរស់នៅក្នុងសង្គម ។

មាត្រា ២ — តុលាការប្រជាជនកំពូលមានប្រធាន ១ រូប អនុប្រធាន ១ រូប ឬ ច្រើនរូប ហើយនិងចៅក្រម ។ អនុប្រធានតុលាការប្រជាជនកំពូល ១ រូប ទទួលបន្ទុកផ្នែកយោធា ។

មាត្រា ៣ .— តុលាការប្រជាជនកំពូលមានសមត្ថកិច្ច ៖

— ជំនុំជំរះជាលើកទី ១ និង ជាលើកចុងក្រោយបង្អស់នូវរឿងទាំងឡាយដែលធ្ងន់ធ្ងរស្មុគស្មាញ ។

— ជំនុំជំរះបណ្ដឹងសាទុក្ខរបស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញាពីសាលក្រមដែលមានអានុភាពអនុវត្តសំរេចដោយសភាតុលាការប្រជាជនកំពូល តុលាការប្រជាជនខេត្ត - ក្រុង ឬ តុលាការយោធា ។

— ពិនិត្យគ្រប់សាលក្រមប្រហារជីវិត មុនពេលដាក់ជូនក្រុមប្រឹក្សារដ្ឋពិនិត្យ និងសំរេច ។

— ត្រួតពិនិត្យ និងតាមដានការងាររបស់តុលាការប្រជាជនខេត្ត - ក្រុង និង របស់តុលាការយោធា ដោយចេញសេចក្ដីណែនាំអនុវត្តច្បាប់ ដើម្បីអោយមានប្រសិទ្ធភាពទូទាំងប្រទេស ។

មាត្រា ៤.— តុលាការប្រជាជនកំពូលមានអង្គការចាត់តាំងដូចខាងក្រោម ៖

— ក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូល

— សភាតុលាការប្រជាជនកំពូល

ក្រៅពីអង្គការចាត់តាំងខាងលើនេះ មានបណ្តាទាយកដ្ឋានជំនួយការ ។

មាត្រា ៥ .— ក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូលមាន : ប្រធានតុលាការប្រជាជនកំពូល អនុប្រធានតុលាការប្រជាជនកំពូលទាំងអស់ និង ចៅក្រមមួយចំនួន ។ ចំនួនចៅក្រមនេះត្រូវសំរេចដោយក្រុមប្រឹក្សារដ្ឋ តាមសំណើរបស់ប្រធានតុលាការប្រជាជនកំពូល ។

មាត្រា ៦ .— ក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូលមានភារកិច្ច :

ក — ពិនិត្យ និង សំរេចថា សំណុំរឿងនេះ ជាសំណុំរឿងមានលក្ខណៈធ្ងន់ធ្ងរស្មុគស្មាញ ។ —

ខ — ពិនិត្យ និង សំរេចលើបណ្តឹងសាទុក្ខរបស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញា ពីសាលក្រមដែលមានអានុភាពអនុវត្ត សំរេចដោយសភាតុលាការប្រជាជនកំពូល តុលាការប្រជាជនខេត្ត-ក្រុង ឬ តុលាការយោធា ។

គ — ណែនាំសភាទាំងអស់នៃតុលាការប្រជាជនកំពូល អោយអនុវត្តច្បាប់ និង គោលការណ៍ជំនុំជំរះ ។

ឃ — សំរេចចាត់តាំងចៅក្រមក្នុងសភាទាំងឡាយរបស់តុលាការប្រជាជនកំពូល ។

ង — ពិភាក្សាលើសេចក្តីព្រាង លិខិតបទដ្ឋាននានាដែលទាក់ទងដល់ការងារតុលាការ ។

ច — ធ្វើសំណើសុំអោយក្រុមប្រឹក្សារដ្ឋបំភ្លឺបកស្រាយច្បាប់ ប្រសិនបើមានការចាំបាច់ ដើម្បីចៀសវាងការខ្វែងយោបល់ ក្នុងការអនុវត្តច្បាប់ ។

ឆ — បូកសរុប ដកពិសោធន៍ការងារជំនុំជំរះ ។

មាត្រា ៧ .— ក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូល ប្រជុំយ៉ាងតិចមួយដង ក្នុងមួយខែ តាមការអញ្ជើញ និង ស្ថិតនៅក្រោមការដឹកនាំរបស់ប្រធានក្រុមប្រឹក្សាចៅក្រម ។ ក្រុមប្រឹក្សាចៅក្រម សំរេចតាមមតិភាគច្រើននៃសមាជិករបស់ខ្លួន ។

អគ្គរដ្ឋអាជ្ញា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិចូលរួមក្នុងអង្គប្រជុំនៃក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូល ។

មាត្រា ៨ .— សភាតុលាការប្រជាជនកំពូលមាន :

- សភាផ្នែកព្រហ្មទណ្ឌ
- សភាផ្នែករដ្ឋប្បវេណី
- សភាផ្នែកយោធា ។

**មាត្រា ៩.—** សភាផ្នែកព្រហ្មទណ្ឌ និង សភាផ្នែករដ្ឋប្បវេណីនៃតុលាការប្រជាជនកំពូលមានសមត្ថកិច្ច

ក — ជំនុំជំរះជាលើកទី ១ និង ជាលើកចុងក្រោយបង្អស់នូវរឿងទាំងឡាយដែលធ្ងន់ធ្ងរស្មុគ្រស្មាញ ។

ខ — ជំនុំជំរះបណ្តឹងសាទុក្ខ របស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញាពីសាលក្រមមានអានុភាពអនុវត្តដែលសភាបានសំរេចជាលើកទី ១ និង ជាលើកចុងក្រោយបង្អស់រួចហើយតែមានការភ័ន្តច្រឡំ ហើយក្រុមប្រឹក្សាចៅក្រមតម្រូវអោយជំនុំជំរះសាឡើងវិញ ។

គ — ជំនុំជំរះបណ្តឹងសាទុក្ខរបស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញាពីសាលក្រម ដែលមានអានុភាពអនុវត្តសំរេចដោយតុលាការប្រជាជន ខេត្ត-ក្រុង ។

ក្នុងករណីបដិសេធសាលក្រមរបស់តុលាការប្រជាជន ខេត្ត-ក្រុង សភាតុលាការប្រជាជនកំពូលអាចជំនុំជំរះផ្ទាល់បាន ឬ បង្វិលសំណុំរឿងទៅតុលាការដើម ដើម្បីជំនុំជំរះសាឡើងវិញក៏បាន

**មាត្រា ១០.—** ប្រធានសភាផ្នែកព្រហ្មទណ្ឌ និង ប្រធានសភាផ្នែករដ្ឋប្បវេណីនៃតុលាការប្រជាជនកំពូលមានភារកិច្ច ៖

ក - ដឹកនាំការងារតុលាការក្នុងមុខជំនាញរបស់ខ្លួន ។

ខ - ធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជំរះ ឬ ចាត់តាំងចៅក្រមមួយរូបអោយធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជំរះ ឬ ចាត់តាំងចៅក្រមអោយធ្វើជាសមាជិកនៃក្រុមប្រឹក្សាជំនុំជំរះ ។

គ — ធ្វើរបាយការណ៍ការងារតុលាការ ជូនក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូល ។

**មាត្រា ១១.—** អនុប្រធានសភាតុលាការប្រជាជនកំពូល ជួយប្រធានក្នុងការបំពេញភារកិច្ច ឬ ជំនួសប្រធាននៅពេលប្រធានអវត្តមាន ។

**មាត្រា ១២.—** នៅពេលជំនុំជំរះ ក្រុមប្រឹក្សាជំនុំជំរះនៃសភាផ្នែកព្រហ្មទណ្ឌ និង សភាផ្នែករដ្ឋប្បវេណី ត្រូវមានទីប្រឹក្សាប្រជាជនចូលរួម ។

បញ្ជីរាយនាមទីប្រឹក្សាប្រជាជនរបស់តុលាការប្រជាជនកំពូល ត្រូវរៀបចំដោយក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ដោយសហការជាមួយសហព័ន្ធ

សហជីពកម្ពុជា មជ្ឈិមសម្ព័ន្ធយុវជនប្រជាជនបដិវត្តកម្ពុជា មជ្ឈិមសមាគមន៍នារីបដិវត្តកម្ពុជា ។ អាណត្តិ និង ចំនួនទីប្រឹក្សាប្រជាជន ត្រូវកំណត់ដោយក្រុមប្រឹក្សារដ្ឋតាមសំណើរបស់ប្រធានតុលាការប្រជាជនកំពូល ។

**មាត្រា ១៣ .—** នៅពេលជំនុំជំរះជាលើកទី ១ និងជាលើកចុងក្រោយបង្អស់ ក្រុមប្រឹក្សាជំនុំជំរះនៃសភាផ្នែកព្រហ្មទណ្ឌ និង សភាផ្នែករដ្ឋប្បវេណី ត្រូវមានចៅក្រម ៣ រូប ដែល ១ រូបជាប្រធាន និងទីប្រឹក្សាប្រជាជន ២ រូប ។

ក្នុងនីតិវិធីជំនុំជំរះ បណ្តឹងសាទុក្ខរបស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញាពីសាលក្រមដែលមានអានុភាពអនុវត្ត សំរេចដោយសភាផ្នែកព្រហ្មទណ្ឌ ឬ សភាផ្នែករដ្ឋប្បវេណីនៃតុលាការប្រជាជនកំពូល, ក្រុមប្រឹក្សាជំនុំជំរះ ត្រូវមានចៅក្រម ៤ រូប ដែល ១ រូប ជាប្រធាន និង ទីប្រឹក្សាប្រជាជន ៣ រូប ហើយសុទ្ធតែអ្នកដែលមិនបានចូលរួមក្នុងការជំនុំជំរះជាលើកទី ១ និងជាលើកចុងក្រោយបង្អស់ ។

**មាត្រា ១៤ .—** ក្នុងនីតិវិធីជំនុំជំរះ បណ្តឹងសាទុក្ខរបស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញាពីសាលក្រមដែលមានអានុភាពអនុវត្ត សំរេចដោយតុលាការប្រជាជនខេត្ត-ក្រុង ក្រុមប្រឹក្សាជំនុំជំរះនៃសភាផ្នែកព្រហ្មទណ្ឌ និង សភាផ្នែករដ្ឋប្បវេណី ត្រូវមានចៅក្រម ៣ រូប ដែល ១ រូបជាប្រធាន និង ទីប្រឹក្សាប្រជាជន ២ រូប ។

**មាត្រា ១៥ .—** ក្រុមប្រឹក្សាជំនុំជំរះ នៃសភាផ្នែកព្រហ្មទណ្ឌ និង សភាផ្នែករដ្ឋប្បវេណី ត្រូវធ្វើការជាសមូហភាព និង សំរេចតាមមតិភាគច្រើន ។

**មាត្រា ១៦ —** បណ្តឹងសាទុក្ខរបស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញា ត្រូវធ្វើឡើងក្នុងរយៈពេល ១ ឆ្នាំ គិតពីថ្ងៃដែលសាលក្រមមានអានុភាពអនុវត្ត ។

ក្នុងករណីពិសេសខ្លះ និងដើម្បីជាផលប្រយោជន៍ដល់ទណ្ឌិត តុលាការប្រជាជនកំពូលអាចទទួលបណ្តឹងសាទុក្ខរបស់ប្រធានតុលាការប្រជាជនកំពូល ឬ របស់អគ្គរដ្ឋអាជ្ញា ពីសាលក្រមព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តបាន ទោះបីជាបណ្តឹងសាទុក្ខនោះហួសរយៈពេលមួយឆ្នាំក៏ដោយ ។

**មាត្រា ១៧ .—** ប្រធានតុលាការប្រជាជនកំពូលមានភារកិច្ច និង សិទ្ធដូចតទៅ :

ក — ធ្វើរបាយការណ៍ស្តីពីការងារតុលាការប្រជាជនកំពូល ជូនរដ្ឋសភា និង ជូនក្រុមប្រឹក្សារដ្ឋនៅចន្លោះសម័យប្រជុំរដ្ឋសភា ។

ខ — ធ្វើជាប្រធានអង្គប្រជុំក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូល ។

គ — ធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជំរះរបស់សភាតុលាការប្រជាជនកំពូល ក្នុងករណីចាំបាច់ ។

ឃ — ប្ដឹងសាទុក្ខពីសាលក្រមមានអានុភាពអនុវត្តដែលសភាតុលាការប្រជាជនកំពូល ឬ តុលាការប្រជាជនខេត្ត - ក្រុង ឬ តុលាការយោធា បានសំរេចដោយភ័ន្តច្រឡំ ។

ង — ចាត់តាំងការបូកសរុប និង ផ្សព្វផ្សាយបទពិសោធន៍នៃការជំនុំជំរះ ។

ច — ផ្អាកជាបណ្ដោះអាសន្ននូវការអនុវត្តសាលក្រម និង សេចក្ដីសំរេចរបស់តុលាការ ប្រសិនបើមានមូលហេតុច្បាស់លាស់ ។

ឆ — តាមដាន និង ជំរុញការអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាចៅក្រមតុលាការប្រជាជនកំពូល និង ការអនុវត្តកម្មវិធីការងាររបស់សភាតុលាការប្រជាជនកំពូល ។

ជ — សម្រួលទំនាក់ទំនងការងាររវាងសភាទាំងអស់ រវាងនាយកដ្ឋានទាំងអស់ និង ផ្នែកផ្សេងទៀត របស់តុលាការប្រជាជនកំពូល ។

ឈ — ចាត់តាំងត្រួតពិនិត្យសាលក្រម និង ការងារសភាតុលាការប្រជាជនកំពូល តុលាការប្រជាជនខេត្ត - ក្រុង និង តុលាការយោធា ។

ញ — ចាត់តាំងចៅក្រមអោយចូលរួមក្នុងសមាសភាព ក្រុមប្រឹក្សាជំនុំជំរះ ក្នុងករណីដែលខ្វះចៅក្រម ។

ដ — ដឹកនាំ ចង្អុលទិសការងារស្រាវជ្រាវច្បាប់ និង ស្រាវជ្រាវគោលការណ៍ជំនុំជំរះ ។

ឋ — បង្កើត ឬ លុបនាយកដ្ឋាន និង អង្គភាពថ្នាក់ប្រហាក់ប្រហែល តែងតាំង ឬ រំសាយប្រធាន ឬ អនុប្រធាននាយកដ្ឋាន និង ថ្នាក់ប្រហាក់ប្រហែល លើកលែងតែ ប្រធាន ឬ អនុប្រធានសភាតុលាការប្រជាជនកំពូល និង ចៅក្រមដែលត្រូវតែងតាំង ឬ រំសាយដោយក្រុមប្រឹក្សារដ្ឋតាមសំណើរបស់ប្រធានតុលាការប្រជាជនកំពូល ។

មាត្រា ១៨ . — អនុប្រធានតុលាការប្រជាជនកំពូល ជួយប្រធានក្នុងការបំពេញភារកិច្ច និង ជំនួសប្រធាននៅពេលប្រធានអវត្តមាន តាមការផ្ទេរសិទ្ធិរបស់ប្រធាន ។

អនុប្រធានតុលាការប្រជាជនកំពូល អាចធ្វើជាប្រធានសភាតុលាការប្រជាជនកំពូលបាន

## ជំពូកទី ២

## អំពីការចាត់តាំង និង សកម្មភាពរបស់មហាអយ្យការអមតុលាការប្រជាជនកំពូល

**មាត្រា ១៩ .—** មហាអយ្យការអមតុលាការប្រជាជនកំពូល ជាស្ថាប័នខ្ពស់បំផុតរបស់អង្គការអយ្យការនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ក្នុងក្របខ័ណ្ឌការងាររបស់ខ្លួន មហាអយ្យការអមតុលាការប្រជាជនកំពូល មានភារកិច្ចការពារនីត្យានុកូលភាព ការពាររបបប្រជាធិបតេយ្យរបស់ប្រជាជន ការពារសណ្តាប់ធ្នាប់សង្គម និងទ្រព្យសម្បត្តិសាធារណៈ ធានាអោយមានការគោរពអាយុជីវិត ទ្រព្យសម្បត្តិ សិទ្ធិសេរីភាពរបស់ពលរដ្ឋ។

រាល់អំពើចំពារបំពានដល់ផលប្រយោជន៍របស់រដ្ឋ សមូហភាព និង ផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ ត្រូវតែបានវិនិច្ឆ័យត្រឹមត្រូវតាមច្បាប់ ។

**មាត្រា ២០ .—** មហាអយ្យការអមតុលាការប្រជាជនកំពូល មានអង្គការចាត់តាំង និងសមាសភាពដូចខាងក្រោម :

ក – មហាអយ្យការអមតុលាការប្រជាជនកំពូលចែកចេញជាបណ្តានាយកដ្ឋានជំនួយការ

ខ – មហាអយ្យការអមតុលាការប្រជាជនកំពូល :

អគ្គរដ្ឋអាជ្ញា ១រូប អគ្គរដ្ឋអាជ្ញារង ១ រូប ឬ ច្រើនរូប និង រដ្ឋអាជ្ញា ។ អគ្គរដ្ឋអាជ្ញារង ១រូប ទទួលបន្ទុកផ្នែកយោធា ។

**មាត្រា ២១ .—** តួនាទី និង ភារកិច្ចរបស់អគ្គរដ្ឋអាជ្ញា :

១ – អគ្គរដ្ឋអាជ្ញាដឹកនាំសកម្មភាពរបស់អយ្យការអមតុលាការប្រជាជនខេត្ត - ក្រុង និង អយ្យការអមតុលាការយោធា អោយឯកភាពទូទាំងប្រទេស ។

២ – អគ្គរដ្ឋអាជ្ញា អមតុលាការប្រជាជនកំពូលទទួលបន្ទុក :

— ចេញទិសដៅភារកិច្ច ផែនការការងារ លើគ្រប់វិស័យរបស់អយ្យការ ។

— ចេញសេចក្តីសំរេច សេចក្តីណែនាំ សារាចរ លក្ខន្តិកៈ បទបញ្ជា និង របៀបរបបធ្វើការងារដែលទាក់ទងរវាងអយ្យការទាំងអស់ ។

— ណែនាំ ត្រួតពិនិត្យ និង តាមដានសកម្មភាពរបស់អយ្យការខេត្ត ក្រុង និង អយ្យការយោធា ។

— ពិភាក្សាលើសេចក្តីព្រាងលិខិតបទដ្ឋាននានាដែលទាក់ទងដល់ការងារអយ្យការ ។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ  សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

# ស្ដីពី

# ដាក់ឱ្យដំណើរការ

# សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអម
# សាលាឧទ្ធរណ៍ភ្នំពេញ

នស/រកត/០៨១៩/១៣០០

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩

*នាំមកសិក្សាដោយ: អៀង សំអាង*

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខៈ ២១៤
ថ្ងៃៈ ពុធ ទី ២១ ខែ សីហា ឆ្នាំ ២០១៩
ម៉ោងៈ ១៥:០០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៩/៧៣០០

## ស្តីពី

## ការដាក់ឱ្យដំណើរការ
## សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS •

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។
សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។

**មាត្រា ២.-**

សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ត្រូវទទួលដោះស្រាយបណ្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចនានារបស់ សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសាលាដំបូងខេត្តកណ្ដាល និងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា ៣.-**

សំណុំរឿងទាំងឡាយដែលសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ បានទទួលជាសមត្ថកិច្ច ត្រូវបន្តចាត់ការសំណុំរឿងទាំងអស់នោះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីសាលាឧទ្ធរណ៍តំបន់ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ណាមួយ មិនទាន់អាចដំណើរការទៅបាន បណ្ដឹងឧទ្ធរណ៍ក្នុងតំបន់នោះ ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

[illegible]

ន សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ  សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

## ស្តីពី

## ដាក់ឱ្យដំណើរការ

## សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការ
## អមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ

នស/រកត/០៨១៩/១៣០១

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩

*នាំមកសិក្សាដោយៈ អៀង សំអាង*

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ២១៥
ថ្ងៃ: ចន្ទ ទី ២១ ខែ[illegible] ឆ្នាំ២០១៩
ម៉ោង: ១៥:០០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៩/១៣០១

## ស្តីពី
## ការដាក់ឱ្យដំណើរការ
## សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២.-**

សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ មានទីតាំងស្ថិតនៅខេត្តត្បូងឃ្មុំ។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ចាម និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម សាលាដំបូងខេត្តកំពង់ធំ និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ សាលាដំបូងខេត្តព្រះវិហារ និងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ សាលាដំបូងខេត្តក្រចេះ និងអយ្យការអមសាលាដំបូងខេត្តក្រចេះ សាលាដំបូងខេត្តស្ទឹងត្រែង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង សាលាដំបូងខេត្តរតនគិរី និងអយ្យការអមសាលាដំបូងខេត្តរតនគិរី សាលាដំបូងខេត្តមណ្ឌលគិរី និងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី សាលាដំបូងខេត្តព្រៃវែង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង សាលាដំបូងខេត្តស្វាយរៀង និងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង និងសាលាដំបូងខេត្តត្បូងឃ្មុំ និងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៧២៨. ១៩០៤. ១៣១៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

# ស្តីពី

# ដាក់ឱ្យដំណើរការ

# សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង

នស/រកត/០៨១៩/១៣០២

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩

*នាំមកសិក្សាដោយ: អៀង សំអាង*

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ៤១៦
ថ្ងៃ: ពុធ ទី២១ ខែមីនា ឆ្នាំ២០២០
ម៉ោង: ១៥:០០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៩/១៣០៤

## ស្តីពី

## ការដាក់ឱ្យដំណើរការ

## សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS

**មាត្រា ២.-**

សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង មានទីតាំងស្ថិតនៅខេត្តបាត់ដំបង។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ឆ្នាំង និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង សាលាដំបូងខេត្តពោធិ៍សាត់ និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ សាលាដំបូងខេត្តបាត់ដំបង និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង សាលាដំបូងខេត្តប៉ៃលិន និងអយ្យការអមសាលាដំបូងខេត្តប៉ៃលិន សាលាដំបូងខេត្តបន្ទាយមានជ័យ និងអយ្យការអមសាលាដំបូងខេត្តបន្ទាយ-មានជ័យ សាលាដំបូងខេត្តឧត្តរមានជ័យ និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងសាលាដំបូងខេត្តសៀមរាប និងអយ្យការអមសាលាដំបូងខេត្តសៀមរាប ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស/រកត.១៩០៨.១៣១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

## ស្ដីពី

## ដាក់ឱ្យដំណើរការ

## សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការ
## អមសាលាឧទ្ធរណ៍ព្រះសីហនុ

នស/រកត/០៨១៩/១៣០៣

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩

*នាំមកសិក្សាដោយ: អៀង សំអាង*

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ៤១៧
ថ្ងៃ: ពុធ ទី២១ ខែសីហា ឆ្នាំ២០១៩
ម៉ោង: ១៥:០០

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៩/៧៣០៣

## ស្ដីពី
## ការដាក់ឱ្យដំណើរការ
## សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

**មាត្រា ២.-**

សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ មានទីតាំងស្ថិតនៅខេត្តព្រះសីហនុ។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តតាកែវ និងអយ្យការអមសាលាដំបូងខេត្តតាកែវ សាលាដំបូងខេត្តកំពត និងអយ្យការអមសាលាដំបូងខេត្តកំពត សាលាដំបូងខេត្តកំពង់ស្ពឺ និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ សាលាដំបូងខេត្តកោះកុង និងអយ្យការអមសាលាដំបូងខេត្តកោះកុង និងសាលាដំបូងខេត្តព្រះសីហនុ និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*នស/រកត. ១៩០៨.១៣១៧*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៩*

*នរោត្តម សីហមុនី* (ហត្ថលេខា)

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

# ស្ដីពី

# ឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ ចៅក្រម និងព្រះរាជអាជ្ញា

*នស/រកត/០៥១៥/៣៩៨*

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥*

*នាំមកសិក្សាដោយ: អៀង សំអាង*

ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល
លេខៈ ១៣១៣......ក.អ.ជ
ថ្ងៃទី២៧.០៧.១៥ ម៉ោង ៩.២.៣០
បញ្ជូន..................................

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៣៧៦

## ស្តីពី

## ឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១..**

ព្រះរាជក្រឹត្យនេះ កំណត់អំពីឋានន្តរស័ក្តិ និងថ្នាក់ សម្រាប់ក្របខណ្ឌចៅក្រម និងក្របខណ្ឌព្រះរាជ-អាជ្ញា ក្នុងគោលដៅរៀបចំចៅក្រម និងព្រះរាជអាជ្ញា ឱ្យស្ថិតនៅក្រោមក្របខណ្ឌនៃអង្គចៅក្រមតែមួយ ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

-អនុព្រះរាជអាជ្ញា។

**មាត្រា ៨..**

ថ្នាក់សម្រាប់ឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានរៀបចំបែងចែក ដូចខាងក្រោម ៖

-ឋានន្តរស័ក្តិអនុចៅក្រម ឬអនុព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី៣ ដែលជាឋានន្តរស័ក្តិទាបបំផុត ដែលមាន ៤ (បួន) ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ ៤ (បួន) ដល់លេខ ១ (មួយ)។

-ឋានន្តរស័ក្តិវរៈចៅក្រម ឬវរៈព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី២ ដែលជាឋានន្តរស័ក្តិខ្ពស់បន្ទាប់ ដែលមាន ៤ (បួន) ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ ៤ (បួន) ដល់លេខ ១ (មួយ)។

-ឋានន្តរស័ក្តិឧត្តមចៅក្រម ឬឧត្តមព្រះរាជអាជ្ញា គឺជាឋានន្តរស័ក្តិទី១ ដែលជាឋានន្តរស័ក្តិខ្ពស់បំផុត ដែលមាន ៦ (ប្រាំមួយ) ថ្នាក់ ដោយរាប់ចាប់ពីថ្នាក់លេខ ៦ (ប្រាំមួយ) ដល់លេខ ១ (មួយ)។

**មាត្រា ៩..**

ថ្នាក់សម្រាប់ឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានកំណត់ឱ្យមានកម្រិតសន្ទស្សន៍បៀវត្ស មូលដ្ឋានដូចខាងក្រោម ៖

| ក្របខណ្ឌ | ឋានន្តរស័ក្តិ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក | ៣ | | | | ២ | | | | ១ | | | | | |
| | ថ្នាក់ | | | | ថ្នាក់ | | | | ថ្នាក់ | | | | | |
| | ៤ | ៣ | ២ | ១ | ៤ | ៣ | ២ | ១ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| | សន្ទស្សន៍បៀវត្ស | | | | សន្ទស្សន៍បៀវត្ស | | | | សន្ទស្សន៍បៀវត្ស | | | | | |
| | ៣៤៥ | ៣៥៤ | ៣៦៤ | ៣៧៩ | ៣៩៤ | ៤១០ | ៤២៦ | ៤៤៣ | ៤៦១ | ៤៧៩ | ៤៩៦ | ៥១៣ | ៥៣១ | ៥៥០ |

**មាត្រា ១០..**

តម្លៃឯកតានៃសន្ទស្សន៍បៀវត្សសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវកំណត់ដោយឡែកដោយអនុក្រឹត្យ។

## ជំពូកទី៤

## និយ័តកម្ម សមាហរណកម្មក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់

**មាត្រា ១១..**

ការធ្វើសមាហរណកម្មចៅក្រម និងព្រះរាជអាជ្ញា ទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃក្របខណ្ឌនៃអង្គចៅក្រម ត្រូវអនុលោមតាមមាត្រា ១០៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

**មាត្រា ១២..**

បន្ទាប់ពីការធ្វើសមាហរណកម្មរួច ចៅក្រម និងព្រះរាជអាជ្ញា អាចត្រូវបានធ្វើនិយ័តកម្មឡើងវិញនូវថ្នាក់ និងឋានន្តរស័ក្តិរបស់ខ្លួន ដោយផ្អែកលើមុខតំណែង ដោយប្រើប្រាស់យន្តការនៃគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

**មាត្រា ១៣..**

ការធ្វើសមាហរណកម្ម និងការធ្វើនិយ័តកម្មដែលមានចែងក្នុងមាត្រា ១១ និងមាត្រា ១២ ខាងលើនេះ ត្រូវរៀបចំទៅក្នុងឋានន្តរស័ក្តិ និងថ្នាក់ ដែលមានកម្រិត ឬសន្ទស្សន៍បៀវត្សខ្ពស់ជាង ឬយ៉ាងហោចណាស់ស្មើនឹងកម្រិត ឬសន្ទស្សន៍បៀវត្សនៃថ្នាក់បច្ចុប្បន្នរបស់ខ្លួន។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា ១៤..**

នៅពេលមិនទាន់មានអនុក្រឹត្យកំណត់តម្លៃឯកតានៃសន្ទស្សន៍បៀវត្សសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ដូចចែងក្នុងមាត្រា ១០ ខាងលើ តម្លៃឯកតានៃសន្ទស្សន៍បៀវត្សសម្រាប់មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះតម្លៃឯកតានៃសន្ទស្សន៍បៀវត្សសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៥..**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៥

៣៧.១៥០៥.៤០១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍនា**

លេខ: ៤១៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៧៤៥

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យដំណើរការសាលាដំបូងខេត្តកែប ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ នេះតទៅ។

នៅអមសាលាដំបូងខេត្តកែប មានអយ្យការមួយ ស្របតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ជាធរមានពាក់ព័ន្ធដទៃផ្សេងទៀត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២.-**

សាលាដំបូងខេត្តកែប មានទីតាំងស្ថិតនៅក្នុងខេត្តកែប និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីស្ថិតក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្ដប់លើខេត្តកែប ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា ៣.-**

សាលាដំបូងខេត្តកែប មានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ នេះតទៅ។

ចំពោះសំណុំរឿងក្ដីទាំងឡាយណាដែលស្ថិតក្នុងសមត្ថកិច្ចរបស់សាលាដំបូងខេត្តកែប ហើយដែលសាលាដំបូងខេត្តកំពតបានទទួលចាត់ការជាសមត្ថកិច្ច នៅមុនថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១នោះ សាលាដំបូងខេត្តកំពតត្រូវបន្តចាត់ការជាសមត្ថកិច្ចដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

វិធានដែលមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអយ្យការអមសាលាដំបូងខេត្តកំពត។

**មាត្រា ៤.-**

ក្នុងករណីដែលសាលាដំបូងខេត្តកែបមិនអាចដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្ដីដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សាលាដំបូងខេត្តកែបនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងខេត្តកំពត។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចេញប្រកាស ដើម្បីកំណត់អំពីការមិនអាចដំណើរការបាននៃសាលាដំបូងខេត្តកែប និងកំណត់ជាថ្មីអំពីកាលបរិច្ឆេទនៃការចាប់ផ្ដើមដំណើរការនៃសាលាដំបូងនេះ។

ប្រសិនបើសាលាដំបូងខេត្តកែបមានចៅក្រមមិនគ្រប់គ្រាន់ ឬខ្វះខាតចៅក្រមដោយមូលហេតុវិសេសភាពជាអាទិ៍ ប្រធានសាលាដំបូងខេត្តកែបត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីចាត់តាំងចៅក្រមពីសាលាដំបូងផ្សេងទៀតមកបំពេញការងារតាមការចាំបាច់។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្ដម សីហមុនី

**នរោត្តម សីហមុនី**

ពរក.០៤២១.៣៤៩

**បានប្រទានព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២១*

# ព្រះរាជក្រឹត្យ

នស/រកត/០៥២១/ ៤០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចរបស់ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## ត្រាស់បង្គាប់

**មាត្រា១**: ផ្ទេរ និងតែងតាំងមុខតំណែង ប្រធាន អនុប្រធាន និងចៅក្រម:

| | |
|---|---|
| ១-ឯកឧត្តម **យូ ម៉ិនឡេង** | ឧត្តមចៅក្រម ថ្នាក់លេខ១ តែងតាំងជាអនុប្រធានតុលាការកំពូល |
| ២-ឯកឧត្តម **សេង ស៊ីវុត្ថា** | ឧត្តមចៅក្រម ថ្នាក់លេខ១ តែងតាំងជាប្រធានសាលាឧទ្ធរណ៍ភ្នំពេញ |
| ៣-ឯកឧត្តម **ញូង ធុល** | អនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ ផ្ទេរមកជាអនុប្រធានសាលាឧទ្ធរណ៍បាត់ដំបង |
| ៤-លោកជំទាវ **ខៀវ សុខា** | វរៈចៅក្រម ថ្នាក់លេខ២ តែងតាំងជាអនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ |
| ៥-ឯកឧត្តម **យស់ ណារ៉ុង** | ឧត្តមចៅក្រម ថ្នាក់លេខ៦ តែងតាំងជាអនុប្រធានសាលាឧទ្ធរណ៍ ភ្នំពេញ |
| ៦-ឯកឧត្តម **យូ ម៉ិនណា** | វរៈចៅក្រម ថ្នាក់លេខ២ តែងតាំងជាអនុប្រធានសាលាឧទ្ធរណ៍ភ្នំពេញ |
| ៧-ឯកឧត្តម **អ៊ិត សម្ផស្ស** | ឧត្តមចៅក្រម ថ្នាក់លេខ៥តែងតាំងជាអនុប្រធានសាលាឧទ្ធរណ៍ព្រះសីហនុ |
| ៨-លោក **គី ឬទ្ធី** | ឧត្តមចៅក្រម ថ្នាក់លេខ៦ តែងតាំងជាចៅក្រមសាលាឧទ្ធរណ៍ភ្នំពេញ |
| ៩-លោក **ឌុច សុខសារិន** | ឧត្តមចៅក្រម ថ្នាក់លេខ៦ តែងតាំងជាចៅក្រមសាលាឧទ្ធរណ៍ភ្នំពេញ |

| | |
|---|---|
| ៨៥-លោក **ញូង ចន្នី** | ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ផ្ទេរមកជាចៅក្រមសាលាដំបូងខេត្តរតនគិរី |
| ៨៦-លោក **សាយ សារុន** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ផ្ទេរមកជាចៅក្រមសាលាដំបូងខេត្តរតនគិរី |
| ៨៧-លោក **ផេង ក្មសល** | ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ផ្ទេរមកជាចៅក្រមសាលាដំបូងខេត្តព្រះវិហារ |
| ៨៨-លោក **ស៊ិន ពិសិដ្ឋ** | ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ ផ្ទេរមកជាចៅក្រមសាលាដំបូងខេត្តព្រះវិហារ |
| ៨៩-លោក **អ៊ុក សុវណ្ណារិទ្ធ** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ផ្ទេរមកជាចៅក្រមសាលាដំបូងខេត្តកណ្តាល។ |

**មាត្រា២** : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស/រកត.២១០៥.៤១៣

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២១*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

# ព្រះរាជក្រឹត្យ

នស/រកត/០២២០/២០៧

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាស
- ឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាស
- ឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំង ប្រធាន អនុប្រធាន សាលាឧទ្ធរណ៍តំបន់:

| | |
|---|---|
| ១- ឯកឧត្តម **ម៉ុង មុនីចរិយា** | ឧត្តមចៅក្រម ថ្នាក់លេខ១ ជាប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ |
| ២- ឯកឧត្តម **សម ប៊ុនថុន** | ឧត្តមចៅក្រម ថ្នាក់លេខ៥ ជាប្រធានសាលាឧទ្ធរណ៍បាត់ដំបង |
| ៣- ឯកឧត្តម **ម៉េង ប៊ុនធឿន** | វរៈព្រះរាជអាជ្ញា ថ្នាក់លេខ១ ជាអនុប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដោយស្ថិតក្នុងឋានន្តរស័ក្តិ វរៈចៅក្រម ថ្នាក់លេខ១ |
| ៤- ឯកឧត្តម **ឆ្លូ មណី** | ឧត្តមចៅក្រម ថ្នាក់លេខ១ ជាអនុប្រធានសាលាឧទ្ធរណ៍បាត់ដំបង |
| ៥- ឯកឧត្តម **ប៉ាក ច័ន្ទសំបូរ** | ឧត្តមចៅក្រម ថ្នាក់លេខ១ ជាអនុប្រធានសាលាឧទ្ធរណ៍ព្រះសីហនុ |

**មាត្រា២:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧.២០០២.២១៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២០*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/០៧២០/ ៧៧៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែងជាប្រធាន និងជាចៅក្រម នៃសាលាឧទ្ធរណ៍ព្រះសីហនុ :

១-ឯកឧត្តម **សុខ កល្យាណ** ឧត្តមចៅក្រម ថ្នាក់លេខ ៦ ជាប្រធានសាលាឧទ្ធរណ៍ព្រះសីហនុ

២-លោកស្រី **អ៊ុន ម៉ានិត្យ** ឧត្តមចៅក្រម ថ្នាក់លេខ ៣ ជាចៅក្រមសាលាឧទ្ធរណ៍ព្រះសីហនុ។

**មាត្រា២ :** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ពរជ.២០០៧.៧៩៥

បានប្រថាប់ព្រះរាជលញ្ឆករហើយ

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២០*

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

3275
29.06.09

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ / នស / ៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ស្ថានភាពចាំបាច់នៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់គោលការណ៍នៃសមត្ថកិច្ចជាប់ចំណាង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំង ÷

១. លោកជំទាវ **ជា លាង** ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ជំនួសឯកឧត្តម **អ៊ុក វិធុន** ដែលត្រូវបានចូលនិវត្តន៍

២. ឯកឧត្តម **អ៊ុក សាវុធ** ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ជំនួសឯកឧត្តម **ហង់រ៉ូ វិរះគេន** ដែលត្រូវបានចូលនិវត្តន៍

៣. ឯកឧត្តម **គង់ ស្រ៊ឹម** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជំនួសលោក **ខៀវ សាម៉េត** ដែលត្រូវបានចូលនិវត្តន៍

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤. លោក **យ៉េត ចរិយា** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជំនួសលោក **ស៊ិន ឌឹម** ដែលត្រូវបានចូលនិវត្តន៍។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤** :ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

៣៩ល. ០៩០៦. ៦៤៣

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៩*

លេខ ២០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ [illegible] ខែមិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០២២០/៤១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២០

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់:

| | |
|---|---|
| ១- ឯកឧត្តម **ហួត វុទ្ធី** | ឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ៣ ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ |
| ២- ឯកឧត្តម **សរ យសឋាវរៈ** | ឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ១ ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ |
| ៣- ឯកឧត្តម **តន់ សីហាតេជ** | វរៈព្រះរាជអាជ្ញា ថ្នាក់លេខ១ ជាអគ្គព្រះរាជអាជ្ញារងនៃមហា អយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ |
| ៤- ឯកឧត្តម **យូ និត្យមន្ត្រៈ** | វរៈព្រះរាជអាជ្ញា ថ្នាក់លេខ៣ ជាអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ |
| ៥- លោក **ឡុល បុន** | វរៈព្រះរាជអាជ្ញា ថ្នាក់លេខ៤ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៦- លោក **ស្រី ម៉ាឥនី** វរៈព្រះរាជអាជ្ញា ថ្នាក់លេខ៤ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ

៧- លោក **រៀម ចន្ទធី** វរៈព្រះរាជអាជ្ញា ថ្នាក់លេខ៤ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

៨- លោក **ហោខ លុយ** វរៈព្រះរាជអាជ្ញា ថ្នាក់លេខ៣ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

៩- លោក **ហ៊ីខ ម៉ិនថន** វរៈព្រះរាជអាជ្ញា ថ្នាក់លេខ១ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

១០- លោក **ខៀវ ផល្លា** វរៈព្រះរាជអាជ្ញា ថ្នាក់លេខ៤ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ

១១- លោក **ផាន់ សុតត្រា** វរៈព្រះរាជអាជ្ញា ថ្នាក់លេខ៤ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ

១២- លោកស្រី **ស៊ី មល្លានី** វរៈព្រះរាជអាជ្ញា ថ្នាក់លេខ១ ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ

**មាត្រា២:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នស/រកត/០២២០/២១៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០២០*

**នរោត្តម សីហមុនី**

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/០៧២០/ ៧៦៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែង ឯកឧត្តម **នួន សាន** ឧត្តមព្រះរាជអាជ្ញា ថ្នាក់លេខ ៦ ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង។

**មាត្រា២ :** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

៣៧៧.២០០៧.៧៩០

បានប្រទាប់ព្រះរាជលញ្ឆករហើយ

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២០*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល លេខ ៦៥៥
ថ្ងៃទី០៥ ខែ១០ ឆ្នាំ២០១៦
ម៉ោង ៥ ៣០

# ពាក្យបណ្តឹងឧទ្ធរណ៍

១/ លោកមេធាវី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ៦៥២ មានការិយាល័យផ្ទ ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

២/ ស្រីមេធាវី " វី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ បង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

៣/ លោកមេធាវី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ៦៨០ មាន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានី ភ្នំពេញ

៤/ លោកមេធាវី ាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ៣២១ មានការិយាល័យផ្ទះលេខ១៤c ផ្លូវលេខ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥/ លោកមេធា ..សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ១៤២ មានការិយាល័យផ្ទះលេខ១៧AB ផ្លូវលេខ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ជាសហមេធាវីការពារសិទ្ធិឯកឧ.. ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ ជាប្រធានស្តីទីតំណាងរាស្ត្រភាគតិចនៃរដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម ។

## សូមគោរពចូលមក
## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ:** ប្តឹងឧទ្ធរណ៍ លើសាលក្រមព្រហ្មទណ្ឌលេខ២៨៦៧ "គ" ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**យោង:** - សាលក្រមព្រហ្មទណ្ឌលេខ២៨៦៧ "គ" ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០១៦របស់សាលាដំបូងរាជធានីភ្នំពេញ
- លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៦ ។

តបតាមកម្មវត្ថុ និងយោងខាងលើ សហមេធាវីសូមជម្រាបជូន លោកប្រធាន ជ្រាបថា ៖ សាលក្រមព្រហ្មទណ្ឌលេខ២៨៦៧ "គ" ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានី

ភ្នំពេញ បានធ្វើឡើងដោយភាពអយុត្តិធម៌ដល់កូនក្ដីរបស់យើងខ្ញុំយ៉ាងធ្ងន់ធ្ងរបំផុត មិនអាចទទួលយកបានឡើយ ។ ហេតុនេះយើងខ្ញុំសុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២៨៦៧ "គ" ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេច។

អាស្រ័យហេតុនេះ សូមលោកប្រធាន ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីយើងខ្ញុំ និង ចាត់ការតាមនីតិវិធីច្បាប់ តាមការគួរ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានដោយស្មោះអំពីយើងខ្ញុំ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ តុលា ឆ្នាំ២០១៦

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍**

លេខ ១២៧ ល.ជ.ណ/០១៦

សំណុំរឿងតម្កល់ទុកឥតចាត់ការលេខ ៥៧

ចុះថ្ងៃទី ២៣-០៣-២០១៦

គណបក្ស អំណាចខ្មែរ

ចូល

លេខ:..................

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦

បញ្ជូនមកពី:..................

## លិខិតជូនដំណឹង

## យើង អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍

## ជម្រាបមក

ឈ្មោះ សូន សេរីវដ្ឋា ភេទប្រុស អាយុ ៤២ឆ្នាំ ជនជាតិខ្មែរ ជាប្រធានគណបក្សអំណាចខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ២៨៤ ផ្លូវលេខ ១៥៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

អំពីបណ្ដឹងតវ៉ារបស់លោក ប្ដឹងពីដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៥០៣៨ ចុះថ្ងៃទី ២១-១២-២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីដំណើររឿង បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង នោះ យើងបានតម្កល់សេចក្ដីសម្រេចរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ដោយសេចក្ដីសម្រេចនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ តាមសេចក្ដីសម្រេចរបស់យើងលេខ ១២៧ សត.ប្រក.០១៦ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ។

ហេតុនេះ សូមលោក ជ្រាប ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦

**អគ្គព្រះរាជអាជ្ញា**

**អ៊ុក_សាវុធ**

យើង..............................មុខងារ.....................បាន
ប្រគល់លិខិតជូនដំណឹងនេះអោយឈ្មោះ ..........................
ទីលំនៅសព្វថ្ងៃនៅ.........................ឃុំ.សង្កាត់..................
ស្រុក.ខណ្ឌ..............................ខេត្ត.រាជធានី.....................
នៅថ្ងៃទី..............ខែ............ឆ្នាំ ២០១៦ រួចហើយ។

អ្នកទទួល អ្នកប្រគល់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍**
លេខ...១២៧......សត.ប្រក.០១៦

## សេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ

បានឃើញ មាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០-០៨-២០០៧ ស្តីពី «ការតម្កល់រឿងទុកឥតចាត់ការ»។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥០៣៨ ចុះថ្ងៃទី ២១-១២-២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿង «តម្កល់រឿងទុកឥតចាត់ការ» ចុះបញ្ជីនៅមហាអយ្យការអមសាលាឧទ្ធរណ៍លេខ ៥៧ ចុះថ្ងៃទី ២៣-០៣-២០១៦ ។

បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ២១-១២-២០១៥ របស់ឈ្មោះ សួន សេរីរដ្ឋា ភេទប្រុស អាយុ ៤២ឆ្នាំ ជនជាតិខ្មែរ ជាប្រធានគណបក្សអំណាចខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ២៤៤ ផ្លូវលេខ ១៥៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្តឹងចោទប្រកាន់លើឈ្មោះ ហោ ណាំហុង ភេទប្រុស អាយុ ៨០ឆ្នាំ ជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពីបទៈ បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឱ្យមានការរើសអើង ។

បានឃើញ ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សេចក្តីសុំប្តឹងតវ៉ាលេខ ០៣១ ចុះថ្ងៃទី ២១-០៣-២០១៦ របស់ឈ្មោះ សួន សេរីរដ្ឋា ប្តឹងតវ៉ានឹងដីកាតម្កល់រឿងទុកឥតចាត់ការខាងលើ ។

បានឃើញ កំណត់ហេតុសួរយកចម្លើយឈ្មោះ សួន សេរីរដ្ឋា នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖ កាលពីថ្ងៃទី ០៧-១២-២០១៥ ឈ្មោះ ហោ ណាំហុង បានធ្វើសន្និសីទព័ត៌មានបានប្រើពាក្យថា៖ "...ជាពិសេសគណបក្សនៃ...សេរីរដ្ឋា នៅអាមេរិក ដែលកន្លងមករហូតដល់មានសមាជិករបស់គេធ្វើអំពើភេរវកម្មនៅកម្ពុជាផង" ដែលពាក្យនេះធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តអ្នកគាំទ្រ និងធ្វើឱ្យការគាំទ្រមកលើគណបក្សមានការថយចុះ ដែលធ្វើឱ្យគណបក្សមានការលំបាកក្នុងការកសាងកំលាំងថ្មី ហើយបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់គណបក្សខ្លួន ។ កន្លងមក ខ្លួន និងសមាជិករបស់ខ្លួនពិតជាត្រូវបានតុលាការកម្ពុជាផ្តន្ទាទោសដាក់ពន្ធនាគារពីបទៈរួមគំនិតក្បត់ ប៉ុន្តែរូបខ្លួន និងសមាជិកត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹត្យលើកលែងទោសរួចហើយ ។ ខ្លួន និងសមាជិកមិនដែលមានពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើភេរវកម្មនោះទេ ។

បានឃើញ កំណត់ហេតុសួរយកចម្លើយឈ្មោះ ហោ ណាំហុង ឆ្លើយនៅអយ្យការអមសាលា ...

ដំបូងរាជធានីភ្នំពេញថា៖ កាលពីថ្ងៃទី ០៧-១២-២០១៥ ខ្លួនពិតជាបានជួបជាមួយអ្នកសារព័ត៌មាន ហើយបាននិយាយថាមានគណបក្សជាច្រើននៅកម្ពុជា គឺនិយាយជារួម មិនសំដៅតែលើគណបក្ស សូន សេរីរដ្ឋា នោះទេ ហើយក៏គ្មានចេតនាបរិហារកេរ្តិ៍ទៅលើឈ្មោះ សូន សេរីរដ្ឋា និងគណបក្ស របស់គេដែរ គឺក្នុងន័យបង្កប់ផ្តល់ព័ត៌មាន មិនមែនមានគោលបំណងបរិហារកេរ្តិ៍អ្នកណាទេ ព្រោះពេលនោះ ខ្លួនជួបអង្គទូតនៅភ្នំពេញ ខ្លួននិយាយពីសភាពការណ៍នយោបាយនៅកម្ពុជាជារួម ។ ខ្លួននិយាយថា សមាជិករបស់គេធ្វើអំពើភេរវកម្មនៅកម្ពុជា ដោយសំអាងហេតុថាមានសាលក្រម និងសាលដីការបស់តុលាការ ដែលបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើបុគ្គល សូន សេរីរដ្ឋា និងបក្ខពួក ពីបទៈ រួមគំនិតក្បត់ និងញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ប៉ុន្តែខ្លួននិយាយត្រឹមពាក្យភេរវកម្ម ដែលស្រាលជាងពាក្យរួមគំនិតក្បត់ទៅទៀត ។ មូលហេតុដែលខ្លួននិយាយដូច្នេះ ដោយហេតុថាមានសេចក្តីសម្រេចរបស់តុលាការ ដែលធ្វើឡើងជាសាធារណៈ ដែលប្រជាពលរដ្ឋទូទៅបានដឹងឮព្រមទាំងត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ហើយឈ្មោះ សូន សេរីរដ្ឋា ខ្លួនឯងក៏បានដឹងឮរឿងនេះដែរ ហើយឈ្មោះ សូន សេរីរដ្ឋា ប្តឹងខ្លួន គឺមានចេតនាប្តឹងមូលបង្កាច់កេរ្តិ៍ដល់រូបខ្លួនសុទ្ធសាធ ។

បានឃើញ ឯកសារផ្សេងៗពាក់ព័ន្ធក្នុងសំណុំរឿង ។

យល់ឃើញថា ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានសំអាងហេតុ សំអាងច្បាប់ និងសេចក្តីសម្រេចសមស្របតាមគតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះសម្រេច**

តម្កល់ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ ៧៩ អ.យ.ង ចុះថ្ងៃទី ២៩-០១-២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែជេស្ឋ ឆ្នាំ ២០១៦

**អគ្គព្រះរាជអាជ្ញា**

**អ៊ុក_សាវុធ**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៧/២៥៣

## ស្តីពី
## ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

## ត្រាស់បង្គាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ត្រូវបានបង្កើតឲ្យមាន ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

**មាត្រា ២._**

ព្រះរាជក្រឹត្យនេះ មានគោលបំណងរៀបចំឲ្យមាន ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតរបស់អង្គចៅក្រម។

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/២៥៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧
ស្តីពី ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានបំពេញមុខងារផ្សេងទៀត របស់អង្គចៅក្រម



ឯកសណ្ឋានក្នុងពេលជំនុំជម្រះ
របស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីជាន់ខ្ពស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យលេខ...នស/រកត/០២១៧/២៥៣.................. ចុះថ្ងៃទី២៨.. ខែកុម្ភៈ.. ឆ្នាំ២០១៧
ស្តីពី ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានបំពេញមុខងារផ្សេងទៀត របស់អង្គចៅក្រម



**ឯកសណ្ឋានក្នុងពេលជំនុំជម្រះ**
**របស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីជាន់ទាប**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/២៥៣ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៧
ស្តីពី ឯកសណ្ឋានក្នុងពេលជំនុំជម្រះ និងឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀត របស់អង្គចៅក្រម



ឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀត
របស់អង្គចៅក្រម ជាបុរសនិងជាស្ត្រី នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL •

